ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គជអប

NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ

# ស្ដីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០២៣

# របស់ គ.ជ.អ.ប.

រៀបចំដោយ ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

# មាតិកា

**មាតិកា** ....... i

**អក្សរកាត់** ....... ii

១. សេចក្តីផ្តើម ....... ១

២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព ....... ២

ក. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ ....... ៣

ខ. សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ....... ១៤

គ. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ....... ១៩

ឃ. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុនិងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ....... ២៨

ង. សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋាន ....... ៣១

៣. ស្ថានភាពហិរញ្ញវត្ថុ ....... ៣៥

៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ ....... ៣៧

៥. សកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២៤ ....... ៣៩

៦. សេចក្តីសន្និដ្ឋាន ....... ៤៣

**ឧបសម្ព័ន្ធ**

១. តារាងវឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពនីមួយៗ ....... ៤៥

២. តារាងវឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣របស់ស្ថាប័នអនុវត្ត ....... ៩៤

៣. តារាងស្ថានភាពនៃការគ្រប់គ្រងហានិភ័យ ....... ៩៧

# អក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| កជទី១ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០ |
| កជទី២ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២<br>ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ(២០២១-២០២៥)ដំណាក់កាលទី១នៃ កជទី២ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ដ.វ.វ. | គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| SNIF/ADB | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| I4Cs | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF/WB | ផែនការអនុវត្តគណនេយ្យភាពសង្គម |
| TSSD-AF/ADB | ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច ដំណាក់កាលទី២ |
| NASLA/ADB | គម្រោងគាំទ្រសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| LGCC-III<br>WRP/UNCDF | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| STARD/UNDP | គម្រោងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា |
| CNP/WB | គម្រោងអាហារូបត្ថម្ភនៅកម្ពុជា |
| ISD/GIZ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា |
| CCCA/UNDP | គម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា |
| Readiness/GCF | គម្រោងគាំទ្រស្ថាប័នទទួលហិរញ្ញប្បទានផ្ទាល់នៅកម្ពុជា ដើម្បីបំពេញលក្ខខណ្ឌទទួលស្គាល់ |
| CSOs | អង្គការសង្គមស៊ីវិល |

## ១. សេចក្តីផ្តើម

ផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ប្រចាំឆ្នាំ២០២៣ របស់ គ.ជ.អ.ប. ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាផែនការឆ្នាំទី៣នៃការអនុវត្ត កជទី២ (២០២១-២០៣០) ដែលត្រូវបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣។ ផែនការនេះ រួមមានលទ្ធផលរំពឹងទុកចំនួន៣១ សកម្មភាពជាអាទិភាពចំនួន៨០ និងសកម្មភាពលម្អិតចំនួន៣៣៨ និងគម្រោងថវិកាចំណាយសរុបមានចំនួន ៥.៣២១.៩៥៤ លានរៀល (១.៣៣០ លានដុល្លារ) ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន ៥.១៦៩.២៧៦លានរៀល (១.២៩២លានដុល្លារអាមេរិក) ស្មើនឹង៩៧% និងថវិកាកម្ចីនិងជំនួយឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាមានចំនួន១៥២.៦៧៩លានរៀល (៣៨លានដុល្លារអាមេរិក) ស្មើនឹង៣% នៃថវិកាសរុប។ ថវិកាចំណាយសរុបនេះ រួមបញ្ចូលទាំងថវិកាចំណាយសម្រាប់គាំទ្រដល់ការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាចំណាយសម្រាប់គាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ផ.ស.ថ. ឆ្នាំ២០២៣ របស់ គ.ជ.អ.ប. រួមមាន ៥សមាសភាគដូចខាងក្រោម៖

សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់
សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស
សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ
សមាសភាគទី៥ ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

**តារាងទី១ ៖ ផែនការចំណាយសរុបតាមសមាសភាគសម្រាប់ឆ្នាំ២០២៣ (គិតជាលានរៀល)**

| ល.រ. | សមាសភាគ | ថវិកា រាជរដ្ឋាភិបាល | ថវិកាកម្ចី | ថវិកាជំនួយ ឥតសំណង | សរុប |
|---|---|---|---|---|---|
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | 7,898 | - | 1,220 | 9,118 |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | 10,034 | - | 9,931 | 19,964 |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សថ្នាក់ក្រោមជាតិ | 3,118 | 8,417 | - | 11,536 |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | 5,145,346 | 28,320 | - | 5,173,666 |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | 2,880 | 98,721 | 6,070 | 107,671 |
| | **សរុបរួម** | **5,169,276** | **135,458** | **17,221** | **5,321,954** |
| | **គិតជាភាគរយ** | **97.13%** | **2.55%** | **0.32%** | **100%** |

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៣នេះ រៀបរាប់អំពីស្ថានភាពនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៣របស់ គ.ជ.អ.ប. គិតពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ រួមមាន៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាព ស្ថានភាពនៃការប្រើប្រាស់ថវិកា បញ្ហាប្រឈមនានា និង សកម្មភាពជាអាទិភាពសម្រាប់អនុវត្តឆ្នាំ២០២៤។

## ២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព

ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង **៧៦** និងសូចនាករចំនួន**១៤៩** នៃ ផ.ស.ថ. ឆ្នាំ២០២៣ របស់ គ.ជ.អ.ប. មានសកម្មភាពជាអាទិភាពចំនួន **៦៥** ស្មើនឹង **៨៥%** និងសូចនាករចំនួន**១២៥** ស្មើនឹង **៨៤%** ត្រូវបានអនុវត្តដូចមានសង្ខេបក្នុងតារាងខាងក្រោម។

**តារាងទី២ ៖ ស្ថានភាពនៃការអនុវត្តសកម្មភាពជាអាទិភាព**

| សមាសភាគ | បរិយាយ | សកម្មភាព អាទិភាព | បានអនុវត្ត (ចំនួន) | បានអនុវត្ត (%) |
|---|---|---|---|---|
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | 21 | 20 | 95% |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | 13 | 11 | 85% |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សថ្នាក់ក្រោមជាតិ | 20 | 18 | 90% |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | 13 | 9 | 69% |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | 9 | 7 | 78% |
| សរុប | | **76** | **65** | **85%** |

លទ្ធផលសំខាន់ៗនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៣ មានរៀបរាប់តាមសមាសភាគនីមួយៗ ដូចខាងក្រោម ៖

## ក. សមាសភាគទី១÷ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សមាសភាគទី១នេះ រួមមានសកម្មភាពជាអាទិភាពចំនួន២១ ក្នុងនោះមានសកម្មភាពអាទិភាពចំនួន២០ ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់

- ឆ្នាំ២០២៣នេះ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំលើកទី២១របស់ខ្លួន ដោយបានពិនិត្យ និងអនុម័តលើលិខិតបទដ្ឋានចំនួន០២ រួមមាន៖ (១)សេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ (២)ពិនិត្យ និងពិភាក្សាលើគោលការណ៍ផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ខណ្ឌ និងមូលនិធិឃុំ សង្កាត់ និងការផ្ទេរធនធានបន្ថែមសម្រាប់អភិវឌ្ឍន៍មូលដ្ឋានជូនរដ្ឋបាលឃុំ សង្កាត់ (២០២៤-២០២៨)។ ជាមួយគ្នានេះ គ.ជ.អ.ប. ក៏បានស្តាប់នូវសេចក្តីរាយការណ៍អំពីវឌ្ឍនភាពនៃការពិនិត្យ និងផ្តល់យោបល់លើមាត្រា និងជំពូកនានាដែលពាក់ព័ន្ធនឹងទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីជលផល និងសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើព្រមទាំងបានផ្តល់ការណែនាំឱ្យពន្លឿនការពិនិត្យ និងការផ្តល់យោបល់នេះ ដើម្បីត្រៀមដាក់ជូនកិច្ចប្រជុំគណៈរដ្ឋមន្ត្រី និងបញ្ជូនទៅរដ្ឋសភាមុនការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧។ ក្រោយពីកិច្ចប្រជុំលើកទី២១រួច រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យចំនួន០៣ រួមមាន ៖ (១) អនុក្រឹត្យលេខ១៥២ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ (២) អនុក្រឹត្យលេខ១៥៣ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ (៣) អនុក្រឹត្យលេខ១៥៤ អនក្រ.បក ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនមូលនិធិរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ពីឆ្នាំ២០២៤-២០២៨ ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ និង(៤) អនុក្រឹត្យលេខ២១៣ អនក្រ.បក ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

### ២. ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព

- អនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃលើការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពង្រីកការផ្ទេរមុខងារនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។

### ៣. ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

- លេខាធិការដ្ឋាន គ.ជ.អ.ប. មានបុគ្គលិកចំនួន ១៥០ នាក់ ក្នុងនោះបុគ្គលិកក្របខ័ណ្ឌមានចំនួន ៦៧នាក់ និងទីប្រឹក្សានិងមន្ត្រីកិច្ចសន្យាមានចំនួន ៨៣នាក់
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីលេខាធិការដ្ឋាន ចំនួន០៣ វគ្គ ដែលក្នុងនោះ ០២វគ្គ បណ្តុះបណ្តាលលើប្រធានបទស្តីពីនីតិវិធីប្រតិបត្តិ និងសវនកម្មផ្ទៃក្នុងរបស់

គ.ជ.អ.ប. នៅខែមករា និងខែមេសា ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន ៩៤នាក់ និងស្ត្រីចំនួន ៣៨នាក់ និង០១វគ្គទៀតលើប្រធានបទស្តីពីការងារសវនកម្ម និងក្រមសីលធម៌ និងការលើកឡើងវិញពីនីតិវិធីកិច្ចប្រតិបត្តិការរបស់ គ.ជ.អ.ប. នៅខែធ្នូ ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន៤១នាក់ និងស្ត្រីចំនួន១៧នាក់

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានបញ្ជូនមន្ត្រីទៅសិក្សារយៈពេលខ្លីនៅក្រៅប្រទេសអំពីវិមជ្ឈការហិរញ្ញវត្ថុនៅប្រទេសហូឡង់រយៈពេល១៥ថ្ងៃ ព្រមទាំងបានធ្វើទស្សនកិច្ចសិក្សានៅបណ្តាប្រទេសមួយចំនួន ដែលក្នុងនោះរួមមាន៖
  - ទស្សនកិច្ចសិក្សាទៅកាន់ខេត្តប៊ិញយឿងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមរយៈពេល ០៣ថ្ងៃ ដើម្បីសិក្សាស្វែងយល់អំពីការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី ដើម្បីសិក្សាស្វែងយល់អំពីការរៀបចំប្រព័ន្ធគ្រប់គ្រងថវិកានៅថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍមូលដ្ឋាន
  - ទស្សនកិច្ចសិក្សាទៅប្រទេសម៉ុងហ្គោលី ដើម្បីផ្លាស់ប្តូរមេរៀនបទពិសោធន៍ និងការអនុវត្តល្អៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ ដែលទស្សនកិច្ចសិក្សានេះបានចាប់ផ្តើមពីថ្ងៃទី២៨ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៣ ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
  - ការចូលរួមទស្សនកិច្ចសិក្សាជាមួយកំណែទម្រង់៣បូក១ ដើម្បីសិក្សាស្វែងយល់អំពីការធ្វើវិមជ្ឈការហិរញ្ញវត្ថុនៅសាធារណរដ្ឋកូរ៉េ
  - ការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការអនុវត្តនឹងកំណែទម្រង់វិមជ្ឈការ របស់ព្រះរាជាណាចក្រកម្ពុជានៅប្រទេសអាល្លឺម៉ង់
  - ការចូលរួមពិព័រណ៍ថ្នាក់តំបន់អំពីផែនការជាតិស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក ( NAP Expo for Asia Pacific ) នៅថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ នៅក្នុងទីក្រុង Incheon នៃសាធារណៈរដ្ឋកូរ៉េ ដើម្បីធ្វើការវាយតម្លៃអំពីការផ្តល់ហិរញ្ញប្បទានភាពបន្សាំសម្រាប់ស្ថាប័នជាតិ និងតំបន់ និងធ្វើបទបង្ហាញអំពីការគាំទ្រផែនការពង្រីកសម្រាប់ការអនុវត្តសកម្មភាពទាក់ទងទៅនឹងភាពបន្សាំការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាននៅក្នុងអាស៊ីប៉ាស៊ីហ្វិកជាផ្នែកមួយនៃពិព័រណ៍ NAP Expo ក្នុងនោះរួមមានមេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្តមូលនិធិ LoCAL
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានចាត់បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា និងកិច្ចប្រជុំនានានៅក្នុងប្រទេសលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចលទ្ធកម្ម ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងបុគ្គលិក យេនឌ័រ សុវត្ថិភាពបរិស្ថាននិងសង្គម ការគ្រប់គ្រងគម្រោង ការប្រែប្រួលអាកាសធាតុ ការងារគ្រោះមហន្តរាយ។ល។

## ៤. ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ដ.វ.វ.)

- គ.ដ.វ.វ. នៃក្រសួង ស្ថាប័នថ្នាក់ជាតិ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីត្រួតពិនិត្យ និងបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ.ឆ្នាំ២០២៣ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២០ ត្រូវបានរៀបចំចុះហត្ថលេខា និងបានអនុវត្ត
- គ.ដ.វ.វ. នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក បានរៀបចំកិច្ចប្រជុំ ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ទាំង ២៥ ត្រូវបានរៀបចំចុះហត្ថលេខា និងបានអនុវត្ត។

## ៥. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

- លេខាធិការដ្ឋានកំណែទម្រង់៣បូក១ បានធ្វើទស្សនកិច្ចសិក្សារួមគ្នាក្នុងការស្វែងយល់ និងដកស្រង់បទពិសោធន៍ អំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងបុគ្គលិកនៅសាធារណរដ្ឋកូរ៉េ ដែលដឹកនាំរៀបចំដោយអគ្គលេខាធិការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងអំឡុងខែមេសា ឆ្នាំ២០២៣
- បានរៀបចំកិច្ចប្រជុំយន្តការកំណែទម្រង់៣បូក១ ប្រចាំត្រីមាសទី១ និងត្រីមាសទី២ ដើម្បីបូកសរុបលទ្ធផលការងារកំណែទម្រង់ទាំង៤ និងបានរៀបចំផែនការសកម្មភាពសម្រាប់០៦ខែបន្ទាប់ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ដែលមានការចូលរួមពីលេខាធិការដ្ឋាននៃកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

## ៦. ការរៀបចំវេទិការ ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើការសិក្សាស្រាវជ្រាវ និងបានរៀបចំជាសេចក្តីព្រាងបឋមនូវឯកសារទស្សនទានសម្រាប់ការសិក្សា និងការរៀបចំវេទិការ ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៧. ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា

- ក្នុងឆ្នាំ២០២៣នេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តគម្រោង និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានសហការ និងការគាំទ្រពីដៃគូនានាក្នុងការពង្រឹងការគាំទ្រ ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យវាយតម្លៃលើការអនុវត្តមុខងារអប់រំ សុខាភិបាល ការគ្រប់គ្រងសំរាមនិងសំណល់រឹងទីប្រជុំជន ការផ្តល់សេវារដ្ឋបាល និងមុខងារផ្សេងទៀតដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានបញ្ជូននូវឯកសារសេចក្តីព្រាងផ.ស.ថ. ឆ្នាំ២០២៤របស់គ.ជ.អ.ប. ជូនដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យ និងផ្តល់យោបល់ និងបានត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការនៅដើមឆ្នាំ២០២៤។

## ៨. ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រុមការងារទទួលបន្ទុកការបញ្ជ្រាបយេនឌ័រនៅតាម ក្រសួង ស្ថាប័នបានរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងស្ថាប័នរបស់ខ្លួន
- គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលរាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ឆ្នាំ២០២៣នេះ ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ចំនួន៥៨៤នាក់ ស្មើនឹង២៧,៥១ %
- គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានរៀបចំកិច្ចប្រជុំរបស់ខ្លួនជាទៀងទាត់ ដើម្បីពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ឆ្នាំ២០២៣នេះ ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានចំនួន១.៦៨៦នាក់ ស្មើនឹង២៣,៥៨ %
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និង សមធម៌សង្គម នៅខេត្តកែប ខេត្តបន្ទាយមានជ័យ និងខេត្តស្វាយរៀងដល់មន្ត្រី ក្រសួង មន្ទីរកិច្ចការនារី ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ មកពីរាជធានីភ្នំពេញ ខេត្តទាំង២៥ ដែលរៀបចំឡើងដោយក្រសួងកិច្ចការនារី
- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីថវិកាឆ្លើយតបយេនឌ័រក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស្វែងរកការគាំទ្រមតិ នៅខេត្ត សៀមរាប និងខេត្តកំពង់ធំ ដល់ ប្រធាន/ អនុប្រធាន ការិយាល័យនៃក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីនិងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក មកពីរាជធានី ខេត្តចំនួន២០។

## ៩. ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

- បាន និងកំពុងសហការជាមួយនឹងមន្ត្រីនៃអង្គការ GIZ ដើម្បីពិនិត្យ និងកែសម្រួលយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយសកម្មភាពនេះគ្រោងនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២៤។

## ១០. ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

- បានរៀបចំ និងផ្សព្វផ្សាយឯកសារព័ត៌មានអំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃកដទី២ និងអំពីសមិទ្ធផលនានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងបានរៀបចំ និងកំពុងដំណើរការរៀបចំកញ្ចប់វីដេអូពាក់ព័ន្ធនឹងការងារវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់រួមមាន ៖
    - ផលិតវីដេអូបទយកការខ្លីស្តីពីការដឹកនាំល្អរបស់មេឃុំក្នុងការផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋាន
    - ផលិត និងកែសម្រួលវីដេអូបទយកការខ្លីស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំនៅស្រុកឈូក ខេត្តកំពត
    - ផលិតវីដេអូផ្សព្វផ្សាយបទយកការខ្លីស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង

- វីដេអូបទយកការខ្លីស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅមណ្ឌលសុខភាព ចន្លាស់ដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប
- អត្ថបទករណីសិក្សានៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅសាលាបឋមសិក្សាឃាយសល់
- វីដេអូអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី** អំពីការជំរុញការអនុវត្តលើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វីដេអូអប់រំអំពីការងារគណនេយ្យភាពសង្គម និងវីដេអូខ្លីអំពីខ្លឹមសារនៃកិច្ចប្រជុំផ្សព្វផ្សាយការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការងារគណនេយ្យភាពសង្គមដល់បណ្តាញសារព័ត៌មានក្នុងស្រុក
- ផ្សព្វផ្សាយ និងការសម្ពោធដាក់ឱ្យអនុវត្តគម្រោងគាំទ្រការងារគម្រោងគណនេយ្យភាពសង្គម
- ឯកសារព័ត៌មានចំនួន១៧០ឯកសារបានដាក់បញ្ចូល និងផ្សព្វផ្សាយក្នុងគេហទំព័រ និងក្នុងបណ្តាញសង្គមរួមមាន Facebook, YouTube និង Chanel Telegram NCDDS
- បានរៀបចំមាតិកាខ្លីៗ (Contents) អំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការងារគណនេយ្យភាពសង្គម ដើម្បីផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**១១. ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង**

- បាន និងកំពុងប្រមូលធាតុចូលនានាដែលពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ឧបករណ៍ និងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនរួមមាន ៖ រដ្ឋបាលរាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង និងខេត្តរតនគីរី ដែលទទួលបានការគាំទ្របច្ចេកទេស និងថវិកាពីអង្គការ GIZ។

**១២. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តចំណាក់កាលនីមួយៗនៃ កជទី២**

- ឯកសារផអ៥ទី១ មានចំនួន៥០០ក្បាល ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ដោយមានការគាំទ្រថវិកាពីគម្រោងលើកកម្ពស់ការផ្តល់សេវាសាធារណៈនៅប្រទេសកម្ពុជារបស់អង្គការ GIZ
- គិតមកដល់ឆ្នាំ២០២៣ដែលជាឆ្នាំទី៣នៃផអ៥ទី១ (២០២១-២០២៥) សកម្មភាពជាអាទិភាពដែលបានអនុវត្តមានចំនួន៧៣ ស្មើនឹង៦៥% នៃផអ៥ទី១។ ទន្ទឹមនឹងនោះ សូចនាករប្រចាំឆ្នាំដែលសម្រេចបានជាមធ្យមមានចំនួន ៨២% ធៀបនឹងសូចនាករនៃសកម្មភាពជាអាទិភាពដែលគ្រោងអនុវត្តក្នុងឆ្នាំនីមួយៗ។

**១៣. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.**

- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៣ របស់ គ.ជ.អ.ប. (ផ.ស.ថ.) ត្រូវបានរៀបចំឡើងដោយមានការដាក់បញ្ចូលនូវផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័នអនុវត្តនីមួយៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ ផ.ស.ថ. ប្រចាំឆ្នាំនេះ ត្រូវបានរៀបចំឡើងដោយមានការពិភាក្សា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា និងត្រូវបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃ

ទី០៩ ខែមីនា ឆ្នាំ២០២៣

- សកម្មភាពជាអាទិភាពចំនួន៦៣ ត្រូវបានអនុវត្តតាមផែនការស្មើនឹង៨៣% នៃសកម្មភាពអាទិភាពសរុបចំនួន៧៦ នៃ ផ.ស.ថ. ឆ្នាំ២០២៣ របស់ គ.ជ.អ.ប.
- សេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ដែលរួមបញ្ចូលលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងសូចនាករនានា ត្រូវបានរៀបចំបញ្ចប់ជាសេចក្តីព្រាង ដោយមានការពិភាក្សា និងពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា និងគ្រោងដាក់ជូនកិច្ចប្រជុំ គ.ជ.អ.ប. នៅដើមខែមករា ឆ្នាំ២០២៤
- សេចក្តីសម្រេចរួមឆ្នាំ២០២៣ រវាង លេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័នចំនួន ២០ និងរដ្ឋបាលរាជធានី ខេត្តចំនួន២៥ ត្រូវបានរៀបចំ អនុម័ត និងអនុវត្ត
- គម្រោង និងកម្មវិធីដាច់ដោយឡែកចំនួន ១៣ ដែលមាននៅក្នុង ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. មានដូចជា ៖ គម្រោង WB/ISAF-Supply Side, WB/ISAF-Demand Side, GIZ/ISD,UNICEF/លើកកម្ពស់វិស័យសេវាសង្គម, UNICEF/លើកកម្ពស់កិច្ចគាំពារកុមារ, UNCDF/LGCC-WRP, UNDP/CCCA, UNDP/STARD, UNDP/STA, ADB/SNIF, ADB/NASLA, GCF/READINESS, WB/CNP ត្រូវបានអនុវត្តទៅតាមគោលការណ៍ និងនីតិវិធីបានកំណត់។

**១៤. ការរៀបចំ និងការដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃ កជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ**

- ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តនីមួយៗ បានរៀបចំនូវផែនការសកម្មភាពដែលពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបានដាក់បញ្ចូលនូវផែនការសកម្មភាពទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តនីមួយៗ។

**១៥. ការរៀបចំគម្រោងនានាគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្សីុជាមួយ កជទី២**

- គម្រោង និងកម្មវិធីដាច់ដោយឡែកចំនួន ០៨ បានជួយគាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់មួយចំនួនមានដូចជា ៖ គម្រោង WB/ISAF-Supply Side, WB/ISAF-Demand Side, GIZ/ISD, UNCDF/LGCC-WRP, ADB/SNIF, ADB/NASLA, GCF/READINESS និង UNDP/STA។

| ល.រ | គម្រោង/គោលបំណង | រយៈពេលអនុវត្ត | គាំទ្រដោយ | ថវិកា | ភ្នាក់ងារអនុវត្ត |
|---|---|---|---|---|---|
| ១ | ការគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ (ISAF) ៖ គម្រោងមានគោលដៅធ្វើឱ្យប្រសើរនូវការបំពេញការងាររបស់អង្គភាពផ្តល់សេវាសាធារណៈតាមរយៈការរៀបចំ និងធ្វើឱ្យក្លាយជាប្រព័ន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីធ្វើឱ្យប្រសើរឡើងតម្លាភាព ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបតម្រូវការនានា។ | ២០២០-២០២៣ | មូលនិធិបរធនបាលកិច្ចគ្រប់គ្រងដោយធនាគារពិភពលោក (គាំទ្រថវិកាដោយរដ្ឋាភិបាលអាល្លឺម៉ង់ SDC) | ១.៧២លានដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ២ | ការលើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (CSOs) ៖គម្រោងមានគោលដៅធ្វើឱ្យប្រសើរនូវការបំពេញការងាររបស់អង្គភាពផ្តល់សេវាសាធារណៈតាមរយៈការរៀបចំ និងធ្វើឱ្យក្លាយជាប្រព័ន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីធ្វើឱ្យប្រសើរឡើងតម្លាភាព ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបតម្រូវការនានា។ | ២០២០-២០២៣ | • មូលនិធិបរធនបាលកិច្ចគ្រប់គ្រងដោយធនាគារពិភពលោក(គាំទ្រថវិកាដោយរដ្ឋាភិបាលអាល្លឺម៉ង់ SDC និងរដ្ឋាភិបាលអូស្ត្រាលី)<br>• សហភាពអឺរ៉ុប<br>• USAID | ២៤.៨ លានដុល្លារ | • អង្គការទស្សនៈពិភពលោក<br>• អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) អង្គការផែអន្តរជាតិ |
| ៣ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា (GIZ/ISD) ដោយផ្តោតជាសំខាន់លើការផ្តល់សេវាសាធារណៈដោយមានការចូលរួមពីប្រជាពលរដ្ឋ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ | ខែមីនា ឆ្នាំ ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៥ | ទីភ្នាក់ងារសហប្រតិបត្តិ ការអន្តរជាតិអាល្លឺម៉ង់(ជីអាយ ហ្សេត GIZ) កម្ពុជា | ៩.៨១៨.១៨២អឺរ៉ូ | លេខាធិការដ្ឋាន គ.ជ.អ.ប. |

| | | | | | |
|---|---|---|---|---|---|
| ៤ | រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ "ពង្រីកការអនុវត្តមូលនិធិធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ នវានុវត្តនៃការផ្គត់ផ្គង់ទឹកស្អាតធន់ទៅនឹងការប្រែប្រួលអាកាសធាតុតាមបែបវិមជ្ឈការ" (UNCDF/LGCC-WRP) ក្នុងគោលបំណង គាំទ្រដល់ការអនុវត្តមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងទឹកស្អាត កែលម្អបង្កើនសមត្ថភាពស្ថាប័ននិងការសម្របសម្រួលសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ទឹកស្អាតរបស់សហគមន៍មូលដ្ឋាន និងបង្កើនភាពធន់ និងសមត្ថភាពបន្សាំនៃជីវភាពរស់នៅតាមជនបទទៅនឹងផលប៉ះពាល់អាកាសធាតុ និងហានិភ័យលើធនធានទឹកនៅក្នុងតំបន់ងាយរងគ្រោះបំផុតចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ | ២០២០-២០២២ ពន្យារការអនុវត្តដល់ឆ្នាំ២០២៣ | UNCDF ក្រសួងបរិស្ថាន នៃសាធារណៈរដ្ឋកូរ៉េ | ៧៤៨,៤០០ ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៥ | គម្រោងគាំទ្រមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (ADB/SNIF) ដើម្បីគាំទ្ររដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | | រាជរដ្ឋាភិបាល ADB | ៧លានដុល្លារ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦ | គម្រោងគាំទ្រការសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងការអភិវឌ្ឍសមត្ថភាព(ADB/NASLA) ផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធរបស់សាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។ | ២០២៣-២០២៥ | រាជរដ្ឋាភិបាល ADB | ៦.១៥លាន ដុល្លារ | ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន) |

| | | | | | |
|---|---|---|---|---|---|
| ៧ | គម្រោងស្ដីពីការគាំទ្រដល់ស្ថាប័នដែលមានសិទ្ធិទទួលហិរញ្ញប្បទានដោយផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង (GCF) នៅកម្ពុជា(លេខាធិការដ្ឋាន គ.ជ.អ.ប.) ដើម្បីបំពេញលក្ខខណ្ឌនានាក្នុងគោលបំណងបិទបញ្ចប់លក្ខខណ្ឌនានា(Accredited Conditions) ដោយស្ថាប័នដែលមានសិទ្ធិទទួលហិរញ្ញប្បទានដោយផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង (GCF) | ២០២១-២០២៥ | មូលនិធិអាកាសធាតុបៃតង (GCF) | ៥១៧.000 ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៨ | គម្រោងពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA) ដើម្បីបង្កើនការចូលរួម និងការទទួលយោបល់ត្រឡប់របស់ប្រជាពលរដ្ឋ ការបំពេញការងារនិងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការគាំទ្រការអនុវត្តគោលនយោបាយនៅថ្នាក់ជាតិ។ | ២០២៣-២០២៥ | រាជរដ្ឋាភិបាលជប៉ុនតាមរយៈកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅព្រះរាជាណាចក្រកម្ពុជា (UNDP) | ៨៩៧.៧៥២ ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. |

## ១៦. ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្ដួចផ្ដើមថ្មីៗ

- គម្រោងសាកល្បងដែលពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងភាពជាដៃគូជាមួយវិស័យឯកជនត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង និងកំពុងបន្តសិក្សា រៀបចំជាគម្រោងសម្រាប់ការអនុវត្តសាកល្បងនៅថ្នាក់ក្រុង ស្រុកដទៃទៀត។

## ១៧. ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២

- កំពុងជ្រើសរើសទីប្រឹក្សាសម្រាប់ធ្វើការវាយតម្លៃកម្មវិធីជាតិដំណាក់កាលទី១ (២០១០-២០២០) និងប្រើប្រាស់លទ្ធផលពីការវាយតម្លៃនេះជាទិន្នន័យដើមគ្រាសម្រាប់ការវាយតម្លៃកម្មវិធីជាតិដំណាក់កាលទី២(២០២១-២០៣០)
- កំពុងរៀបចំលក្ខខណ្ឌការងារសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការធ្វើអង្កេតអភិបាលកិច្ចនៅទូទាំងរាជធានី ខេត្តក្នុងឆមាសទី១ ឆ្នាំ២០២៤
- របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមស្ដីពីការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ របស់ គ.ជ.អ.ប ត្រូវបានរៀបចំ និងគ្រោងដាក់ក្នុងកិច្ចប្រជុំ គ.ជ.អ.ប. នាអំឡុងដើមខែមករា ឆ្នាំ២០២៤ ដើម្បីត្រួតពិនិត្យ វាយតម្លៃ និងអនុម័ត។

## ១៧. ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

- កិច្ចប្រជុំរវាងប្រធានសមាគមក្រុមប្រឹក្សារាជធានី ខេត្តទាំង២៥ ជាមួយថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិ ស្តីពីការពិគ្រោះយោបល់លើការបំពេញមុខងាររបស់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានមានចំនួន ០១លើក ដោយមានអ្នកចូលរួមចំនួន ៦៦នាក់ ស្ត្រី៣៤នាក់
- បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិ ស្តីពីការពង្រឹងការអនុវត្តតួនាទីរបស់ថ្នាក់ដឹកនាំសមាគម ក្នុងការរៀបចំរចនាសម្ព័ន្ធអង្គអភិបាលកិច្ច ដោយមានអ្នកចូលរួមចំនួន ០៩នាក់ ក្នុងនោះស្ត្រីចំនួន ០៤នាក់
- បានអភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបណ្តុះបណ្តាលសំខាន់ៗ ចំនួន១៣ វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន ៣៤៦នាក់ ក្នុងនោះស្ត្រីចំនួន១៩៥នាក់ លើប្រធានបទដូចជា៖
    - បេក្ខនារីឈរឈ្មោះបោះឆ្នោតពេញសិទ្ធិនៅស្រុកគោលដៅទាំង៦
    - គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
    - អំពើហឹង្សាយេនឌ័រ យេនឌ័រនិងរដ្ឋបាលមូលដ្ឋាន ការទំនាក់ទំនងនិងសម្របសម្រួលមតិ ការបញ្ជ្រាបសមភាពយេនឌ័រ
    - ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក
    - លក្ខខណ្ឌការងាររបស់មន្ត្រីរដ្ឋបាលក្រុងស្រុក
    - វិធានការផ្លាស់ប្តូរយេនឌ័រ
- វគ្គបណ្តុះបណ្តាលលេខាធិការសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរាជធានី ខេត្ត ដើម្បីពង្រឹងការអនុវត្តតួនាទី និងភារកិច្ច ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រមូលប្រាក់សមាជិកភាពសមាគមប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវចំនួន ០១លើក ដោយមានអ្នកចូលរួមចំនួន ៣៣នាក់ ក្នុងនោះស្ត្រីចំនួន ១៨នាក់
- ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិចំនួន១៣នាក់ ក្នុងនោះស្ត្រីចំនួន ០៤នាក់ បានចុះពង្រឹងចំនួន២៥ លើកនៅតាមសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងគោលបំណងពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធអង្គអភិបាលកិច្ចសមាគម និងការបណ្តុះបណ្តាល ការតម្រង់ទិសលើការគ្រប់គ្រងហិរញ្ញវត្ថុ និងការអនុវត្តសកម្មភាពសមាគម។

## ១៨. ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

- សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានលើកសំណើមកលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីស្នើសុំការគាំទ្រលើការសិក្សាវាយតម្លៃ និងកំណត់អំពីជម្រើសសមស្របនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ លេខាធិការដ្ឋាន គ.ជ.អ.ប. បាននឹងកំពុងរៀបចំឯកសារទស្សនទាន និងផែនការសកម្មភាព និងការកៀរគរការគាំទ្រសម្រាប់ការសិក្សាអំពីជម្រើសទាំងនេះ។

## ២០. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់

- ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ និងឆ្នាំ២០២៤ របស់ គ.ជ.អ.ប. បានបញ្ជូនទៅដៃគូ និងអង្គការសង្គមស៊ីវិល ដើម្បីពិនិត្យ និងផ្ដល់យោបល់
- បានរៀបចំកិច្ចប្រជុំចំនួន០២លើកជាមួយអង្គការ NGO Forum និងអង្គការសហគមន៍ជនជាតិដើមភាគតិចស្ដីពីការផ្ដល់មតិយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់ការពារធនធានធម្មជាតិ ច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផល
- ក្រសួងមហាផ្ទៃបានជួបប្រជុំជាមួយអង្គការតម្លាភាពកម្ពុជា (TI) អំពីផែនការការពិនិត្យឡើងវិញសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣
- ក្រសួងមហាផ្ទៃបានជួបពិភាក្សាពិគ្រោះយោបល់ដំណាក់កាលទី២ជាមួយតំណាងអង្គការសង្គមស៊ីវិល ដោយមានការអញ្ជើញចូលរួមពីតំណាងស្ថានទូត និងដៃគូអភិវឌ្ឍន៍ ដើម្បីបន្តធ្វើការពិនិត្យពិភាក្សាលើសេចក្ដីព្រាងខ្លឹមសារវិសោធនកម្មច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

## ខ. សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី២នេះ រួមមានសកម្មភាពជាអាទិភាពចំនួន១៣ ក្នុងនោះមានសកម្មភាពអាទិភាពចំនួន១១ ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម ៖

### ១. ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក

- ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានចុះទៅសិក្សាវាយតម្លៃលើការអនុវត្តមុខងារអប់រំនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១៧ក្នុងរាជធានី ខេត្តចំនួន៥ គឺខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តកំពត ខេត្តកណ្ដាល និងរាជធានីភ្នំពេញ។ ក្នុងការចុះសិក្សាវាយតម្លៃនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានជួបសម្ភាសន៍ជាមួយថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា លោកគ្រូ អ្នកគ្រូ មេឃុំ ចៅសង្កាត់ តំណាងមាតាបិតាសិស្សថ្នាក់ដឹកនាំខេត្ត មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរមុខងារសាធារណៈ និងរតនាគារ ខេត្ត ដែលមានចំនួនសរុបប្រមាណជាង៧០០នាក់។ ការសិក្សាវាយតម្លៃនេះបានផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖
    - ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
    - ការគ្រប់គ្រងសាលារៀន
    - ការគ្រប់គ្រងបុគ្គលិកអប់រំ
    - ការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារអប់រំ
    - ការប្រើប្រាស់ទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារអប់រំ
    - ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យ
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ទៅលើសេចក្តីព្រាងរបាយការណ៍លម្អិតស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលមានចំនួនសរុបប្រមាណ ១៧០នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ចំនួន៤៦គោលដៅជំហានទី២ ចំនួន៣លើក នៅខេត្តសៀមរាប ខេត្តកំពត និងខេត្តស្វាយរៀង
- បានសហការជាមួយក្រសួងអប់រំយុវជន និងកីឡា ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងសមាគមក្រុមប្រឹក្សាថ្នាក់ក្រោមជាតិរៀបចំកិច្ចប្រជុំណែនាំតម្រង់ទិសស្តីពីការមុខងារវិស័យអប់រំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដោយរៀបចំជា៦តំបន់ដែលមានអ្នកចូលរួមសរុបចំនួន១.១៦៣នាក់ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់រាជធានី ខេត្ត
- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សា និងកំណត់នូវមុខងារជាកាតព្វកិច្ច និងមុខងារជា

ដម្រើសរបស់រដ្ឋបាលក្រុង ស្រុក

- បានប្រជុំពិនិត្យរៀបចំសេចក្ដីព្រាងសេចក្ដីណែនាំអន្តរក្រសួងស្ដីពីការអនុវត្តមុខងារផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស័យពាណិជ្ជកម្ម និងវិស័យសាធារណការនិងដឹកជញ្ជូន
- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួងលើសេចក្ដីព្រាងកម្រងសេវារដ្ឋបាលក្នុងវិស័យបរិស្ថានដែលបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បានរៀបចំវគ្គបណ្ដុះបណ្ដាលសាកល្បងសេចក្ដីព្រាងសៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសៀវភៅណែនាំសម្រាប់យុវជនស្ដីពីការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការ អភិវឌ្ឍន៍ កម្មវិធិវិនិយោគបីឆ្នាំរំកិល និងការរៀបចំនិងអនុម័តថវិកាឃុំ សង្កាត់ នៅខេត្តបាត់ដំបង
- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការគណនាពិន្ទុសូចនាករពានរង្វាន់សេវាសង្គម ដើម្បីត្រៀមចុះធ្វើសុពលភាពពិន្ទុសូចនាករពានរង្វាន់សេវាសង្គម
- បានរៀបចំវគ្គបណ្ដុះបណ្ដាលអំពីសៀវភៅណែនាំ ស្ដីពីការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព
- បានរៀបចំវគ្គបណ្ដុះបណ្ដាលអំពីគោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារអប់រំយុវជន និងកីឡាដល់ក្រុង ស្រុកទាំងអស់នៃខេត្តចំនួន៤រួមមាន ៖ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ និងខេត្តស្វាយរៀង ដែលមានអ្នកចូលរួមសរុបចំនួន១៦៣នាក់។

**២. ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់**

- រដ្ឋបាលឃុំ សង្កាត់ទាំងអស់ទទួលបានការគាំទ្រពីក្រសួង ស្ថាប័នក្នុងការផ្ដល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយ និងការអនុវត្តការងារគណនេយ្យភាពសង្គម និងការផ្ទេរមូលនិធិឃុំ សង្កាត់ និងការគាំទ្រនានា
- រដ្ឋបាលឃុំ សង្កាត់ទាំងអស់ទទួលបានការគាំទ្រពីរដ្ឋបាលខេត្តក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤ -២០២៦) និងការសិក្សាលទ្ធភាពគម្រោង
- បានផ្ទេរធនធានថវិកាពីមូលនិធិឃុំ សង្កាត់ជូនរដ្ឋបាលឃុំ សង្កាត់ប្រចាំត្រីមាសទៅគណនីប្រាក់បញ្ញើរបស់រដ្ឋបាលឃុំ សង្កាត់នៅតាមរតនាគារ រាជធានីខេត្ត ទូទាំងប្រទេសសរុបទាំង០៤ត្រីមាសមានចំនួន១.០៤៦.៥៥២លានរៀល ស្មើនឹង៧៥ %
- ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២៣ មានចំនួន២០៦៧គម្រោង ដែលក្នុងនោះគម្រោងមិនទាន់សិក្សា០១គម្រោង គម្រោងកំពុងដំណើរការសិក្សា០៨គម្រោង គម្រោងបានបញ្ចប់ការសិក្សា២០៥៨គម្រោង ស្មើនឹង៩៩.៥៦%។ គម្រោងឃុំ សង្កាត់ ឆ្នាំ២០២៣ បានដេញថ្លៃរួចចំនួន១៩៥៥គម្រោង ស្មើនឹង៩៥%។ ការអនុវត្តកិច្ចសន្យាគម្រោងឃុំ សង្កាត់ ឆ្នាំ២០២៣ មានចំនួន១៨៨៧កិច្ចសន្យា ក្នុងនោះរួមមានកិច្ចសន្យាមិនទាន់អនុវត្តចំនួន៣៣៧កិច្ចសន្យា ស្មើនឹង១៧.៨៥% អនុវត្តបានតិចជាង៥០%ចំនួន២០០កិច្ចសន្យា ស្មើនឹង១០.៦០% អនុវត្តបាន

លើស៥០%ចំនួន៣២០កិច្ចសន្យា ស្មើនឹង១៦.៩៦% បញ្ចប់ការសាងសង់១០០%ចំនួន១០៣០ កិច្ចសន្យា ស្មើនឹង៥៤.៥៨%។

**៣. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់**

- បានរៀបចំឯកសារទស្សនទានស្តីពីការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ និងបានទទួលការឯកភាពពីប្រធាន គ.ជ.អ.ប. ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣
- បានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សាអំពីជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ ព្រមទាំងបានគ្រោងនូវផែនការសកម្មភាពនានាសម្រាប់ការសិក្សានៅក្នុង និងក្រៅប្រទេសនៅដើមឆ្នាំ២០២៤។

**៤. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ**

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ដឹកនាំ(អភិបាលរងរាជធានី ខេត្ត) និងថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងអំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**៥. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ**

- រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បានរៀបចំវេទិកាសាធារណៈដើម្បីរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារ ការផ្តល់ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបំពេញតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ និងពិនិត្យដោះស្រាយបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**៦. ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ**

- ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី២ (២០១៩-២០២៣) ត្រូវបានពិនិត្យ និងឯកភាពក្នុងការពន្យារពេលរហូតដល់ឆ្នាំ២០២៥ ដោយគណៈកម្មាធិការគ្រប់គ្រងការងារគណនេយ្យភាពសង្គមនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ និងបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣
- ការងារគណនេយ្យភាពសង្គមត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅឃុំ សង្កាត់ចំនួន ១.៥៤៥ ស្មើនឹង៩៤% នៃឃុំ សង្កាត់សរុបទូទាំងប្រទេស ដែលឃុំ សង្កាត់ទាំងនេះស្ថិតក្នុងក្រុង ស្រុក ខណ្ឌគោលដៅចំនួន១៨៩ នៃ២៥រាជធានី ខេត្ត។ ការងារគណនេយ្យសង្គមនេះ ផ្តោតទៅលើសេវាសំខាន់ៗចំនួន៣ គឺ ៖ ការផ្តល់សេវារដ្ឋបាលរបស់ឃុំ សង្កាត់ សេវាអប់រំបឋមសិក្សា និងសេវាសុខាភិបាលនៅមណ្ឌលសុខភាព
- ការងារគណនេយ្យភាពសង្គមផ្តោតលើសេវារដ្ឋបាលតាមរយៈការិយាល័យច្រកចេញចូលតែមួយត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ៣៧ ស្មើនឹង១៨% នៃក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។

## ៧. ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ

- ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្តបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន១.៤២៩ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចមានចំនួន៦៣៨ករណី (បញ្ចប់ការដោះស្រាយចំនួន៥៨៤ករណី ស្មើនឹង៩១% កំពុងដោះស្រាយចំនួន៥៤ករណី) បណ្តឹងក្រៅសមត្ថកិច្ចចំនួន២២៤ករណី និងព័ត៌មានផ្សេងៗចំនួន៥០៧ករណី (ការសរសើរចំនួន១១៧ករណី សំណូមពរចំនួន១៤១ករណី និងការសាកសួរព័ត៌មានចំនួន៣០៩ករណី)




- ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌចំនួន១៩០គោលដៅ បានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋបានចំនួនសរុប ១៣.៦៩០ករណី ដែលក្នុងនោះ បណ្តឹងក្នុងសមត្ថកិច្ចមានចំនួន៣០៣ករណី (បញ្ចប់ការដោះស្រាយ២៧៧ករណី ស្មើនឹង៩១% កំពុងដំណើរការ ២៦ករណី) បណ្តឹងក្រៅសមត្ថកិច្ច១៩៨ករណី ព័ត៌មានផ្សេងៗសរុបចំនួន ១៣.១៨៩ករណី (ការសរសើរមាន៣៧២ករណី សំណូមពរមានចំនួន១.០៦៦ករណី ការសាកសួរព័ត៌មានមានចំនួន១១.៧៥១ករណី)



- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកិច្ចការរដ្ឋបាល និងស៊ើបអង្កេតបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋដល់ប្រធាន និងជំនួយការការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ចំនួន០៣វគ្គនៅខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកោះកុង
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹង (Database) របស់ការិយាល័យប្រជាពលរដ្ឋដល់ប្រធាន និងជំនួយការការិយាល័យប្រជាពលរដ្ឋក្រុង ស្រុកនៃខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ នៅខេត្តបាត់ដំបង
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុកដល់រដ្ឋបាលក្រុង ស្រុកដែលទើបបំបែក និងបង្កើតថ្មីចំនួន០៥គោលដៅ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីបច្ចេកទេសស៊ើបអង្កេតបណ្តឹង និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌនៅខេត្តកំពត

**៨. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ**

- រដ្ឋបាលថ្នាក់រាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ បានរៀបចំកិច្ចប្រជុំបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមពាក់ព័ន្ធការងារគណនេយ្យភាពសង្គម សេវាសង្គម ការប្រែប្រួលអាកាសធាតុដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធ
- អង្គការសង្គមស៊ីវិលចំនួន៣២អង្គការ បានចូលរួមអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការដោយបំពេញតួនាទីក្នុងការផ្សព្វផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងព័ត៌មានថវិកា ព្រមទាំងសម្របសម្រួលក្នុងដាក់ពិន្ទុវាយតម្លៃការបំពេញការងារ និងការផ្តល់សេវាសាធារណៈរបស់អង្គភាពផ្តល់សេវា។

**៩. ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត**

- គិតមកដល់ឆ្នាំ២០២៣នេះ រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពប្រើប្រាស់សេវាអ៊ីនធឺណិតក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**១០. ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលនៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- បានធ្វើបច្ចុប្បន្នភាព បញ្ចូលព័ត៌មានអាកាសធាតុ និងទាញយករបាយការណ៍ក្នុងប្រព័ន្ធPID ដោយមានការគាំទ្រពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៃកម្ពុជា គាំទ្រដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុបៃតងដំណាក់កាលទី៣ (CCCA3) និងបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនេះកំពុងរៀបចំ និងធ្វើតេស្តសាកល្បងចំនួន០៣ខេត្តគឺ ខេត្តកំពត ព្រៃវែង និងខេត្តស្វាយរៀង។

**១១. ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**

- រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានាក្នុងការទំនាក់ទំនងផ្សព្វផ្សាយ និងអនុវត្តភារកិច្ចរបស់ខ្លួនមានដូចជា ប្រព័ន្ធ Facebook, Telegram, Website។ ព័ត៌មានសំខាន់ៗដែលបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋរួមមាន ៖ ព័ត៌មានស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាព /ការិយាល័យប្រកចេញចូលតែមួយ ការងារគណនេយ្យភាពសង្គម កិច្ចលទ្ធកម្មសាធារណៈ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ល។

## គ. សមាសភាគទី៣ ÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមាសភាគទី៣នេះ រួមមានសកម្មភាពជាអាទិភាពចំនួន២០ ក្នុងនោះមានសកម្មភាពអាទិភាពចំនួន១៨ ត្រូវបានអនុវត្តដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ

- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអង្គរដ្ឋបាលត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាលក្ខណៈអន្តរក្រសួងនាឆ្នាំ២០១៧ ដោយសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ក៏ត្រូវលើកយកមកពិនិត្យ និង ពិភាក្សាជាបន្តបន្ទាប់នៅអំឡុងពេលនៃការអនុវត្ត ផអទី៣ នៃកជទី១។ ក្នុងដំណាក់កាលនៃការអនុវត្ត ផអ៥ទី១ នៃកជទី២នេះ សេចក្តីព្រាងព្រះរាជក្រឹត្យនេះ ពុំត្រូវបានលើកយកមកពិនិត្យពិភាក្សាជាបន្តទៀតទេ ដោយស្នើសុំលើកយកសកម្មភាពនេះមកអនុវត្តនៅក្នុងឆ្នាំ២០២៤វិញ។

### ២. ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

- អនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងឯកសារពិពណ៌នាមុខតំណែង (មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ) សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ក្នុងនោះមុខតំណែងសម្រាប់រដ្ឋបាលស្រុកមានចំនួន ៥៤ រដ្ឋបាលក្រុងមានចំនួន ៥២ និងរដ្ឋបាលខណ្ឌមានចំនួន៥៤
- សេចក្តីព្រាងបឋមសេចក្តីណែនាំអំពីការអនុវត្តអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងឯកសារពិពណ៌នាមុខតំណែងកំពុងត្រូវបានរៀបចំ និងពិភាក្សា ហើយគ្រោងនឹងដាក់ចេញអនុវត្តក្នុងដើមឆ្នាំ២០២៤នេះ។

### ៣. ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

- រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានរៀបចំ និងអនុវត្តនូវលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗប្រចាំឆ្នាំតាមគោលការណ៍ និងនីតិវិធីជាធរមានដែលបានណែនាំអនុវត្តដោយក្រសួងមហាផ្ទៃ។ ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បាន និងកំពុងសហការជាមួយនឹងក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យមើលឡើងវិញនូវការរៀបចំលក្ខខណ្ឌការងាររបស់មន្ត្រីបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌស្របទៅតាមឯកសារពិពណ៌នាមុខតំណែង។

### ៤. ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

- រដ្ឋបាលថ្នាក់ក្រោមជាតិបានពង្រឹងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនតាមរយៈការចុះបញ្ជីវត្តមាននៅតាមអង្គភាពនីមួយៗ ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមគ្រប់គ្រងបុគ្គលិកនានារបស់ខ្លួន ដែលបានផ្ទេរទៅឱ្យតាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌបានល្អប្រសើរជាងមុន។

### ៥. ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

- បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិមានក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូបង្រៀន (អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨) ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូពេទ្យ (អនុក្រឹត្យ

លេខ៦១អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣) និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីបំពេញការងារនៅអង្គភាព និងការិយាល័យច្រកចេញចូលតែមួយ (លិខិតរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១)។ ដោយឡែក ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិកប្រភេទផ្សេងទៀត មិនទាន់ត្រូវបានរៀបចំនៅឡើយ ដែលសកម្មភាពនេះ គ្រោងធ្វើនៅក្នុងឆ្នាំ២០២៤។

**៦. ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ**

- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យបុគ្គលិកសម្រាប់ដំឡើងថ្នាក់ ឋានន្តរសក្តិ ការចូលនិវត្តត្រូវបាននិងកំពុងសិក្សារៀបចំ ដោយក្រសួងមុខងារសាធារណៈ។

**៧. ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកចំនួន ១០២.៥៩៦នាក់ ក្នុងនោះ ៖
  - បុគ្គលិករដ្ឋបាលរាជធានី ខេត្តមានចំនួន ២៥.៧៥៣នាក់ ស្ត្រី១៣.២០០នាក់ (បុគ្គលិករដ្ឋបាលចំនួន ៣.២៩៥នាក់ ស្ត្រី១.០៣១នាក់ និងគ្រូពេទ្យមានចំនួន២២.៤៥៨នាក់ ស្ត្រី១២.១៦៩នាក់)
  - បុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន ៧៦.៨៤៣នាក់ (បុគ្គលិករដ្ឋបាលចំនួន១៦.៨៤៣នាក់ និងគ្រូបង្រៀនប្រមាណជាង៦០.០០០នាក់)។
- រដ្ឋបាលរាជធានី ខេត្ត បានរៀបចំផែនការតម្រូវការបុគ្គលិកសម្រាប់ក្របខ័ណ្ឌស្នើសុំថ្មីឆ្នាំ២០២៤ មានចំនួន២.៩៣១នាក់ និងមន្ត្រីកិច្ចសន្យាចំនួន៥.៨៨៧នាក់ ក្នុងនោះ ៖
  - រាជធានីភ្នំពេញ ចំនួន៥០នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៣៣៩២នាក់
  - ខេត្តកំពង់ស្ពឺ ចំនួន៣១នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៧២នាក់
  - ខេត្តកំពង់ចាម ចំនួន១៧២នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន១៣៤នាក់
  - ខេត្តពោធិ៍សាត់ ចំនួន៩៨នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៨២នាក់
  - ខេត្តសៀមរាប ចំនួន២៩៤នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន២០៧នាក់
  - ខេត្តបន្ទាយមានជ័យ ចំនួន៣០នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៧៧នាក់
  - ខេត្តឧត្តរមានជ័យ ចំនួន៣៧នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៥៤នាក់
  - ខេត្តស្វាយរៀង ចំនួន៥៦នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៨៣នាក់
  - ខេត្តក្រចេះ ចំនួន១៤១នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៥៥នាក់
  - ខេត្តកោះកុង ចំនួន៦៩នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៧៣នាក់
  - ខេត្តប៉ៃលិន ចំនួន១១៩នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៦៨នាក់
  - ខេត្តព្រះសីហនុ ចំនួន៥៦នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៥៧នាក់
  - ខេត្តតាកែវ ចំនួន៨៦នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៨០នាក់
  - ខេត្តកំពង់ធំ ចំនួន១១៥នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៣៨នាក់

- ខេត្តកំពង់ឆ្នាំង ចំនួន៤៤១នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន២០១នាក់
- ខេត្តស្ទឹងត្រែង ចំនួន៤៩១នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន២៦៦នាក់
- ខេត្តបាត់ដំបង ចំនួន១០៣នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៣៣៧នាក់
- ខេត្តកណ្ដាល ចំនួន២៥នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៤នាក់
- ខេត្តកំពត ចំនួន១១៩នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៨៦នាក់
- ខេត្តព្រៃវែង ចំនួន១៥នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៩៨នាក់
- ខេត្តព្រះវិហារ ចំនួន១១២នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៧៤នាក់
- ខេត្តរតនគិរី ចំនួន៣៥នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៥១នាក់
- ខេត្តមណ្ឌលគិរី ចំនួន៤៣នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៦០នាក់
- ខេត្តកែប ចំនួន៥៣នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន៥១នាក់
- ខេត្តត្បូងឃ្មុំ ចំនួន១៤០នាក់ និងមន្ត្រីកិច្ចសន្យា ចំនួន១៨៧នាក់

## ៤. ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រស្ដីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលក្រោមការដឹកនាំសម្របសម្រួលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយសហការជាមួយក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ និងមានការគាំទ្រដោយកម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា (ISD) របស់កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់(GIZ)
- មន្ត្រីជាស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត (អភិបាល អភិបាលរង នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន ៥៨៤នាក់ ស្មើនឹង២៧,៥១ % និងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (អភិបាល អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន១.៦៨៦នាក់ ស្មើនឹង ២៣,៥៨ %។

## ទិន្នន័យមន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ឆ្នាំ២០២៣

| ល.រ | មុខតំណែងគ្រប់គ្រង | ឆ្នាំ២០២៣ | | |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ភាគរយស្ត្រី (%) |
| ១ | អភិបាល | 25 | 2 | 8% |
| ២ | អភិបាលរង | 250 | 32 | 12.80% |
| ៣ | នាយករដ្ឋបាល | 25 | 1 | 4% |
| ៤ | នាយករងរដ្ឋបាល | 115 | 21 | 18.26% |
| ៥ | នាយកទីចាត់ការ និងឬថ្នាក់ស្មើ | 208 | 24 | 11.54% |
| ៦ | នាយករងទីចាត់ការ និងឬថ្នាក់ស្មើ | 398 | 113 | 28.39% |
| ៧ | ប្រធានការិយាល័យ | 388 | 103 | 26.55% |
| ៨ | អនុប្រធានការិយាល័យ | 714 | 288 | 40.34% |
| **សរុប** | | **2123** | **584** | **27.51%** |

## ទិន្នន័យមន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២៣

| ល.រ | មុខតំណែងគ្រប់គ្រង | ឆ្នាំ២០២៣ | | |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ភាគរយស្ត្រី (%) |
| ១ | អភិបាល | 208 | 7 | 3.37% |
| ២ | អភិបាលរង | 1,248 | 266 | 21.31% |
| ៣ | នាយករដ្ឋបាល | 178 | 18 | 10.11% |
| ៤ | នាយករងរដ្ឋបាល | 308 | 78 | 25.32% |
| ៥ | ប្រធានការិយាល័យ និងឬថ្នាក់ស្មើ | 2,056 | 420 | 20.43% |
| ៦ | អនុប្រធានការិយាល័យ និងឬថ្នាក់ស្មើ | 3,153 | 897 | 28.45% |
| **សរុប** | | **7,151** | **1,686** | **23.58%** |

**៩. ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលដោយសាលាជាតិរដ្ឋបាលមូលដ្ឋានដោយមានការសហការជាមួយក្រុមហ៊ុន Training Technology Transfer Company ។

**១០.ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានីខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព**

- អង្គភាពអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ទទួលបានការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីការរៀបចំវាយតម្លៃលើតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**១១. ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព**

- រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំ និងអនុវត្តផែនការសកម្មភាពស្តីពីការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួនស្របតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលរាជធានី ខេត្តបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន៧៥វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួនប្រមាណ១.៨០០រូប ដោយផ្តោត លើប្រធានបទសំខាន់ៗមានដូចជា៖
    - ការងារគណនេយ្យភាពសង្គម
    - ការកសាងផែនការ និងការរៀបចំថវិកា
    - អន្តរាគមន៍អភិវឌ្ឍសមត្ថភាព
    - តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
    - តួនាទី ភារកិច្ចស្មៀនដល់រដ្ឋបាលឃុំ សង្កាត់
    - ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ
    - ថវិកាឆ្លើយតបនឹងយេនឌ័រក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់។

**១២. ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន**

- ក្រសួងមហាផ្ទៃបានចាត់តាំង និងរៀបចំបុគ្គលិកបំពេញការងារនៅតាមនាយកដ្ឋានទាំង០៤នៃសាលាជាតិរដ្ឋបាលមូលដ្ឋានដែលមានចំនួន៨២នាក់ ស្ត្រីចំនួន២៩នាក់ និងកំពុងរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីទាំងនោះ ដើម្បីត្រៀមបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពនាឆ្នាំ២០២៤
- សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំទីតាំងសម្រាប់ការសាងសង់សាលាជាតិរដ្ឋបាលដ្ឋានដែលមានអគារចំនួន០២ខ្នង គឺអគារសិក្សាសម្រាប់បង្រៀនដែលមានទំហំ ១២.៨៥៨ម៉ែត្រការ៉េ កម្ពស់២ជាន់ និងអគារអន្តេវាសិកដ្ឋានទំហំ ៣.៧៣៤ម៉ែត្រការ៉េ កម្ពស់១ជាន់។ អគារសិក្សា

មានបន្ទប់សិក្សាតូចៗចំនួន០៩ បន្ទប់សិក្សាធំៗចំនួន០៧ សហសាលសិក្សាចំនួន០១ បន្ទប់កុំព្យូទ័រចំនួន០២ បណ្ណាល័យចំនួន០១ បន្ទប់ប្រជុំចំនួន២ បន្ទប់សម្រាប់គ្រូបង្រៀនចំនួន០១ អាហារដ្ឋានចំនួន០១ កន្លែងក្មេងលេង បន្ទប់ព្យាបាលបឋមចំនួន០១ បន្ទប់សម្ភារៈនិងបន្ទប់ផ្សេងៗទៀត។ ក្រៅពីនេះមានការិយាល័យសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីបំពេញការងារ។ អគារអន្តេវាសិកដ្ឋានមានបន្ទប់សម្រាប់សិក្ខាកាមស្នាក់នៅចំនួន៦៤បន្ទប់ និងបន្ទប់ផ្សេងៗទៀត។ ការសាងសង់អគារសិក្សា និងអន្តេវាសិកដ្ឋាននៃសាលាជាតិរដ្ឋបាលមូលដ្ឋានគ្រោងបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០២៥ខាងមុខ ដែលប្រើប្រាស់ថវិកាសាងសង់ប្រមាណ៦.១៥លានដុល្លារ ដែលទទួលបានថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី ស្ថិតក្រោមក្របខណ្ឌកម្មវិធីកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុ ជំហ៊ានទី២ ( ADB Loan No. 3970-CAM )

- បុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានបានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០៦វគ្គ នៅក្នុងប្រទេសចំនួន០៤វគ្គ និងក្រៅប្រទេសចំនួន០២វគ្គ ដែលមានសិក្ខាកាមសរុបចំនួន៦៩រូប ស្ត្រី៣៣រូប លើប្រធានបទសំខាន់ៗដូចជា ៖
    - ការគ្រប់គ្រងហិរញ្ញនៅរដ្ឋបាលឃុំ សង្កាត់
    - តួនាទីសារព័ត៌មានក្នុងដំណើរការបោះឆ្នោត និងការពង្រឹងតួនាទីសារព័ត៌មានក្នុងបរិបទឌីជីថល
    - ការបញ្ជ្រាបយេនឌ័រក្នុងការិយាល័យប្រជាពលរដ្ឋ
    - យេនឌ័រ និងការប្រែប្រួលអាកាសធាតុ
    - បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសសិង្ហបុរី
    - កម្មវិធីអភិវឌ្ឍសមត្ថភាពនៅសាធារណរដ្ឋកូរ៉េ

## ១៣. កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការ និងចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយស្ថាប័នអភិវឌ្ឍសមត្ថភាពរបស់ក្រសួង ស្ថាប័នចំនួន៣រួមមាន៖
    - សាលាភូមិន្ទរដ្ឋបាល នៃក្រសួងមុខងារសាធារណៈ
    - វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
    - វិទ្យាស្ថានជាតិសង្គមកិច្ច នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា
- សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការ និងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដូចជា ៖ UNDP សម្ព័ន្ធភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ខេត្តកណ្តាល ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី
- សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិមួយចំនួន ដើម្បីផ្តល់ការបណ្តុះបណ្តាលដូចខាងក្រោម៖

- បានសហការជាមួយការិយាល័យគម្រោងផ្នែកអភិបាលកិច្ចរបស់អង្គការសហប្រជាជាតិ (UNPOG) បានរៀបចំឯកសារ និងផ្តល់ការបណ្តុះបណ្តាលអំពីមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដល់មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានសហការជាមួយអង្គការតម្លាភាពកម្ពុជា (TIC) សិក្សាស្រាវជ្រាវ និងរៀបចំឯកសារ (១) គោលនយោបាយសង្ខេបស្តីពីក្របខណ្ឌសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិក្រោយកូវីដ-១៩ (២) ឯកសារស្រាវជ្រាវស្តីពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និង (៣) ករណីសិក្សាស្តីពីការរៀបចំសណ្តាប់ធ្នាប់តាមដងស្ទឹងសៀមរាប។ ទន្ទឹមនេះ ក៏បាននិងកំពុងសហការរៀបចំគម្រោងស្តីពីការលើកកម្ពស់ភាពជាដៃគូនៅថ្នាក់ក្រោមជាតិដើម្បីការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព (Public-Private Partnership Project)។
- បានសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) រៀបចំឯកសារបណ្តុះបណ្តាល និងករណីសិក្សាពាក់ព័ន្ធភាពជាដៃគូ (PPP-Public Private Partnership) និងរៀបចំគម្រោងស្តីពីការរៀបចំអនាគតក្រុង ស្រុកអភិវឌ្ឍន៍ប្រកបដោយចីរភាព
- បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រៀបចំរបាយការណ៍ឯកសារទស្សនទានស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា
- បានសហការជាមួយអង្គការទស្សនពិភពលោក (World Vision) រៀបចំម៉ូឌុលសិក្សា និងឯកសារបណ្តុះបណ្តាលសម្រាប់ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមគោលដៅជាកម្លាំងសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានសហការជាមួយអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីសមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំដល់ក្រុមគោលដៅជាមន្ត្រីរាជការជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានសហការជាមួយអង្គការវ៉តធើអេត (WaterAid) ផ្តល់វគ្គបណ្តុះបណ្តាលក្នុងកម្មវិធីពង្រឹងភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត និងអនាម័យ សម្រាប់ក្រុមគោលដៅជាមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រៅពីកិច្ចសហប្រតិបត្តិការខាងលើ សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងសិក្សាអំពីលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូផ្សេងៗទៀតរួមមាន ៖ អង្គការមូលនិធិអាស៊ីកម្ពុជា (The Asia Foundation) អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) អង្គការអាក់សិនអេតកម្ពុជា (ActionAid) អង្គការសុខភាពអន្តរជាតិ៣៦០ (FHI360) អង្គការឃែរកម្ពុជា (Care Cambodia) និងសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ជាដើម។ល។

## ១៤. ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចំនួន៣៧វគ្គ ដែលមានសិក្ខាកាមសរុបចំនួន១.៥៧០នាក់ ស្ត្រីចំនួន៥៨៤នាក់ ដោយផ្តោតលើប្រធានបទ និងកម្មវិធីសំខាន់ៗមានដូចជា ៖
    - មូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព
    - កម្មវិធីភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីជំនាន់៥
    - កិច្ចការរដ្ឋបាល
    - កម្មវិធីវិក្រឹត្យការមូលដ្ឋានជំនាន់ទី៧
    - អភិបាលកិច្ចល្អ
    - កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
    - កម្មវិធីលេខាធិការរដ្ឋបាលឆ្នាំ២០២៣
    - កម្មវិធីរចនាបែបនវានុវត្តន៍លើកទី២
    - កម្មវិធីបង្កើនសមត្ថភាពយេនឌ័រ និងអភិវឌ្ឍន៍ ជំនាញជាអ្នកដឹកនាំ
    - កម្មវិធីគ្រប់គ្រងកម្រិត១ ឆ្នាំ២០២៣សម្រាប់ ក្រុមគោលដៅជាអភិបាលរងក្រុង ស្រុក ខណ្ឌ
    - ការតម្រង់ទិសដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស។

## ១៥. ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ និងអ្នកជំនាញវិជ្ជាជីវៈដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារៈបណ្តុះបណ្តាល

- ស្ថិតក្រោមក្របខណ្ឌកម្មវិធីកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុជំហ៊ានទី២ (ADB Loan No. 3970-CAM) សាលាជាតិរដ្ឋបាលមូលដ្ឋានបានជ្រើសរើសក្រុមហ៊ុន Training and Technology Transfer Limited (TTT), New Zealand ដើម្បីរៀបចំកម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាល។

## ១៦. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងរៀបចំជាសេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ១៧. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំសេចក្តីព្រាងសៀវភៅគោលចំនួន០៨ ពាក់ព័ន្ធប្រធានបទ (១)ការតាក់តែងអត្ថបទ (២)សេចក្តីផ្តើមនៃការគ្រប់គ្រងនៅកម្ពុជា (៣)រចនាសម្ព័ន្ធ តួនាទី

ការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤)ការគ្រប់គ្រងបុគ្គលិកនៅក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៥)រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ក្រសួងមហាផ្ទៃ (៦)ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (៧)ការសរសេរសំណើគម្រោង និង(៨)បម្រែបម្រួលអាកាសធាតុ។ ជាមួយនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំសៀវភៅស្ដីពីកិច្ចការពិធីការ។

- សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំសៀវភៅណែនាំចំនួន០៧ ពាក់ព័ន្ធប្រធានបទ (១)ការគ្រប់គ្រងមុខងារអប់រំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (២)ការគ្រប់គ្រងមុខងារសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត (៣) ប្រតិបត្តិការសម្រាប់ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន (៤)ការរៀនបណ្ដើរធ្វើការបណ្ដើរ (៥)ការណែនាំសម្រាប់គ្រូបណ្ដុះបណ្ដាល (៦)ការណែនាំសម្រាប់អ្នកគ្រប់គ្រងវគ្គបណ្ដុះបណ្ដាល និង(៧)នីតិវិធី និងរបៀបរបបការងាររបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។

## ១៤. ការលើកកម្ពស់ការបណ្ដុះបណ្ដាលតាមបណ្ដុំវិស័យ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក

- ក្នុងឆ្នាំ២០២៣ កន្លងទៅ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្ដុះបណ្ដាលចំនួន៦៣វគ្គ ដែលសិក្ខាកាមចូលរួមសរុបចំនួន២.៨០៦នាក់ ស្រី៩៤៨នាក់។

## ឃ. សមាសភាគទី៤÷ ទិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី៤នេះ រួមមានសកម្មភាពជាអាទិភាពចំនួន១៣ ក្នុងនោះមានសកម្មភាពអាទិភាព ចំនួន០៩ ត្រូវបានអនុវត្តដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការបន្សុីគ្នារវាងកិច្ចចំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បានរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៣ សរុបចំនួន២.៩៣៧គម្រោង ដែលគម្រោងទាំងនេះជាគម្រោងដែលបានលើកឡើងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

### ២. ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- កម្រងបញ្ជីសំណួរនៃប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ដែលមានសំណួរសរុបចំនួន ១.១៦២ ប្រមូលផ្ដុំលើគ្រប់វិស័យត្រូវបានពិនិត្យ កែសម្រួល និងបំពេញបន្ថែមដោយមានកិច្ចសហការវាង លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងផែនការ
- បានធ្វើបច្ចុប្បន្នភាពបញ្ចូលព័ត៌មានអាកាសធាតុ និងទាញយករបាយការណ៍ក្នុងប្រព័ន្ធ PID និង SPD ដោយមានការគាំទ្រពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគ អាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៃកម្ពុជា គាំទ្រដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាស ធាតុបៃតងដំណាក់កាលទី៣ (CCCA3) និងបានកំពុងធ្វើតេស្តសាកល្បងនៅរដ្ឋបាលខេត្តចំនួន ០៣រួមមាន ៖ ខេត្តកំពត ព្រៃវែង និងខេត្តស្វាយរៀង។
- ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់(CDB) ឆ្នាំ២០២២ត្រូវបានប្រមូល ផលិត និងចែករំលែកដល់ ស្ថាប័នដែលមានតម្រូវការពាក់ព័ន្ធ។

### ៣. ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)

- រដ្ឋបាលរាជធានី ខេត្ត ទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងការត្រួតពិនិត្យ តាមដានការអនុវត្ត ថវិកា និងការរៀបចំរបាយការណ៍
- បានដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថលសាកល្បង FMIS (Portal) ជំនាន់ទី១ នៅរដ្ឋបាលក្រុង ស្រុក ចំនួន១៩០ និងឃុំ សង្កាត់គោលដៅចំនួន១.៦៥២ ព្រមទាំងបានដាក់ឱ្យអនុវត្ត និងបាន បណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់គោលដៅទាំងនេះជាបន្តបន្ទាប់។

### ៤. ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រង ចំណូលសារពើពន្ធដែលមានស្រាប់

- ក្នុងឆ្នាំ២០២៣នេះ ការប្រមូលចំណូលសារពើពន្ធរបស់រាជធានី ខេត្តឆ្នាំ២០២៣មានចំនួន ៥៣០លានដុល្លារ មានការកើនឡើងចំនួន១៤៣លានដុល្លារ ស្មើនឹង ២៦% ធៀបនឹងឆ្នាំ ២០២២។

## ៥. ការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

- ក្នុងឆ្នាំ២០២៣នេះ រដ្ឋបាលខេត្តបានបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤% ស្មើនឹង១៧.៦៦៤ លានរៀល ស្មើ ៤.៤០ លានដុល្លារ (គិតជាមធ្យមក្រុង ស្រុកនីមួយៗទទួលបាន៩៣ លានរៀល ស្មើនឹង ២៣.២៥០ដុល្លារ)។ បន្ថែមលើនេះរដ្ឋបាលរាជធានី ខេត្តបានក៏បែងចែកចំណូលសារពើពន្ធរបស់ខ្លួនទៅឱ្យរដ្ឋបាលឃុំ សង្កាត់នៅក្នុងរដ្ឋបាលខេត្តទាំង២៤ ចំនួន៥,៥% ស្មើនឹង៧១.៦៣០ លានរៀល ស្មើ១៧.៩ លានដុល្លារ (គិតជាមធ្យមឃុំ សង្កាត់នីមួយៗទទួលបាន៤៦ លានរៀល ស្មើនឹង ១១.៥០០ ដុល្លារ)
- ចាប់ពីឆ្នាំ២០២៤តទៅរដ្ឋបាលរាជធានីខេត្ត នឹងបែងចែកចំណូលសារពើពន្ធរបស់ខ្លួន ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងអត្រាថេរចំនួន៤% និងទៅឱ្យរដ្ឋបាលឃុំ សង្កាត់មានការកើនឡើងដល់៦%។

## ៦. ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា

- បានកំពុងសាកល្បងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នៅរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេស ដោយបានបណ្តុះបណ្តាលដល់មន្ត្រីជំនាញមន្ត្រីឃុំ សង្កាត់ចំនួន៧វគ្គពីថ្ងៃទី២០ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ តាមប្រព័ន្ធអនឡាញ (Zoom) ដែលមានសមាសភាពចូលរួមសរុបចំនួន ៣.៣០៤រូប និងគ្រោងដាក់ឱ្យអនុវត្តជាផ្លូវការនៅរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសនាដើមខែមករា ឆ្នាំ២០២៤
- បានពង្រីកការអនុវត្តសាកល្បងប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយខេត្តគោលដៅចំនួន១៣ រួមមាន៖ រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំងនិងអនុវត្តជាផ្លូវការនៅឆ្នាំ២០២៤។

## ៧. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- រដ្ឋបាលរាជធានី ខេត្តទាំង២៥បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានដាក់ឱ្យអនុវត្តតាំងពីខែមករា ឆ្នាំ២០២១
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទូទាំងប្រទេសតាំងពីខែមីនា ឆ្នាំ២០២៣។

## ៨. ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក

- រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ពីឆ្នាំ២០២៤-២០២៨ ដែលមានអត្រា១,៦% ដែលអត្រានេះ មានការកើនឡើង ០,១% ធៀបទៅនឹងអត្រាផ្ទេរនៅក្នុងឆ្នាំ២០២៣ធនធានថវិការបស់រដ្ឋបាលក្រុង ស្រុកសម្រាប់ឆ្នាំ២០២៣នេះ មានចំនួន៦៨០.៨០៣លានរៀល (សមមូល១៧០លានដុល្លារ) មានការកើនឡើងចំនួន៥០.៥៩៦លានរៀល ស្មើនឹង៨% ធៀបទៅនឹងថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២២
- ធនធានថវិការបស់រដ្ឋបាលក្រុង ស្រុកសម្រាប់ឆ្នាំ២០២៤ មានចំនួន២.២៥៥.២៨៤លានរៀល (សមមូល៥៥៥លានដុល្លារ) មានការកើនឡើងចំនួន១.៥៧៤.៤៨១លានរៀល ស្មើនឹងជាង

៣៣០% ធៀបទៅនឹងថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២៣។ ថវិកាកើនឡើងនេះ គឺភាគច្រើនលើសលុបជាថវិកាផ្ទេរក្នុងវិស័យអប់រំ ស្របតាមមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដែលមានចំនួនប្រមាណជាង៤០០លានដុល្លារ។

**៩. ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងសិក្សា និងរៀបចំដាក់ឱ្យអនុវត្តនូវនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក
- លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងរៀបចំការសិក្សាអំពីលទ្ធភាពនៃការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងរៀបចំនូវនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត។

## ខ. សមាសភាគទី៥÷ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

សមាសភាគទី៥នេះ រួមមានសកម្មភាពជាអាទិភាពចំនួន០៩ ហើយត្រូវបានអនុវត្តទាំង០៧ សកម្មភាព ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច

- សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នចំនួន០៨ រួមមាន ៖ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជននិងកីឡា
- សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីអនុវត្តមុខងារការសាងសង់ ការជួសជុល ការថែទាំផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានា និងការងារគ្រប់គ្រងដីចំណីផ្លូវជាតិ ផ្លូវខេត្ត ដែលស្ថិតក្នុងទីប្រជុំជន កំពុងរៀបចំដោយក្រសួងសាធារណការ និងដឹកជញ្ជូន
- លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធបានរៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងសម្របសម្រួលដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តមុខងារសុខាភិបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួងអប់រំ យុវជននិងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ បានចុះផ្សព្វផ្សាយអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ ការគ្រប់គ្រងបុគ្គលិកអប់រំ ការគ្រប់គ្រងថវិកាអប់រំ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ដោយមានអ្នកចូលរួមសរុប១.១៦៣នាក់
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយក្រសួងអប់រំ យុវជននិងកីឡាមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ បានរៀបចំបញ្ចប់នូវសៀវភៅណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារអប់រំ និងបានរៀបចំការបណ្តុះបណ្តាលអំពីសៀវភៅណែនាំនេះ ដល់រដ្ឋបាលក្រុង ស្រុកនៃខេត្តចំនួន០៤រួមមាន ៖ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដែលមានសិក្ខាកាមចូលរួមសរុប ចំនួន១៦៣នាក់។ លេខាធិការដ្ឋាន គ.ជ.អ.ប. គ្រោងនឹងរៀបចំការបណ្តុះបណ្តាលនេះ ទៅដល់ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសនៅដើមឆ្នាំ ២០២៤ខាងមុខនេះ
- បានសហការជាមួយក្រុមការងារធនាគារពិភពលោក និងអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យ និងរៀបចំការគ្រប់គ្រង និងប្រតិបត្តិការទីលានទុកដាក់សំរាមនៅតាមក្រុងមួយចំនួន និងបានសិក្សាវាយតម្លៃលើគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា ក្រោមក្របខណ្ឌហិរញ្ញប្បទានរបស់ធនាគារពិភពលោក។ ជាមួយគ្នានេះ ក្រោមការគាំទ្រពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅកម្ពុជា (ISD/GIZ) បាននិងកំពុង

រៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រសម្រាប់ការកៀរគរធនធានគាំទ្រដល់ការផ្តល់សេវាសំរាម និងសំណល់រឹង។

## ២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស

- សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ កំពុងត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញឱ្យបានសមស្របទៅតាមគោលការណ៍ ច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលបានដាក់ចេញ និងផ្តល់ភាពងាយស្រួល និងច្បាស់លាស់សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- សៀវភៅណែនាំស្តីពីកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យ និងរៀបចំឡើងវិញ ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស
- សៀវភៅណែនាំស្តីពីការរៀបចំរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងផ្សព្វផ្សាយអនុវត្តដោយក្រសួងមហាផ្ទៃក្នុងឆ្នាំ២០២៣។

## ៣. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត

- នៅក្នុងឆ្នាំ២០២៣នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត បានផ្តល់សេវារដ្ឋបាលសរុបចំនួន៦២៥.៧២៩សេវា ស្មើនឹង៩០% ធៀបនឹងចំនួនសេវាសរុបដែលបានផ្តល់ក្នុងឆ្នាំ២០២២។ បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់ក្នុងវិស័យទាំង១៤ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានផ្តល់សេវាបានច្រើនជាងគេគឺចំនួន២០៤.៦៥៨សេវា (ស្មើនឹង៣២,៧១%) បន្ទាប់មកគឺការងាររដ្ឋបាលបានផ្តល់សេវាចំនួន១៥១.៥១៨សេវា (ស្មើនឹង២៤,២១%)។ ចំពោះវិស័យពាណិជ្ជកម្ម បានផ្តល់សេវាតិចជាងគេគឺចំនួន៦សេវា (ស្មើនឹង០,០០១%)។




- នៅក្នុងឆ្នាំ២០២៣នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន៩០.៨៩៦.៩៣០.៥៤៩រៀល (ស្មើនឹង២២.៧២៤.២៣២,៦៣ដុល្លារអាមេរិក) ស្មើនឹង ៨០% ធៀបនឹងចំណូលសរុបឆ្នាំ២០២២។ បើប្រៀបធៀបចំណូលដែលទទួលបានក្នុងចំណោមវិស័យទាំង១៤ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន៦៧.៩៩២.៨៤៤.៦៥៩រៀល (ស្មើនឹង៧៤,៨០%) បន្ទាប់មកវិស័យសាធារណការ និងដឹកជញ្ជូន ទទួលបានចំណូលចំនួន៨.១១៥.៥៧៣.៨៤០រៀល (ស្មើនឹង

៨,៩៣%)។ ចំពោះវិស័យពាណិជ្ជកម្ម ទទួលបានចំណូលតិចជាងគេគឺចំនួន១.២០០.០០០រៀល (ស្មើនឹង០,០០១%)។




## ៩. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់ថវិកាប្រាក់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ
- សេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារផ្តល់សេវាក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស័យពាណិជ្ជកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារអភិវឌ្ឍន៍ក្នុងវិស័យពាណិជ្ជកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- ជាមួយគ្នានេះ ក្រោមការគាំទ្រពី គម្រោងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅកម្ពុជា (ISD/GIZ) បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រសម្រាប់ការកៀរគរធនធានគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយ
- នៅក្នុងឆ្នាំ២០២៣នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ បានផ្តល់សេវារដ្ឋបាលសរុបចំនួន២.៦៦២.៥៩៨សេវា ស្មើនឹង១៧០% ធៀបនឹងសេវាសរុបដែលផ្តល់ក្នុងឆ្នាំ២០២២។ បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់ក្នុងចំណោមវិស័យទាំង១៤ ឃើញថាការងារនីត្យានុកូលកម្មបានផ្តល់សេវាបានច្រើនជាងគេគឺចំនួន១.២៤១.៣១៨សេវា (ស្មើនឹង៤៦,៦២%) បន្ទាប់មក

ការងារអត្រានុកូលដ្ឋានបានចំនួន១.១៩៣.៨៦៦សេវា (ស្មើនឹង៤៤,៨៤%)។ ចំពោះវិស័យដែលបានផ្តល់សេវាតិចជាងគេគឺវិស័យអប់រំទទួលបានចំនួន៧៤៩សេវា (ស្មើនឹង០,០២៨%)។




- នៅក្នុងឆ្នាំ២០២៣នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន១៣.៣១៧.៤២០.០៥៦រៀល (ស្មើនឹង៣.៣២៩.៣៥៥ដុល្លារអាមេរិក) ស្មើនឹង១២០% ធៀបនឹងចំណូលសរុបឆ្នាំ២០២២។ បើប្រៀបធៀបចំណូលដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ វិស័យសុរិយោដីទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន៣.៩៨៦.៥៣១.០១៩រៀល (ស្មើនឹង២៩,៩៣%) បន្ទាប់មកវិស័យសំណង់ទទួលបានចំណូលចំនួន២.៣១៦.៥៩៥.៣៦០រៀល (ស្មើនឹង១៧,៤០%)។ ចំពោះវិស័យដែលបានទទួលចំណូលតិចជាងគេគឺវិស័យឧស្សាហកម្មទទួលបានចំនួន៦៦.១៨៦.០០០រៀល (ស្មើនឹង០,៥០%)។



## ៥. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ

- អង្គភាព/ការិយាល័យច្រកចេញចូលតែមួយបានផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញដែលកំពុងដំណើរការសាកល្បងរួមមាន០៤ វិស័យដូចជាវិស័យវប្បធម៌ វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ និងវិស័យកសិកម្ម។

## ៦. ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសិក្សាវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងពិនិត្យ និងបញ្ជ្រាបគោលនយោបាយនេះទៅក្នុងសៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

## ៧. ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

- រដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោង "លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា (STARD) គម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា (CCCA) គម្រោងគាំទ្រលេខាធិការដ្ឋានគ.ជ.អ.ប. ក្នុងការបំពេញល័ក្ខខ័ណ្ឌស្ថាប័នអនុវត្តគម្រោងនៃ GCF និងគម្រោងនវានុវត្តនៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-WRP)
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសិក្សាវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងពិនិត្យ និងបញ្ជ្រាបគោលនយោបាយនេះក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

# ៣. ស្ថានភាពហិរញ្ញវត្ថុ

ឆ្នាំ២០២៣នេះ ចំណាយសរុបសម្រាប់ ផ.ស.ថ.របស់ គ.ជ.អ.ប. មានចំនួន **៤.៥១៣.១៤៣ លានរៀល** សមមូល **១.១២៨ លានដុល្លារ ស្មើនឹង៨៧%** នៃផែនការថវិកាដែលបានគ្រោងទុកសរុប **៥.៣៣៦.២២៨ លានរៀល** សមមូល **១.៣០៣ លានដុល្លារ**។ ការចំណាយនេះ រួមបញ្ចូលការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណាយរបស់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលបានគាំទ្រដល់ ផ.ស.ថ.ឆ្នាំ២០២៣។ ខាងក្រោមនេះ បង្ហាញអំពីក្រាហ្វិកនានានៃការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័នអនុវត្ត និងដៃគូអភិវឌ្ឍន៍តាមសេចក្តីសម្រេចរួមនិងកិច្ចព្រមព្រៀង និងចំណូលសរុបនិងចំណាយសរុបជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះ ៖

- ចំពោះការអនុវត្តសកម្មភាពនានានៃសេចក្តីសម្រេចរួម និងកិច្ចព្រមព្រៀងរវាង គ.ជ.អ.ប. ជាមួយស្ថាប័នអនុវត្ត បានចំណាយថវិកាសរុបចំនួន **១៣០.៥៤៧ លានរៀល** សមមូល **៣២.៦ លាន**

ដុល្លារ ស្មើនឹង៧៦% ធៀបនឹងថវិកាគ្រោងមានចំនួន ១៧២.៦២២ លានរៀល សមមូល៤៣ លានដុល្លារ ដូចរៀបរាប់សង្ខេបក្នុងតារាង និងក្រាហ្វិកដូចខាងក្រោម។

**តារាងទី៣ ៖ សង្ខេបការអនុវត្តថវិកាឆ្នាំ២០២៣ (គិតជាលានរៀល)**

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកាគ្រោង | | ការចំណាយ | |
|---|---|---|---|---|---|
| | | (លានរៀល) | (លានដុល្លារ) | (លានរៀល) | (លានដុល្លារ) |
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | 8,550 | 2.1 | 8,547 | 2.14 |
| ២ | ក្រសួង ស្ថាប័ននានា | 2,395 | 0.6 | 1,274 | 0.31 |
| ៣ | រដ្ឋបាលថ្នាក់ក្រោមជាតិ | 14,038 | 3.5 | 9,632 | 2.39 |
| ៤ | គម្រោង កម្មវិធីដាច់ដោយឡែកនានា | 147,638 | 36.9 | 111,104 | 27.78 |
| | **សរុប** | **172,622** | **43** | **130,557** | **32.6** |

*** តួលេខចំណាយគិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២៣*




- រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បានចំណាយសរុបចំនួន៤.៣៨២.៥៨៦ លានរៀល សមមូល ១.០៩៦ លានដុល្លារ ស្មើនឹង៨៧% នៃចំណូលសរុបដែលមានចំនួន៥.១៦៣.៦០៥ លានរៀលសមមូល១.២៥៩ លានដុល្លារ ក្នុងនោះ រដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់នីមួយៗបានអនុវត្តចំណាយដូចខាងក្រោម ៖
  - រាជធានី ខេត្ត បានចំណាយសរុបចំនួន២.៦៧៨.៨៥០ លានរៀល សមមូល ៦៧០ លានដុល្លារ ស្មើនឹង៨០% នៃចំណូលសរុបដែលមានចំនួន៣.៤៣៦.២៥០ លានរៀល សមមូល ៨៣៨ លានដុល្លារ

- ក្រុង ស្រុក បានចំណាយសរុបចំនួន ៦៤៧.០០៤ លានរៀល សមមូល ១៦២ លានដុល្លារ ស្មើនឹង៩៧% នៃចំណូលសរុបដែលមានចំនួន៦៨០.៨០៣ លានរៀល សមមូល១៦៦ លានដុល្លារ
- ឃុំ សង្កាត់ បានចំណាយសរុបចំនួន១.០៥៦.៧៣២ លានរៀល សមមូល ២៦៤ លានដុល្លារ ស្មើនឹង១០៣% នៃចំណូលសរុបដែលមានចំនួន១.០៤៧ លានរៀល សមមូល ២៥៥ លានដុល្លារ។

| ល.រ. | ធនធានហិរញ្ញវត្ថុ | ថវិកាគ្រោង | | ការចំណាយ | |
|---|---|---|---|---|---|
| | | (លានរៀល) | (លានដុល្លារ) | (លានរៀល) | (លានដុល្លារ) |
| ១ | រាជធានី ខេត្ត | 3,436,250 | 838 | 2,678,850 | 670 |
| ២ | ក្រុង ស្រុក | 680,803 | 166 | 647,004 | 162 |
| ៣ | ឃុំ សង្កាត់ | 1,046,552 | 255 | 1,056,732 | 264 |
| | **សរុប** | **5,163,605** | **1,259** | **4,382,586** | **1,096** |

*** តួលេខចំណាយគិតត្រឹមខែធ្នូ ឆ្នាំ២០២៣*




## ៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

ក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣នេះ មានបញ្ហាប្រឈមជាគន្លឹះមួយចំនួនរួមមាន៖

- ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ជាពិសេស មុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត (ការគាំទ្រថវិកាតិចតួច ពុំទាន់មានការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាព)
- ក្រសួង ស្ថាប័នមួយចំនួនតូចមានបំណងចង់ដកយកសិទ្ធិអំណាចមួយចំនួនដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មកក្រសួង ស្ថាប័នថ្នាក់ជាតិវិញ (ក្រសួងអប់រំ និងក្រសួងដែនដី...)
- រដ្ឋបាលក្រុង ស្រុក ខណ្ឌពុំទាន់ទទួលបានថវិកាសមស្របសម្រាប់អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរឱ្យ (លើកលែងវិស័យអប់រំ យុវជន និងកីឡា)

- រដ្ឋបាលក្រុង ស្រុក ជាពិសេសរដ្ឋបាលស្រុកនៅតាមតំបន់ជនបទជួបប្រទះនូវបញ្ហាខ្វះបុគ្គលិក ដែលមានសមត្ថភាពជំនាញសមស្របសម្រាប់ការអនុវត្តមុខងារនានាដែលបានផ្ទេរឱ្យ
- ភាពយឺតយ៉ាវនៃការអនុវត្តសកម្មភាពអាទិភាពមួយចំនួន ដូចជា៖ ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីជលផល និងព្រៃឈើ ការរៀបចំប្រព័ន្ធវាយតម្លៃផ្អែកលើសមិទ្ធកម្ម ការរៀបចំអង្គមន្ត្រីរាជការ ការរៀបចំក្រមសីលធម៌មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពន្យារពេល និងផ្អាកអនុវត្តសកម្មភាពមួយចំនួននៃសេចក្តីសម្រេចរួម ដោយសារស្ថាប័នអនុវត្តជាប់រវល់ក្នុងភារកិច្ចចាំបាច់មួយចំនួនក្នុងនាមក្រុមការងាររាជរដ្ឋាភិបាល និងកិច្ចការមួយចំនួនពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៧ និងការរៀបចំរាជរដ្ឋាភិបាលថ្មី
- ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនពុំទទួលបានថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់អនុវត្តសកម្មភាពក្នុងសេចក្តីសម្រេចរួមរបស់ខ្លួន
- ក្រសួង ស្ថាប័នអនុវត្តមួយចំនួន ពុំមានថវិកាសមស្របសម្រាប់អនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខណ្ឌក្រសួង ស្ថាប័នរបស់ខ្លួន ជាពិសេសក្រសួងពាក់ព័ន្ធនឹងការផ្ទេរមុខងារ
- ថវិកាសម្រាប់អនុវត្តមុខងារចំនួន៥៥ដែលបានផ្ទេរទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងវិស័យចំនួន១៩ នៅពុំទាន់បានផ្ទេរទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ (កន្លងមកមានការផ្ទេរថវិកាសម្រាប់តែប្រាក់ខែបុគ្គលិក និងប្រាក់សម្រាប់គាំទ្រផ្នែករដ្ឋបាល)
- សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារមួយចំនួនដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំបានរៀបចំបញ្ចប់ និងពុំទាន់បានបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការកង្វះបុគ្គលិកមានសមត្ថភាព និងជំនាញ និងកង្វះការទទួលខុសត្រូវជាក់លាក់របស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ដែលជាបញ្ហាសំខាន់ត្រូវយកចិត្តទុកដាក់ក្នុងរៀបចំមន្ត្រីឱ្យបានសមស្របតាមជំនាញវិជ្ជាជីវៈ ពង្រឹងសមត្ថភាពជំនាញ រៀបចំឱ្យមានលក្ខខណ្ឌការងារច្បាស់លាស់ និងផ្តល់ការលើកទឹកចិត្ត
- ភាពមានកម្រិតក្នុងគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការបំពេញការងារពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- ***សកម្មភាពជាអាទិភាពដែលមិនបានអនុវត្តមានចំនួន១១ដែលរួមមានដូចខាងក្រោម៖***

  ១.៤.១ ការសិក្សាអំពីជម្រើសជាយុទ្ធសាស្ត្រនានាត្រូវបានបញ្ចប់

  ២.៥.១ ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

  ២.៥.២ ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

  ៣.៤.១ ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ

៣.៨.៣ ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា

៤.១.៣ ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤.២.២ ការធ្វើវិមជ្ឍការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤.៦.២ ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

៤.៧.១ ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង

៥.៣.១ ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន

៥.៤.១ ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

## ៥. សកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២៤

សកម្មភាពជាអាទិភាពតាមសមាសភាគនីមួយៗដែលត្រូវអនុវត្តឆ្នាំ២០២៤ មានដូចខាងក្រោម៖

### សមាសភាគទី១៖ ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់

១. ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់

២. ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព

៣. ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

៤. ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឍការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

៦. ការរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

៧. ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា

៨. ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៩. ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

១០. ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

១១. ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង

១២. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២

១៣. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប.

១៤. ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ

១៥. ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬ អង្គការសង្គមស៊ីវិលនានាដោយបន្សុីជាមួយកជទី២

១៦. ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ

១៧. ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២

១៨. រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួល ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា

១៩. ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

២០. ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

២១. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់

## សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

១. ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ រដ្ឋបាលក្រុង ស្រុក

២. ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់

៣. ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន

៤. ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំ ស្ថិតនៅក្នុងតំបន់ជនបទ

៥. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់

៦. ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានី

៧. ការពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខុសៗគ្នា

៨. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

៩. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ

១០. ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

១១. ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ការរៀបចំកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

១៣. ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ

១៤. ការពង្រឹងយន្តការសម្រាប់ទទួល និងដោះស្រាយបណ្តឹងតវ៉ា និងសំណើសំណូមពររបស់ប្រជាពលរដ្ឋ

១៥. ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ

១៦. ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត

១៧. ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១៨. ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

១៩. ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

១. ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ

២. ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាល ថ្នាក់ក្រោមជាតិ

៣. ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៦. ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ

៧. ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រង ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ

៨. ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ

៩. ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក

១០. ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១១. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១២. លើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១៣. ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១៤. ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព

១៥. ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

១៦. ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព

១៧. ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៨. ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ

១៩. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា

២០. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា

## សមាសភាគទី៤÷ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការរដ្ឋបាលថ្នាក់ក្រោមជាតិ

១. ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២. ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣. ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)

៥. ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៦. ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់

៧. ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

៨. ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា

៩. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១០. ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក

១១. ការពង្រឹងប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា

១៣. ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និង កែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង

១៤. ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

១៥. ការសិក្សា និងរៀបចំក្របខណ្ឌសម្រាប់បង្កើតមូលនិធិភារតភាព និងកញ្ចប់ថវិកាពិសេស

១៦. ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## សមាសភាគទី៥÷ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

១. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច

២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស

៣. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត

៤. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

៥. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ

៦. ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន

៧. ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ

៨. ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

៩. ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

១០. ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

១១. ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

## ៦. សេចក្តីសន្និដ្ឋាន

ជារួម ក្នុងឆ្នាំ២០២៣នេះ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដោយមានការចូលរួមគាំទ្រ និងអនុវត្តយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ កម្មវិធីកំណែទម្រង់នេះសម្រេចបាននូវសមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ ការពង្រឹងការគ្រប់គ្រង និងការចាត់ចែងអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ការពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និងការពង្រឹងការផ្តល់សេវាសាធារណៈ ព្រមទាំងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ។ តាមរយៈកម្មវិធីកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹងទៅជាស្ថាប័នដែលមានភាពរឹងមាំ មានសមត្ថភាព មានសិទ្ធិអំណាច មានមុខងារ និងធនធាន និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងរួមចំណែកសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០។ គិតត្រឹមឆ្នាំ២០២៣នេះ មានមុខងារជិត ៦០ក្នុងវិស័យចំនួន២០ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារផ្តល់សេវារដ្ឋបាលប្រមាណជាង ៨០០ប្រភេទត្រូវបានប្រគល់ និងធ្វើប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋតាមយន្តការច្រកចេញចូលតែមួយ។ ក្នុងឆ្នាំ២០២៣នេះ ការផ្ទេរថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងពី ១.១១៦លានដុល្លារក្នុងឆ្នាំ២០២២ ដល់ចំនួន១.២៩១លានដុល្លារក្នុងឆ្នាំ២០២៣។ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារជាជម្រើសរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិ

បានធ្វើការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងអនុវត្តគម្រោងសេវាសង្គមប្រមាណជាង ២.០០០ គម្រោងក្នុងឆ្នាំ២០២៣ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ដែលជាការរួមចំណែកកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន។

ទន្ទឹមនឹងវឌ្ឍនភាព និងសមិទ្ធផលខាងលើនេះ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់ និងដោះស្រាយជាបន្តបន្ទាប់ក្នុងឆ្នាំ២០២៤នេះ ដើម្បីឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលរំពឹងទុកនានាស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា និងស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០២១-២០៣០)។

ថ្ងៃ សុក្រ ៩ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

## ឧបសម្ព័ន្ធទី១៖ វឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពចំនួន៦៣ ធៀបនឹងចំណុចដៅដែលគ្រោងក្នុងឆ្នាំ២០២៣

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា | ប្រចាំឆ្នាំ | វឌ្ឍនភាពចំណុចដៅប្រចាំឆ្នាំ២០២៣ | | |
|---|---|---|---|---|---|---|---|---|
| | | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
| 1 | ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖<br>យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព | | | | | | | |
| 1.1 | យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន | | | | | | | |
| 1.1.1 | ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់ | 1. ចំនួនកិច្ចប្រជុំ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | 1 | 2 | 1 | កំពុងដំណើរការ | – ក្នុងឆ្នាំ២០២៣នេះ៖ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំចំនួន ០១លើក នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ លើប្រធានបទ អនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពិនិត្យ និងពិភាក្សាលើគោលការណ៍ផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ខណ្ឌ និងមូលនិធិឃុំ សង្កាត់ (២០២៤-២០២៨)។ |
| | | 2. ចំនួនសរុបលិខិតបទដ្ឋាន/ឯកសារដែលបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំ គ.ជ.អ.ប. | ឯកសារ | 3 | 6 | 6 | បានបញ្ចប់ | – កិច្ចប្រជុំ គ.ជ.អ.ប. លើកទី២១ បានអនុម័តលើលិខិតបទដ្ឋានចំនួន០២ ដូចជា៖ (១)សេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (២)ពិនិត្យ និងពិភាក្សាលើគោលការណ៍ផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ខណ្ឌ និងមូលនិធិឃុំ សង្កាត់ (២០២៤-២០២៨)(៣)សេចក្តីរាយការណ៍អំពីវឌ្ឍនភាពនៃការពិនិត្យ និងផ្តល់យោបល់លើមាត្រា និងជំពូកនានាដែលពាក់ព័ន្ធនឹងទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីជលផល និងសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | – អនុក្រឹត្យលេខ១៥២ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣<br>– អនុក្រឹត្យលេខ១៥៣ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣<br>– អនុក្រឹត្យលេខ១៥៤ អនក្រ.បក ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនមូលនិធិរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ពីឆ្នាំ២០២៤-២០២៨ ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ និង(៤) អនុក្រឹត្យលេខ២១៣ អនក្រ.បក ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។ |
| 1.1.2 | ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញការកិច្ចឱ្យមានប្រសិទ្ធភាព | 3. អង្គភាព ឬក្រុមការងារអនុគណៈកម្មាធិការត្រូវបានបង្កើត | អង្គភាព | | 5 | 5 | កំពុងដំណើរការ | – លេខាធិការដ្ឋាន គ.ជ.អ.ប. បានសិក្សា និងរៀបចំអង្គភាព ឬក្រុមការងារអនុគណៈកម្មាធិការដែលនឹងត្រូវបានបង្កើត។ |
| | | 4. ចំនួនកិច្ចប្រជុំអនុគណៈកម្មាធិការ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | | 10 | 5 | កំពុងដំណើរការ | –អនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃលើការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពង្រីកការផ្ទេរមុខងារនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ |
| 1.1.3 | ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 5. រចនាសម្ព័ន្ធនៃអង្គភាពចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល | រចនាសម្ព័ន្ធ | សេចក្តីព្រាង | អនុម័ត | សេចក្តីព្រាង | កំពុងដំណើរការ | –លេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងពិភាក្សាលើសេចក្តីព្រាងបឋម ស្តីពីរចនាសម្ព័ន្ធនៃអង្គភាពចំណុះលេខាធិការដ្ឋានគ.ជ.អ.ប.។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 6. ចំនួនសរុបវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់បុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប. | វគ្គ | 4 | 4 | 4 | បានបញ្ចប់ | – លេខាធិការដ្ឋាន គ.ជ.អ.ប. មានបុគ្គលិកចំនួន ១៥០ នាក់ ក្នុងនោះបុគ្គលិកក្របខ័ណ្ឌមានចំនួន៦៧នាក់ និងទីប្រឹក្សានិងមន្ត្រីកិច្ចសន្យាមានចំនួន ៨៣នាក់<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីលេខាធិការដ្ឋាន ចំនួន០៣ វគ្គ ដែលក្នុងនោះ ០២វគ្គ បណ្តុះបណ្តាលលើប្រធានបទស្តីពីនីតិវិធីប្រតិបត្តិ និងសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប. នៅខែមករា និងខែមេសា ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន ៩៤ នាក់ និងស្ត្រីចំនួន ៣៨នាក់ និង០១វគ្គទៀតលើប្រធានបទស្តីពីការងារសវនកម្ម និងក្រមសីលធម៌ និងការរំលឹកឡើងវិញពីនីតិវិធីកិច្ចប្រតិបត្តិការ របស់ គ.ជ.អ.ប. នៅខែធ្នូ ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន៤១នាក់ និងស្ត្រីចំនួន១៧នាក់<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. បានបញ្ជូនមន្ត្រីទៅសិក្សារយៈពេលខ្លីនៅក្រៅប្រទេសអំពីវិមជ្ឈការហិរញ្ញវត្ថុនៅប្រទេសហូឡង់រយៈពេល១៥ថ្ងៃ ព្រមទាំងបានធ្វើទស្សនកិច្ចសិក្សានៅបណ្តាប្រទេសមួយចំនួន ដែលក្នុងនោះរួមមាន៖<br>○ ទស្សនកិច្ចសិក្សាទៅកាន់ខេត្តប៊ិញយឿងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមរយៈពេល០៣ថ្ងៃ ដើម្បីសិក្សាស្វែងយល់អំពីការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>○ ទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី ដើម្បីសិក្សាស្វែងយល់អំពីការរៀបចំប្រព័ន្ធគ្រប់ គ្រងថវិកានៅថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍមូលដ្ឋាន<br>○ ទស្សនកិច្ចសិក្សាទៅប្រទេសម៉ុងហ្គោលី ដើម្បីផ្លាស់ប្តូរមេរៀនបទពិសោធន៍ និងការអនុវត្តល្អៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ ដែលទស្សនកិច្ចសិក្សានេះបាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | ចាប់ផ្តើមពីថ្ងៃទី២៨ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៣ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>○ ការចូលរួមទស្សនកិច្ចសិក្សាជាមួយកំណែទម្រង់៣បូក១ ដើម្បីសិក្សាស្វែងយល់អំពីការធ្វើវិមជ្ឈការហិរញ្ញវត្ថុនៅសាធារណរដ្ឋកូរ៉េ<br>○ ការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការអនុវត្តនឹងកំណែទម្រង់វិមជ្ឈការ របស់ព្រះរាជាណាចក្រកម្ពុជា នៅប្រទេសអាល្លឺម៉ង់<br>○ ការចូលរួមពិព័រណ៍ថ្នាក់តំបន់អំពីផែនការជាតិស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក ( NAP Expo for Asia Pacific ) នៅថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ នៅក្នុងទីក្រុង Incheon នៃសាធារណៈរដ្ឋកូរ៉េ ដើម្បីធ្វើការវាយតម្លៃអំពីការផ្តល់ហិរញ្ញប្បទានភាពបន្សាំសម្រាប់ស្ថាប័នជាតិ និងតំបន់ និងធ្វើបទបង្ហាញអំពីការគាំទ្រផែនការពង្រីកសម្រាប់ការអនុវត្តសកម្មភាពទាក់ទងទៅនឹងភាពបន្សាំការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាននៅក្នុងអាស៊ីប៉ាស៊ីហ្វិកជាផ្នែកមួយនៃពិព័រណ៍ NAP Expo ក្នុងនោះរួមមាន មេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្តមូលនិធិ LoCAL។ |
| 1.1.4 | ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 7. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយក្រសួង ស្ថាប័ន | កិច្ចប្រជុំ | 40 | 80 | 80 | បានបញ្ចប់ | – គ.ដ.វ.វ. នៃក្រសួង ស្ថាប័នថ្នាក់ជាតិ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័ន |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ៣ក់ព័ន្ធចំនួន២០ ត្រូវបានរៀបចំ ចុះហត្ថលេខា និងអនុវត្ត។ |
| | | ៨. ចំនួនកិច្ចប្រជុំ គ.ជ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់រាជធានី ខេត្ត | កិច្ចប្រជុំ | 50 | 100 | 100 | បានបញ្ចប់ | – គ.ជ.វ.វ. នៃរដ្ឋបាលរាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិចចំនួន០៤លើកក្នុងឆ្នាំ២០២៣ ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ ត្រូវបានរៀបចំ ចុះហត្ថលេខា និងអនុវត្ត។ |
| | | ៩. ចំនួនកិច្ចប្រជុំ គ.ជ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រុង ស្រុក | កិច្ចប្រជុំ | 388 | 776 | 776 | បានបញ្ចប់ | – គ.ជ.វ.វ. នៃរដ្ឋបាលថ្នាក់ក្រុង ស្រុក បានរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិចចំនួន០៤លើកក្នុងឆ្នាំ២០២៣ ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤។ |
| 1.1.5 | ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា | 10. ចំនួនកិច្ចប្រជុំរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានាដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 5 | បានបញ្ចប់ | – លេខាធិការដ្ឋានកំណែទម្រង់៣បូក១ បានធ្វើទស្សនកិច្ចសិក្សារួមគ្នាក្នុងការស្វែងយល់ និងដកស្រង់បទពិសោធន៍អំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងបុគ្គលិកនៅសាធារណរដ្ឋកូរ៉េ ដែលដឹកនាំរៀបចំដោយអគ្គលេខាធិការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងអំឡុងខែមេសា ឆ្នាំ២០២៣<br>– បានរៀបចំកិច្ចប្រជុំយន្តការកំណែទម្រង់៣បូក១ ប្រចាំត្រីមាសទី១ និងត្រីមាសទី២ ដើម្បីបូកសរុបលទ្ធផលការងារកំណែទម្រង់ទាំង៤ និងបានរៀបចំផែនការសកម្មភាពសម្រាប់០៦ខែបន្ទាប់នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ដែលមានការចូលរួមពីលេខាធិការដ្ឋាននៃកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | 11. ផែនការសកម្មភាពរួមប្រចាំឆ្នាំដែលបានរៀបចំ | ផែនការ | 1 | 1 | 1 | បានបញ្ចប់ | – ផែនការសកម្មភាពរួមប្រចាំឆ្នាំ២០២៣នៃលេខាធិការដ្ឋានកំណែទម្រង់៣បូក១ត្រូវបានរៀបចំ និងអនុវត្ត។ |
| 1.1.6 | ការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយនានា | 12. ការសិក្សាអំពីការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សិក្សា | | 1 | ការសិក្សា | កំពុងដំណើរការ | – លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើការសិក្សាស្រាវជ្រាវ និងបានរៀបចំជាសេចក្តីព្រាងបឋមនូវឯកសារទស្សនទានសម្រាប់ការសិក្សា និងការរៀបចំវេទិការ ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 13. សេចក្តីណែនាំស្តីពីការរៀបចំកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | សេចក្តីណែនាំ | | 1 | | មិនទាន់បានអនុវត្ត | |
| 1.1.7 | ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា | 14. ចំនួនកិច្ចប្រជុំ TWG-SNDD ដែលបានរៀបចំ | កិច្ចប្រជុំ | 1 | 2 | | កំពុងដំណើរការ | – ក្នុងឆ្នាំ២០២៤នេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តគម្រោង និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>– បានសហការ និងការគាំទ្រពីដៃគូនានាក្នុងការពង្រឹងការគាំទ្រ ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យ វាយតម្លៃលើការអនុវត្តមុខងារអប់រំ សុខាភិបាល ការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ការផ្តល់សេវារដ្ឋបាល និងមុខងារផ្សេងទៀតដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– បានបញ្ជូននៅឯកសារសេចក្តីព្រាងផ.ស.ថ. ឆ្នាំ២០២៤ របស់គ.ជ.អ.ប. ជូនដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យ និងផ្តល់យោបល់ និងបានត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការនៅដើមឆ្នាំ២០២៤។ |
| 1.1.8 | ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 15. ចំនួនកិច្ចប្រជុំក្រុមការងារយេនឌ័ររបស់ក្រសួង ស្ថាប័ន ដែលបានរៀបចំ | កិច្ចប្រជុំ | 84 | 84 | 42 | កំពុងដំណើរការ | – បានរៀបចំវគ្គបណ្តុះបណ្តាលស្តីការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និង សមធម៌សង្គម នៅខេត្តកែប ខេត្តបន្ទាយមានជ័យ និងស្វាយរៀង ដល់មន្ត្រី ក្រសួង មន្ទីរកិច្ចការនារី ការិយាល័យសង្គមកិច្ចនិងសុខុមាលភាព |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | សង្គម និងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ មកពីរាជធានីភ្នំពេញ ខេត្តទាំង២៥ ដែលរៀបចំឡើង ដោយក្រសួងកិច្ចការនារី<br>– បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីថវិកាឆ្លើយតបយេនឌ័រ ក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់<br>– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស្វែងរកការគាំទ្រមតិ នៅខេត្ត សៀមរាប និងខេត្តកំពង់ធំ ដល់ ប្រធាន/អនុប្រធាន ការិយាល័យនៃក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីនិងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក មកពីរាជធានី ខេត្តចំនួន២០។<br>– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និង សមធម៌សង្គម នៅខេត្តកែប ខេត្តបន្ទាយមានជ័យ និងស្វាយរៀង ដល់មន្ត្រី ក្រសួង មន្ទីរកិច្ចការនារី ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ មកពីរាជធានីភ្នំពេញ ខេត្តទាំង២៥ ដែលរៀបចំឡើង ដោយក្រសួងកិច្ចការនារី<br>– បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីថវិកាឆ្លើយតបយេនឌ័រ ក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់<br>– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស្វែងរកការគាំទ្រមតិ នៅខេត្ត សៀមរាប និងខេត្តកំពង់ធំ ដល់ ប្រធាន/អនុប្រធាន ការិយាល័យនៃក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីនិងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក មកពីរាជធានី ខេត្តចំនួន២០។ |
| | | 16. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់រាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 300 | 300 | 300 | បានបញ្ចប់ | – គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលរាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បី |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ឆ្នាំ២០២៣នេះ ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ចំនួន៥៨៤នាក់ ស្មើនឹង២៧,៥១ %។ |
| | | 17. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់ក្រុង ស្រុក ខណ្ឌដែលបានរៀបចំ | កិច្ចប្រជុំ | 2,496 | 2,496 | 2,496 | បានបញ្ចប់ | – គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង ស្រុក ខណ្ឌ បានរៀបចំកិច្ចប្រជុំរបស់ខ្លួនជាទៀងទាត់ដើម្បីពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ឆ្នាំ២០២៣នេះ ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានចំនួន១.៦៨៦នាក់ ស្មើនឹង២៣,៥៨ %។ |
| **1.2** | **ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា** | | | | | | | |
| 1.2.1 | ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 18. យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងត្រូវបានពិនិត្យ កែសម្រួល និងអនុម័ត | យុទ្ធសាស្ត្រ | | 1 | ការសិក្សា | កំពុងដំណើរការ | – បាន និងកំពុងសហការជាមួយនឹងមន្ត្រីនៃអង្គការ GIZ ដើម្បីពិនិត្យ និងកែសម្រួលយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយសកម្មភាពនេះគ្រោងនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២៤។ |
| 1.2.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 19. ចំនួនសរុបវេទិកា ឬកម្មវិធីផ្សព្វផ្សាយអំពីចក្ខុវិស័យ គោលដៅ និងសមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំ | វេទិកា | 5 | 10 | 10 | បានបញ្ចប់ | – បានរៀបចំ និងផ្សព្វផ្សាយឯកសារព័ត៌មានអំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃកជទី២ និងអំពីសមិទ្ធផលនានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងកំពុងដំណើរការរៀបចំកញ្ចប់វីដេអូពាក់ព័ន្ធនឹងការងារវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់រួមមាន ៖<br>• ផលិតវីដេអូបទយកការខ្លីស្តីពីការដឹកនាំល្អរបស់មេឃុំក្នុងការផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋាន<br>• ផលិត និងកែសម្រួលវីដេអូបទយកការខ្លីស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំនៅស្រុកឈូក ខេត្តកំពត |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | • ផលិតវីដេអូផ្សព្វផ្សាយបទយកការខ្លីស្ដីពីការផ្ទេរមុខងារក្នុងវិស័យអប់រំនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង<br>• វីដេអូបទយកការខ្លីស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅមណ្ឌលសុខភាពចន្លាស់ដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប<br>• អត្ថបទករណីសិក្សានៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅសាលាបឋមសិក្សាយាយសល់<br>• វីដេអូអនុសាសន៍ **សម្ដេចមហាបវរធិបតី** អំពីការជំរុញការអនុវត្តលើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• វីដេអូអប់រំអំពីការងារគណនេយ្យភាពសង្គម និងវីដេអូប្រសាសន៍ក្នុងកិច្ចប្រជុំផ្សព្វផ្សាយការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនិងការងារគណនេយ្យភាពសង្គមដល់បណ្ដាញសារព័ត៌មានក្នុងស្រុក<br>• ផ្សព្វផ្សាយ និងការសម្ពោធដាក់ឱ្យអនុវត្តគម្រោងគាំទ្រការងារគម្រោងគណនេយ្យភាពសង្គម។ |
| | | 20. ចំនួនសរុបឯកសារព័ត៌មានស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្សព្វផ្សាយ | ឯកសារព័ត៌មាន | 3 | 5 | 5 | បានបញ្ចប់ | – ឯកសារព័ត៌មានសំខាន់ៗចំនួន១៧០ ឯកសារបានដាក់បញ្ចូល និងផ្សព្វផ្សាយក្នុងគេហទំព័រ និងក្នុងបណ្ដាញសង្គមរួមមាន Facebook YouTube និងChanel Telegram NCDDS, Website<br>– បានរៀបចំមាតិកាខ្លីៗ ( Contents ) អំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការងារគណនេយ្យភាពសង្គម ដើម្បីផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 1.2.3 | ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង | 21. ការអង្កេតអំពីលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងត្រូវបានអនុវត្ត | ការអង្កេត | | 1 | ការសិក្សា | កំពុងដំណើរការ | – បាន និងកំពុងប្រមូលធាតុចូលនានាដែលពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ឧបករណ៍ និងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនរួមមាន ៖ រដ្ឋបាលរាជធានីភ្នំពេញ ខេត្តស្វាយរៀង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង និងខេត្តរតនគីរី ដែលទទួលបានការគាំទ្របច្ចេកទេស និងថវិកាពីអង្គការ GIZ។ |
| **1.3** | **កម្មវិធីជាតិចំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | | | | |
| 1.3.1 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលទី១ នៃកជទី២ | 22. ឯកសារផអ៥ទី១នៃ កជទី២បានបោះពុម្ព និងផ្សព្វផ្សាយ | ឯកសារ | អនុម័ត | 1 | 1 | បានបញ្ចប់ | – ឯកសារផអ៥ទី១ មានចំនួន៥០០ក្បាល ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ដោយមានការគាំទ្រថវិកាពីគម្រោងលើកកម្ពស់ការផ្តល់សេវាសាធារណៈនៅប្រទេសកម្ពុជារបស់អង្គការ GIZ<br>– គិតមកដល់ឆ្នាំ២០២៣ដែលជាឆ្នាំទី៣នៃផអ៥ទី១ (២០២១-២០២៥) សកម្មភាពជាអាទិភាពដែលបានអនុវត្តមានចំនួន៧៣ ស្មើនឹង៦៥% នៃផអ៥ទី១។ ទន្ទឹមនឹងនោះ សូចនាករដែលសម្រេចបានជាមធ្យមមានចំនួន ៨២% ធៀបនឹងសូចនាករនៃសកម្មភាពជាអាទិភាពដែលគ្រោងអនុវត្តក្នុងឆ្នាំនីមួយៗ។ |
| 1.3.2 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. | 23. ផ.ស.ថ. ឆ្នាំ២០២៣ ត្រូវបានរៀបចំ និងអនុម័ត | ផ.ស.ថ. | 1 | 1 | 1 | បានបញ្ចប់ | – ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៣ របស់ គ.ជ.អ.ប. (ផ.ស.ថ.) ត្រូវបានរៀបចំឡើងដោយមានការដាក់បញ្ចូលនូវផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័នអនុវត្តនីមួយៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដោយមានការពិភាក្សា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា។<br>ផ.ស.ថ. ឆ្នាំ២០២៣ ត្រូវបានរៀបចំ និងអនុម័តនៅថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២៣ ដោយ គ.ជ.អ.ប.។ |
| | | 24. ភាគរយសរុបសកម្មភាពអាទិភាពនៃ ផ.ស.ថ. ឆ្នាំ២០២៣ ដែលសម្រេចបាន | ភាគរយ | 70% | 80% | 40% | បានបញ្ចប់ | – សកម្មភាពជាអាទិភាពចំនួន៦៣ ត្រូវបានអនុវត្តតាមផែនការស្មើនឹង៨៣% នៃសកម្មភាពអាទិភាពចំនួន៧៦ នៃ ផ.ស.ថ នៃឆ្នាំ២០២៣ របស់ គ.ជ.អ.ប. |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | 25. ផ.ស.ថ. ឆ្នាំ២០២៤ ត្រូវបានរៀបចំ | ផ.ស.ថ. | | 1 | សេចក្ដីព្រាង | បានបញ្ចប់ | – សេចក្ដីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ដែលរួមបញ្ចូលលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងសូចនាករនានា ត្រូវបានរៀបចំបញ្ចប់ជាសេចក្ដីព្រាង ដោយមានការពិភាក្សា និងពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា និងគ្រោងដាក់ជូនកិច្ចប្រជុំ គ.ជ.អ.ប. នៅដើមខែមករា ឆ្នាំ២០២៤។ |
| | | 26. ចំនួនសរុបនៃសេចក្ដីសម្រេចរួមដែលបានរៀបចំ និងអនុម័ត | សេចក្ដីសម្រេចរួម | 45 | 45 | 45 | បានបញ្ចប់ | – សេចក្ដីសម្រេចរួមឆ្នាំ២០២៣ រវាង លេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័នចំនួន២០ និងរដ្ឋបាលរាជធានី ខេត្តចំនួន២៥ ត្រូវបានរៀបចំ អនុម័ត និងអនុវត្ត |
| | | 27. ចំនួនគម្រោងដៃគូអភិវឌ្ឍន៍ដែលបានចូលរួមគាំទ្រ | ចំនួនគម្រោង | 5 | 5 | 5 | បានបញ្ចប់ | – គម្រោង និងកម្មវិធីដាច់ដោយឡែកចំនួន ១៣ មានដូចជា ៖ គម្រោង WB/ISAF, GIZ/ISD, UNICEF (វិស័យសេវាសង្គម និងកិច្ចគាំពារកុមារ ), UNCDF/LGCC-WRP, UNDP/CCCA, STARD, STAR, ADB/SNIF, ADB/NASLA, ADB/TSDD, GCF/READINESS, WB/CNP ត្រូវបានអនុវត្តទៅតាមគោលការណ៍ និងនីតិវិធីបានកំណត់។ |
| 1.3.3 | ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ | 28. ចំនួនក្រសួង ស្ថាប័នបានបញ្ចូលសកម្មភាពនៃផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 21 | 21 | 21 | បានបញ្ចប់ | – ក្រសួង ស្ថាប័ន បានរៀបចំនូវផែនការសកម្មភាពដែលពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបានដាក់បញ្ចូលនូវផែនការសកម្មភាពទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ របស់ខ្លួន។ |
| | | 29. ចំនួនរដ្ឋបាលរាជធានី ខេត្តបានបញ្ចូលសកម្មភាពនៃ ផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 25 | 25 | 25 | បានបញ្ចប់ | – រដ្ឋបាលរាជធានី ខេត្ត បានរៀបចំនូវផែនការសកម្មភាពដែលពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបានដាក់បញ្ចូលនូវផែនការសកម្មភាពទាំង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | នេះទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ របស់ខ្លួន។ |
| 1.3.4 | ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្សីជាមួយកជទី២ | 30. ចំនួនដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដែលបានបន្សីគម្រោងរបស់ខ្លួនជាមួយកជទី២ | អង្គការ | 13 | 5 | 5 | បានបញ្ចប់ | – គម្រោង និងកម្មវិធីជាច់ដោយឡែកចំនួន ០៨បានជួយគាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់មួយចំនួនមានដូចជា ៖ គម្រោង WB/ISAF-Supply Side, WB/ISAF-Demand Side, GIZ/ISD, UNCDF/LGCC-WRP, ADB/SNIF, ADB/NASLA, GCF/READINESS និង UNDP/STA។ |
| 1.3.5 | ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ | 31. ការសាកល្បងអំពីគំនិតផ្តួចផ្តើមថ្មីៗដែលពាក់ព័ន្ធនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ | ការសាកល្បង | 1 | 1 | 1 | បានបញ្ចប់ | – វឌ្ឍនភាពដូចក្នុងលទ្ធផល ១.១.១. ខាងលើ<br>– គម្រោងសាកល្បងដែលពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងភាពជាដៃគូជាមួយវិស័យឯកជនត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅឃុំបាសាក់ ស្រុកភ្នំក្រវាញ ខេត្តបាត់ដំបង និងកំពុងបន្តសិក្សា រៀបចំជាគម្រោងសម្រាប់ការអនុវត្តសាកល្បងនៅថ្នាក់ក្រុង ស្រុកដទៃទៀត។ |
| | | 32. ការវាយតម្លៃអំពីការអនុវត្តសាកល្បងអំពីគំនិតផ្តួចផ្តើមថ្មីៗ | ការវាយតម្លៃ | 1 | 1 | | មិនទាន់បានអនុវត្ត | – គ្រោងអនុវត្តនៅដើមឆ្នាំ២០២៤។ |
| 1.3.6 | ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២ | 33. ការអង្កេតអភិបាលកិច្ច | ការអង្កេត | | 1 | ឯកសារទស្សនទាន | កំពុងដំណើរការ | – ឯកសារទស្សនទានស្តីពីការអង្កេតអភិបាលកិច្ច កំពុងដំណើរការដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងសហការជាមួយ STAD/UNDP<br>– កំពុងជ្រើសរើសទីប្រឹក្សាសម្រាប់ធ្វើការវាយតម្លៃកម្មវិធីជាតិដំណាក់កាលទី១ (២០១០-២០២០) និងប្រើប្រាស់លទ្ធផលពីការវាយតម្លៃនេះជាទិន្នន័យដើមគ្រាសម្រាប់ការវាយតម្លៃកម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០) |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | – កំពុងរៀបចំលក្ខខណ្ឌការងារសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការធ្វើអង្កេតអភិបាល កិច្ចនៅទូទាំងរាជធានី ខេត្តក្នុងឆមាសទី១ ឆ្នាំ២០២៤ |
| | | 34. របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ.របស់ គ.ជ.អ.ប. ប្រចាំឆ្នាំ | របាយការណ៍ | 2 | 1 | សេចក្តីព្រាង | កំពុងដំណើរការ | – របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមស្តីពីការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ របស់ គ.ជ.អ.ប.ត្រូវបានរៀបចំ និងគ្រោងដាក់ក្នុងកិច្ចប្រជុំ គ.ជ.អ.ប. នាអំឡុងដើមខែមករា ឆ្នាំ២០២៤ ដើម្បីត្រួតពិនិត្យ វាយតម្លៃ និងអនុម័ត។ |
| **1.4** | **រចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ជាតិសម្រាប់ធានាការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | | | | | | | |
| 1.4.1 | ការសិក្សាអំពីជម្រើសជាយុទ្ធសាស្ត្រនានាត្រូវបានបញ្ចប់ | 35. សិក្សាជម្រើសនានាត្រូវបានកំណត់សម្រាប់ពង្រឹងរចនាសម្ព័ន្ធ និងប្រព័ន្ធនៃស្ថាប័នថ្នាក់ជាតិសម្រាប់គាំទ្រ និងត្រួតពិនិត្យលើរដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | | 1 | | មិនទាន់អនុវត្ត | |
| **1.5** | **ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គម ស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់** | | | | | | | |
| 1.5.1 | ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 36. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 4 | បានបញ្ចប់ | – កិច្ចប្រជុំរវាងប្រធានសមាគមក្រុមប្រឹក្សារាជធានី ខេត្តទាំង២៥ ជាមួយថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិ ស្តីពីការពិគ្រោះយោបល់លើការបំពេញមុខងាររបស់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានមានចំនួន ០១លើក ដោយមានអ្នកចូលរួមចំនួន ៦៦រូប ស្ត្រី៣៤រូប។ |
| | | 37. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋានដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 4 | បានបញ្ចប់ | – បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិស្តីពីការពង្រឹងការអនុវត្តតួនាទីរបស់ថ្នាក់ដឹកនាំសមាគម ក្នុងការរៀបចំរចនាសម្ព័ន្ធអង្គអភិបាលកិច្ច ដោយមានអ្នកចូលរួមចំនួន ០៩រូប ក្នុងនោះស្ត្រីចំនួន ០៤រូប។ |
| | | 38. ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ផែនការ | | 1 | 1 | បានបញ្ចប់ | – បានអភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបណ្តុះបណ្តាលសំខាន់ៗចំនួន១៣វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន ៣៤៦រូប ក្នុងនោះស្ត្រីចំនួន១៩៥រូប លើប្រធានបទ ដូចជា៖ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | • បេក្ខនារីឈរឈ្មោះបោះឆ្នោតពេញសិទ្ធិនៅស្រុកគោលដៅទាំង៦<br>• គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា<br>• អំពើហិង្សា យេនឌ័រ និងរដ្ឋបាលមូលដ្ឋាន ការទំនាក់ទំនងនិងសម្របសម្រួល មតិ<br>• ការបញ្ជ្រាបសមភាពយេនឌ័រ<br>• តួនាទី ភារកិច្ច និងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក<br>• លក្ខខណ្ឌការងាររបស់មន្ត្រីរដ្ឋបាលក្រុងស្រុក<br>• វិធានការណ៍ផ្លាស់ប្តូរយេនឌ័រ |
| | | 39. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់សមាជិកសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត | វគ្គ | 3 | 3 | 3 | បានបញ្ចប់ | – វគ្គបណ្តុះបណ្តាលលេខាធិការសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរាជធានី ខេត្ត ដើម្បីពង្រឹងការអនុវត្តតួនាទី និងភារកិច្ចពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រមូលប្រាក់សមាជិកភាពសមាគមប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវចំនួន ០១លើក ដោយមានអ្នកចូលរួមចំនួន ៣៣នាក់ ក្នុងនោះស្ត្រីចំនួន ១៨នាក់។ |
| | | 40. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន | វគ្គ | 3 | 3 | 3 | បានបញ្ចប់ | – ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិចំនួន១៣នាក់ ក្នុងនោះស្ត្រីចំនួន ០៤នាក់ បានចុះពង្រឹងចំនួន២៥លើកនៅតាមសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងគោលបំណងពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធអង្គអភិបាលកិច្ចសមាគម និងការបណ្តុះបណ្តាល ការតម្រង់ទិសលើការគ្រប់គ្រងហិរញ្ញវត្ថុ និងការអនុវត្តសកម្មភាពសមាគម។ |
| 1.5.2 | ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 41. ការសិក្សាអំពីជម្រើសនានាត្រូវបានអនុវត្ត | ការសិក្សា | | 1 | ការសិក្សា | កំពុងដំណើរការ | – សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានលើកសំណើមកលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីស្នើសុំការគាំទ្រលើការសិក្សាវាយតម្លៃ និងកំណត់អំពីជម្រើសសមស្របនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ លេខាធិការដ្ឋាន គ.ជ.អ.ប. បាននឹង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | កំពុងរៀបចំឯកសារទស្សនទាន និងផែនការសកម្មភាព និងការកៀរគរការគាំទ្រសម្រាប់ការសិក្សាអំពីជម្រើសទាំងនេះ។ |
| 1.5.4 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់ | 42. ចំនួនកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលស្ដីពីដំណើរការរៀបចំគោលនយោបាយ | កិច្ចប្រជុំ | | 2 | 2 | បានបញ្ចប់ | – ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ និងឆ្នាំ២០២៤ របស់ គ.ជ.អ.ប. បានបញ្ជូនទៅដៃគូ និងអង្គការសង្គមស៊ីវិល ដើម្បីពិនិត្យ និងផ្ដល់យោបល់<br>– បានរៀបចំកិច្ចប្រជុំចំនួន០២លើកជាមួយអង្គការ NGO Forum និងអង្គការសហគមន៍ជនជាតិដើមភាគតិចស្ដីពីការផ្ដល់មតិយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់ការពារធនធានធម្មជាតិ ច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផល<br>– ក្រសួងមហាផ្ទៃបានជួបប្រជុំជាមួយអង្គការតម្លាភាពកម្ពុជា (TI) អំពីផែនការការពិនិត្យឡើងវិញសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣<br>– ក្រសួងមហាផ្ទៃបានជួបពិភាក្សាពិគ្រោះយោបល់ដំណាក់កាលទី២ជាមួយតំណាងអង្គការសង្គមស៊ីវិល ដោយមានការអញ្ជើញចូលរួមពីតំណាងស្ថានទូត និងដៃគូអភិវឌ្ឍន៍ ដើម្បីបន្តធ្វើការពិនិត្យពិភាក្សាលើសេចក្ដីព្រាងខ្លឹមសារវិសោធនកម្មច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ |
| 2 | **វិមជ្ឈការ និងវិសហមជ្ឈការ ... ** | | | | | | | |

**2** **យុទ្ធសាស្ត្រ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ៖**

**យុទ្ធសាស្ត្រ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្ដល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ**

**2.1** **យុទ្ធសាស្ត្រ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 2.1.1 | ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក | 43. ភាគរយសរុបនៃក្រុង ស្រុក ខណ្ឌដែលទទួលការគាំទ្រពីក្រសួង ស្ថាប័នក្នុងការអនុវត្តមុខងារថ្មីដែលបានផ្ទេរ | ភាគរយ | | 20% | 10% | កំពុងដំណើរការ | លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន៖<br>– ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានចុះទៅសិក្សាវាយតម្លៃលើការអនុវត្តមុខងារអប់រំនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១៧ក្នុងរាជធានី ខេត្តចំនួន៥ គឺខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តកំពត ខេត្តកណ្ដាល និងរាជធានីភ្នំពេញ។ ក្នុងការចុះសិក្សាវាយតម្លៃនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានជួបសម្ភាសន៍ជាមួយថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា លោកគ្រូ អ្នកគ្រូ មេឃុំ ចៅសង្កាត់ តំណាងមាតាបិតាសិស្ស ថ្នាក់ដឹកនាំខេត្ត មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរមុខងារសាធារណៈ និងរតនាគារ ខេត្ត ដែលមានចំនួនសរុបប្រមាណជាង៧០០នាក់។ ការសិក្សាវាយតម្លៃនេះបានផ្ដោតលើចំណុចសំខាន់ៗដូចខាងក្រោម ៖<br>• ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ<br>• ការគ្រប់គ្រងសាលារៀន<br>• ការគ្រប់គ្រងបុគ្គលិកអប់រំ<br>• ការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារអប់រំ<br>• ការប្រើប្រាស់ទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារអប់រំ<br>• ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យ<br>– បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ទៅលើសេចក្ដីព្រាងរបាយការណ៍លម្អិតស្ដីពីលទ្ធផលនៃការសិក្សាវាយតម្លៃការអនុវត្តមុខងារដែលបានផ្ទេរវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ២០២៣ ដែលមានអ្នកចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលមានចំនួនសរុបប្រមាណ ១៧០ នាក់<br>- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ចំនួន ៤៦គោលដៅជំហានទី២ ចំនួន៣លើក នៅខេត្តសៀមរាប ខេត្តកំពត និងខេត្តស្វាយរៀង<br>- បានសហការជាមួយក្រសួងអប់រំយុវជន និងកីឡា ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងសមាគមក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ រៀបចំកិច្ចប្រជុំណែនាំតម្រង់ទិសស្តីពីការមុខងារវិស័យអប់រំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដោយរៀបចំជា៦តំបន់ ដែលមានអ្នកចូលរួមសរុបចំនួន ១.១៦៣នាក់ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់រាជធានី ខេត្ត<br>- បានរៀបចំវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដល់ក្រុង ស្រុកទាំងអស់នៃខេត្តចំនួន៤រួមមាន ៖ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ និងខេត្តស្វាយរៀង ដែលមានអ្នកចូលរួមសរុបចំនួន១៦៣នាក់។ |
| | | 44. មុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសត្រូវបានកំណត់ច្បាស់លាស់ | លិខិតបទដ្ឋាន | | 1 | | កំពុងដំណើរការ | - លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សា និងកំណត់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលក្រុង ស្រុក។ |
| | | 45. ភាគរយសរុបនៃមុខងារក្រុង ស្រុក ដែលមានសេចក្តីណែនាំបច្ចេកទេសក្នុងការអនុវត្តច្បាស់លាស់ | ភាគរយ | 50% | 70% | 60% | កំពុងដំណើរការ | - បានប្រជុំពិនិត្យរៀបចំសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅរដ្ឋបាលក្រុង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ស្រុក ខណ្ឌ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>– បានប្រជុំពិនិត្យរៀបចំសេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យពាណិជ្ជកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួងលើសេចក្តីព្រាងកម្រងសេវារដ្ឋបាលក្នុងវិស័យបរិស្ថានដែលបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– បានប្រជុំពិនិត្យរៀបចំសេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យសាធារណការ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| | | 46. ការវាយតម្លៃ និងការពង្រីកការផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក | ការវាយតម្លៃ | | អនុវត្ត | 1 | បានបញ្ចប់ | – ក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់ការសិក្សាវាយតម្លៃការអនុវត្តមុខងារដែលបានផ្ទេរវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានចុះសិក្សា និងប្រមូលទិន្នន័យពីក្រុង ស្រុក ខណ្ឌ គោលដៅនីមួយៗដើម្បីបូកសរុបជាសេចក្តីព្រាងរបាយការណ៍បឋម និងបានដាក់ពិនិត្យ ពិភាក្សាក្នុងសិក្ខាសាលាពិគ្រោះយោបល់កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលមានចំនួនសរុបប្រមាណ ១៧០នាក់។ ផ្អែកតាមមតិយោបល់ក្រុមការងារបច្ចេកទេសអន្តរក្រសួង បានបញ្ចប់សេចក្តីព្រាងរបាយការណ៍លម្អិតស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃការអនុវត្តមុខងារដែលបានផ្ទេរវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| | | 47. ការសិក្សាអំពីលទ្ធភាពនៃការផ្ទេរមុខងារសុខាភិបាលទៅឱ្យរដ្ឋបាលក្រុង ស្រុក | ការសិក្សា | | 1 | | មិនទាន់បានអនុវត្ត | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | 48. ភាគរយឃុំ សង្កាត់ដែលទទួលបានការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារ | ភាគរយ | | 5% | 2,5% | បានបញ្ចប់ | – បានរៀបចំវគ្គបណ្តុះបណ្តាលសាកល្បងសេចក្តីព្រាងសៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសៀវភៅណែនាំសម្រាប់យុវជនស្តីពីការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងការរៀបចំនិងអនុម័តថវិកាឃុំ សង្កាត់ នៅខេត្តបាត់ដំបង<br>– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគណនាពិន្ទុសូចនាករពានរង្វាន់សេវាសង្គម ដើម្បីត្រៀមចុះធ្វើសុពលភាពពិន្ទុសូចនាករពានរង្វាន់សេវាសង្គម<br>– បានរៀបចំវគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំ ស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព |
| 2.1.2 | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់ | 49. ភាគរយសរុបនៃឃុំ សង្កាត់ដែលទទួលការគាំទ្រដោយក្រសួង ស្ថាប័នក្នុងការអនុវត្តមុខងារ | ភាគរយ | | 5% | 2,5% | បានបញ្ចប់ | – រដ្ឋបាលឃុំ សង្កាត់ទាំងអស់ទទួលបានការគាំទ្រពីក្រសួង ស្ថាប័នក្នុងការផ្តល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយ និងការអនុវត្តការងារគណនេយ្យភាពសង្គម និងបានផ្ទេរធនធានថវិកាពីមូលនិធិឃុំ សង្កាត់ជូនរដ្ឋបាលឃុំ សង្កាត់ប្រចាំត្រីមាសទៅគណនីប្រាក់បញ្ញើរបស់រដ្ឋបាលឃុំ សង្កាត់ នៅតាមធនាគារ រាជធានីខេត្ត ទូទាំងប្រទេសសរុបទាំង០៤ត្រីមាសមានចំនួន១.០៤៦.៥៥២លានរៀល ស្មើនឹង៧៥ %។ |
| | | 50. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយរាជធានី ខេត្តក្នុងការអនុវត្តមុខងារ | ភាគរយ | | 100% | 100% | បានបញ្ចប់ | – រដ្ឋបាលឃុំសង្កាត់ទាំងអស់ទទួលបានការគាំទ្រពីរដ្ឋបាលខេត្តក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤ -២០២៦) និងការសិក្សាលទ្ធភាពគម្រោង។ |
| | | 51. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយក្រុង ស្រុកក្នុងការអនុវត្តមុខងារ | ភាគរយ | | 100% | 100% | បានបញ្ចប់ | – រដ្ឋបាលក្រុង ស្រុក ទាំងអស់ទទួលបានការគាំទ្រពីរដ្ឋបាលខេត្តក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤ -២០២៦) និងការសិក្សាលទ្ធភាពគម្រោង។ |
| 2.2 | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 2.2.1 | ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ | 52. ការសិក្សាត្រូវបានអនុវត្ត | ការសិក្សា | | 1 | ឯកសារទស្សនទាន | កំពុងដំណើរការ | – បានរៀបចំឯកសារទស្សនទានស្តីពីការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ និងបានទទួលការឯកភាពពីប្រធាន គ.ជ.អ.ប. ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣<br>– បានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សាអំពីជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ ព្រមទាំងបានគ្រោងនូវផែនការសកម្មភាព នានាសម្រាប់ការសិក្សានៅក្នុង និងក្រៅប្រទេសនៅដើមឆ្នាំ២០២៤។ |
| **2.4** | **ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 2.4.3 | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ | 53. លិខិតបទដ្ឋានស្តីពីទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | 1 | សេចក្តីណែនាំ | កំពុងដំណើរការ | – សាលាជាតិរដ្ឋបាលមូលដ្ឋានបានបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ដឹកនាំ(អភិបាលរាជធានី ខេត្ត) និងថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងអំពីការគ្រប់គ្រង រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ |
| 2.4.4 | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | 54. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលរាជធានី ខេត្ត | វេទិកា | | 100 | 50 | កំពុងដំណើរការ | – រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បានរៀបចំវេទិកាសាធារណៈ ដើម្បីរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារការផ្តល់ព័ត៌មានផ្សេងពាក់ព័ន្ធនឹងការបំពេញ តួនាទី ភារកិច្ច និងពិនិត្យដោះស្រាយបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| | | 55. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលក្រុង ស្រុក | វេទិកា | | 776 | 388 | កំពុងដំណើរការ | – រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បានរៀបចំវេទិកាសាធារណៈ ដើម្បីរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារការផ្តល់ព័ត៌មានផ្សេងពាក់ព័ន្ធនឹងការ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | បំពេញ តួនាទី ភារកិច្ច និងពិនិត្យដោះស្រាយបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| **2.5** | **សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | | | | | | | |
| 2.5.1 | ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ | 56. ការសិក្សាអំពីការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សា | ការសិក្សា | | 1 | | មិនទាន់បានអនុវត្ត | |
| 2.5.2 | ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 57. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំលេខាធិការដ្ឋានក្រុមប្រឹក្សាត្រូវបានអនុវត្ត | ការសិក្សា | | 1 | 1 | មិនទាន់បានអនុវត្ត | |
| **2.6** | **ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីទាញយកជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| 2.6.1 | ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ | 58. ការសិក្សាអំពីជម្រើសនានាក្នុងការបង្កើតយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ | ការសិក្សា | | 1 | | មិនទាន់បានអនុវត្ត | |
| | | 59. ភាគរយសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ | ភាគរយ | 83% | 90% | 90% | បានបញ្ចប់ | – ក្រុង ស្រុក ខណ្ឌសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមមានចំនួន១៨៩ ក្នុង២៥រាជធានី ខេត្ត ស្មើនឹង៩១% នៃក្រុង ស្រុក ខណ្ឌសរុបទូទាំងប្រទេសចំនួន២០៨។ |
| | | 60. ភាគរយសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ | ភាគរយ | 85% | 90% | 90% | បានបញ្ចប់ | – ឃុំ សង្កាត់សរុបនៃតំបន់គោលដៅដែលអនុវត្តការងារគណនេយ្យភាពសង្គមមានចំនួន១.៥៤៥ ក្នុង២៥រាជធានី ខេត្ត ស្មើនឹង៩៤% នៃឃុំ សង្កាត់សរុបទូទាំងប្រទេសចំនួន១.៦៥២ ដោយផ្តោតលើសេវាសំខាន់ៗចំនួន៣ គឺ ៖ ការផ្តល់សេវារដ្ឋបាលរបស់ឃុំ សង្កាត់ សេវាបឋមសិក្សា និងសេវាមណ្ឌល សុខភាព។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | 61. ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលបន្ទាប់ (២០២៤-២០៣០) ត្រូវបានពិនិត្យ និងកែសម្រួល | ផែនការ | | 1 | 1 | បានបញ្ចប់ | – ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី២ (២០១៩-២០២៣) ត្រូវបានពិនិត្យ និងឯកភាពដោយគណៈកម្មាធិការគ្រប់គ្រងការងារគណនេយ្យភាពសង្គមនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ និងបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ ដើម្បីពន្យារពេលរហូតដល់ឆ្នាំ២០២៥។ |
| | | 62. ភាគរយសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌលើសេវាតាមការិយាល័យច្រកចេញចូលតែមួយ | ភាគរយ | 2% | 15% | 15% | បានបញ្ចប់ | – ក្រុង ស្រុក ខណ្ឌនៃតំបន់គោលដៅដែលកំពុងអនុវត្តការងារគណនេយ្យភាពសង្គមលើសេវារដ្ឋបាលតាមរយៈការិយាល័យច្រកចេញចូលតែមួយមានចំនួន ៣៧ក្រុង ស្រុក ខណ្ឌ ស្មើនឹង១៨% នៃក្រុង ស្រុក ខណ្ឌ<br>ទូទាំងប្រទេស។ |
| 2.6.2 | ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ | 63. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដែលបានរៀបចំ | វគ្គ | | 1 | | មិនទាន់បានអនុវត្ត | |
| | | 64. ភាគរយបណ្ដឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | បណ្ដឹង | 80% | 80% | 80% | បានបញ្ចប់ | សកម្មភាពនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– ចំនួន១.៤២៩ករណី ក្នុងនោះបណ្ដឹងក្នុងសមត្ថកិច្ចមានចំនួន៦៣៨ករណី (បញ្ចប់ការដោះស្រាយចំនួន៥៨៤ករណី ស្មើនឹង៩១% កំពុងដោះស្រាយចំនួន៥៤ករណី) បណ្ដឹងក្រៅសមត្ថកិច្ចចំនួន២២៤ករណី និងព័ត៌មានផ្សេងៗចំនួន៥០៧ករណី (ការសរសើរចំនួន១១៧ករណី សំណូមពរចំនួន១៤១ករណី និងការសាកសួរព័ត៌មានចំនួន៣០៩ករណី) |
| | | 65. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដែលបានរៀបចំ | វគ្គ | | 1 | 1 | បានបញ្ចប់ | – បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីកិច្ចការរដ្ឋបាល និងស៊ើបអង្កេតបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋដល់ប្រធាន និងជំនួយការការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ចំនួន៣វគ្គរួមមាននៅខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកោះកុង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | – បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹង (Database) របស់ការិយាល័យប្រជាពលរដ្ឋដល់ប្រធាន និងជំនួយការការិយាល័យប្រជាពលរដ្ឋក្រុង ស្រុកនៃខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ នៅខេត្តបាត់ដំបង<br>– បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីការផ្តល់សេវាតាមការិយាល័យច្រកចេញចូលតែមួយ និងការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុកដល់រដ្ឋបាលក្រុង ស្រុកដែលទើបបំបែក និងបង្កើតថ្មីចំនួន០៥គោលដៅ<br>– បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីបច្ចេកទេសស៊ើបអង្កេតបណ្តឹង និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌនៅខេត្តកំពត |
| | | 66. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះ សម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ប្រចាំត្រីមាស (គិតជាមធ្យម) | បណ្តឹង | 80% | 80% | 80% | បានបញ្ចប់ | សកម្មភាពនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌចំនួន១៩០គោលដៅ បានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋបានចំនួនសរុប ១៣.៦៩០ករណី ដែលក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចមានចំនួន៣០៣ករណី (បញ្ចប់ការដោះស្រាយ២៧៧ករណី ស្មើនឹង៩១% កំពុងដំណើរការ ២៦ករណី) បណ្តឹងក្រៅសមត្ថកិច្ច១៩៨ករណី ព័ត៌មានផ្សេងៗសរុបចំនួន ១៣.១៨៩ករណី (ការសរសើរមាន ៣៧២ករណី សំណូមពរមានចំនួន១.០៦៦ករណី ការសាកសួរព័ត៌មានមានចំនួន១១.៧៥១ករណី)។ |
| 2.6.3 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ | 67. ភាគរយរដ្ឋបាលរាជធានី ខេត្ត ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលជាទៀងទាត់ | ភាគរយ | | 50% | 50% | កំពុងដំណើរការ | – រដ្ឋបាលថ្នាក់រាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមពាក់ព័ន្ធការងារគណនេយ្យភាពសង្គម សេវាសង្គម ការប្រែប្រួលអាកាសធាតុដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | – អង្គការសង្គមស៊ីវិលចំនួន៣២អង្គការ បានចូលរួមអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការដោយបំពេញតួនាទីក្នុងការផ្សព្វផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងព័ត៌មានថវិកា ព្រមទាំងសម្របសម្រួលក្នុងដាក់ពិន្ទុវាយតម្លៃការបំពេញការងារ និងការផ្តល់សេវាសាធារណៈរបស់អង្គភាពផ្តល់សេវា។ |
| | | 68. ភាគរយរដ្ឋបាលក្រុង ស្រុក ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលជាទៀងទាត់ | ភាគរយ | | 20% | 20% | កំពុងដំណើរការ | – រដ្ឋបាលថ្នាក់ក្រុង ស្រុក បានរៀបចំកិច្ចប្រជុំបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមពាក់ព័ន្ធការងារគណនេយ្យភាពសង្គម សេវាសង្គម ការប្រែប្រួលអាកាសធាតុដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធ |
| | | 69. បញ្ជីអង្គការសង្គមស៊ីវិលត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជាប្រចាំដោយរាជធានី ខេត្ត | បញ្ជី | | 1 | | កំពុងដំណើរការ | – រាជធានី ខេត្តមួយចំនួនបានរៀបចំកិច្ចប្រជុំ និងធ្វើបច្ចុប្បន្នភាពបញ្ជីអង្គការសង្គមស៊ីវិល |
| | | 70. បញ្ជីអង្គការសង្គមស៊ីវិលត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជាប្រចាំដោយក្រុង ស្រុក ខណ្ឌ | បញ្ជី | | 1 | | កំពុងដំណើរការ | – ក្រុង ស្រុក ខណ្ឌមួយចំនួនបានរៀបចំកិច្ចប្រជុំ និងធ្វើបច្ចុប្បន្នភាពបញ្ជីអង្គការសង្គមស៊ីវិល |
| **2.7** | **ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល** | | | | | | | |
| 2.7.1 | ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត | 71. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលបានតំណភ្ជាប់សេវាអ៊ីនធឺណិត | ភាគរយ | 20% | 40% | 20% | បានបញ្ចប់ | – គិតមកដល់ឆ្នាំ២០២៣នេះ រដ្ឋបាលថ្នាក់ក្រោមជាតិចំនួនមានលទ្ធភាពប្រើប្រាស់សេវាអ៊ីនធឺណិតក្នុងការបំពេញការកិច្ចរបស់ខ្លួន។ |
| 2.7.2 | ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 72. ប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួល | ប្រព័ន្ធ | | 3 | 1 | កំពុងដំណើរការ | – បានធ្វើបច្ចុប្បន្នភាព បញ្ចូលព័ត៌មានអាកាសធាតុ និងទាញយករបាយការណ៍ក្នុងប្រព័ន្ធ pID ដោយមានការគាំទ្រពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោម |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ជាតិនៃកម្ពុជា គាំទ្រដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុបៃតងដំណាក់កាលទី៣ (CCCA3)<br>– បច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនេះកំពុងរៀបចំ និងធ្វើតេស្តសាកល្បងចំនួន០៣ ខេត្ត កំពត ព្រៃវែង និងខេត្តស្វាយរៀង។ |
| | | 73. ការសិក្សាអំពីប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងបុគ្គលិកហិរញ្ញវត្ថុ ទ្រព្យសម្បត្តិត្រូវបានអនុវត្ត | ការសិក្សា | | 1 | | មិនទាន់អនុវត្ត | |
| 2.7.3 | ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 74. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់គេហទំព័រ បណ្តាញសង្គម និងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ ដើម្បីផ្សព្វផ្សាយ និងទទួលព័ត៌មានពាក់ព័ន្ធនានា | ភាគរយ | 20% | 50% | 50% | បានបញ្ចប់ | – រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានាក្នុងការទំនាក់ទំនង ផ្សព្វផ្សាយ និងអនុវត្តភារកិច្ចរបស់ខ្លួនមានដូចជា ប្រព័ន្ធ Telegram, Facebook, Website។ |
| | | 75. ភាគរយរាជធានីខេត្ត បានរៀបចំ និងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ភាគរយ | 70% | 70% | 70% | បានបញ្ចប់ | – រដ្ឋបាលរាជធានី ខេត្តទាំង២៥ បានរៀបចំ និងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចជា ព័ត៌មានស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ។ |
| 3 | **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្ដីភាព និងមនសិការវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងចំណេះវិជ្ជាជីវៈជាប្រចាំ** | | | | | | | |
| 3.1 | **អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.1.1 | ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ | 76. ការសិក្សាអំពីលិខិតបទដ្ឋាននានាស្តីពីអង្គមន្ត្រីរាជការត្រូវបានអនុវត្ត | ការសិក្សា | សេចក្តីព្រាង | 1 | អនុម័ត | កំពុងដំណើរការ | – សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអង្គរដ្ឋបាលត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាលក្ខណៈអន្តរក្រសួងនាឆ្នាំ២០១៧ ដោយសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ក៏ត្រូវលើកយកមកពិនិត្យ និង ពិភាក្សាជាបន្តបន្ទាប់នៅអំឡុងពេលនៃការអនុវត្ត ផអទី៣ នៃកជទី១។ ក្នុងដំណាក់កាលនៃការអនុវត្ត ផអ៥ទី១ នៃកជទី២នេះ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | សេចក្ដីព្រាងព្រះរាជក្រឹត្យនេះ ពុំត្រូវបានលើកយកមកពិនិត្យ ពិភាក្សាជាបន្តទៀតទេ ដោយស្នើសុំលើកយកសកម្មភាពនេះមកអនុវត្តនៅក្នុងឆ្នាំ២០២៤វិញ។ |
| | | 77. ការសិក្សាអំពីការរៀបចំក្របខ័ណ្ឌឋានន្តរស័ក្តិ ថ្នាក់ឱ្យសមស្របនឹងមុខតំណែង និងការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | | 1 | 1 | មិនទាន់បានអនុវត្ត | |
| **3.2** | **ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.2.1 | ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 78. ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងអនុម័ត | ប្រព័ន្ធ | សេចក្ដីព្រាង | អនុម័ត | សេចក្ដីព្រាង | កំពុងដំណើរការ | – សេចក្ដីព្រាងអនុក្រឹត្យ និងសេចក្ដីណែនាំស្ដីពីការវាយតម្លៃផ្អែកលើសមិទ្ធកម្មត្រូវបាន និងកំពុងរៀបចំដោយក្រសួងមុខងារសាធារណៈ ដើម្បីជាមូលដ្ឋានសម្រាប់ការវាយតម្លៃទៅលើការបំពេញការងាររបស់បុគ្គលិកប្រចាំឆ្នាំ។ |
| | | 79. លិខិតបទដ្ឋានស្ដីពីការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | សេចក្ដីព្រាង | អនុម័ត | អនុម័ត | បានបញ្ចប់ | – អនុក្រឹត្យស្ដីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងឯកសារពិពណ៌នាមុខតំណែង (មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ) សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ក្នុងនោះមុខតំណែងសម្រាប់រដ្ឋបាលស្រុកមានចំនួន ៥៤ រដ្ឋបាលក្រុងមានចំនួន ៥២ និងរដ្ឋបាលខណ្ឌមានចំនួន៥៤<br>– សេចក្ដីព្រាងបឋមសេចក្ដីណែនាំអំពីការអនុវត្តអនុក្រឹត្យស្ដីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងឯកសារពិពណ៌នាមុខតំណែងកំពុងត្រូវបានរៀបចំ និងពិភាក្សា ហើយគ្រោងនឹងដាក់ចេញអនុវត្តក្នុងដើមឆ្នាំ២០២៤នេះ។ |
| 3.2.2 | ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 80. លិខិតបទដ្ឋានស្ដីពីលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | អនុម័ត | | កំពុងដំណើរការ | – រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានរៀបចំ និងអនុវត្តនូវលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗប្រចាំឆ្នាំតាមគោលការណ៍ និងនីតិវិធីជាធរមានដែលបានណែនាំអនុវត្តដោយក្រសួងមហាផ្ទៃ។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 3.2.3 | ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 81. ភាគរយរដ្ឋបាលរាជធានី ខេត្តបានពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិក ( គិតជាមធ្យម ) | ភាគរយ | | 70% | 70% | កំពុងដំណើរការ | – រដ្ឋបាលថ្នាក់ក្រោមជាតិបានពង្រឹងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនតាមរយៈការចុះបញ្ជីវត្តមាននៅតាមអង្គភាពនីមួយៗ ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាប់ផ្ដើមគ្រប់គ្រងបុគ្គលិកនានារបស់ខ្លួន ដែលបានផ្ទេរទៅឱ្យតាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌបានល្អប្រសើរជាងមុន។ |
| 3.2.4 | ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 82. លិខិតបទដ្ឋានស្ដីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | អនុម័ត | | កំពុងដំណើរការ | – បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិមានក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូបង្រៀន (អនុក្រឹត្យលេខ១២៦អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨) ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូពេទ្យ(អនុក្រឹត្យលេខ៦១អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣) និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីបំពេញការងារនៅអង្គភាព និងការិយាល័យច្រកចេញចូលតែមួយ (លិខិតរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១)។ ដោយឡែក ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិកប្រភេទផ្សេងទៀត មិនទាន់ត្រូវបានរៀបចំនៅឡើយ ដែលសកម្មភាពនេះ គ្រោងធ្វើនៅក្នុងឆ្នាំ២០២៤។ |
| **3.3** | **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.3.1 | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ | 83. ការសិក្សាអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ការសិក្សា | | 1 | 1 | កំពុងដំណើរការ | – ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យបុគ្គលិកសម្រាប់ដំឡើងថ្នាក់ ឋានន្តរសក្តិ ការចូលនិវត្តត្រូវបាននិងកំពុងសិក្សារៀបចំដោយក្រសួងមុខងារសាធារណៈ។ |
| **3.4** | **តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់** | | | | | | | |
| 3.4.1 | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្ដីណែនាំស្ដីពីការវាយតម្លៃ | 84. សេចក្ដីណែនាំស្ដីពីការវាយតម្លៃតម្រូវការធនធានមនុស្សត្រូវបានរៀបចំ | សេចក្ដីណែនាំ | | សេចក្ដីព្រាង | | មិនទាន់បានអនុវត្ត | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | អំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ | | | | | | | |
| 3.4.3 | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 85. ភាគរយរដ្ឋបាលថ្នាក់រាជធានី ខេត្ត បានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | | 80% | 80% | បានបញ្ចប់ | – បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកចំនួន ១០២.៥៩៦នាក់ ក្នុងនោះ ៖<br>○ បុគ្គលិករដ្ឋបាលរាជធានី ខេត្តមានចំនួន ២៥.៧៥៣នាក់ ស្ត្រី១៣.២០០នាក់ (បុគ្គលិក<br>○ រដ្ឋបាលចំនួន ៣.២៩៥នាក់ ស្ត្រី១.០៣១នាក់ និងគ្រូពេទ្យមានចំនួន២២.៤៥៨នាក់ ស្ត្រី១២.១៦៩នាក់<br>○ បុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន ៧៦.៨៤៣នាក់ (បុគ្គលិករដ្ឋបាលចំនួន ១៦.៨៤៣នាក់ និងគ្រូបង្រៀនប្រមាណជាង៦០.០០០នាក់) |
| **3.5** | **គោលនយោបាយលើកទឹកចិត្តបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.5.4 | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 86. ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួល | ផែនការ | សេចក្តីព្រាង | អនុម័ត | អនុម័ត | កំពុងដំណើរការ | – សេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលក្រោមការដឹកនាំសម្របសម្រួលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយសហការជាមួយក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ និងមានការគាំទ្រដោយកម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា (ISD) របស់កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់(GIZ)។ |
| | | 87. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត | ភាគរយ | 14% | 14,50% | 27,51% | បានបញ្ចប់ | – មន្ត្រីជាស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត (អភិបាល អភិបាលរង នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន៥៨៤នាក់ ស្មើនឹង២៧,៥១ % |
| | | 88. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ | ភាគរយ | 18,72 % | 19,50% | 23,58 % | បានបញ្ចប់ | – មន្ត្រីជាស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (អភិបាល អភិបាលរង នាយករដ្ឋបាល |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | នាយករងរដ្ឋបាល និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន១.៦៨៦នាក់ ស្មើនឹង២៣,៥៨ %។ |
| **3.6** | **ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់** | | | | | | | |
| 3.6.1 | ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 89. លិខិតបទដ្ឋានស្តីពីឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | | 1 | 1 | កំពុងដំណើរការ | – វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ កំពុងដំណើរការពិនិត្យ និងកែសម្រួលដោយសាលាជាតិរដ្ឋបាលមូលដ្ឋានដោយមានការសហការជាមួយក្រុមហ៊ុន Training Technology Transfer Company ។ |
| 3.6.2 | ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | 90. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | វគ្គ | | 1 | 1 | បានបញ្ចប់ | – អង្គភាពអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តទទួលបានការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីការរៀបចំវាយតម្លៃលើតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| 3.6.4 | ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព | 91. ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | 100% | 100% | 100% | បានបញ្ចប់ | – រដ្ឋបាលរាជធានី ខេត្ត បានរៀបចំ និងអនុវត្តផែនការសកម្មភាពស្តីពីការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួនស្របតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 92. ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | 100% | 100% | 100% | បានបញ្ចប់ | – រដ្ឋបាលក្រុង ស្រុក បានរៀបចំ និងអនុវត្តផែនការសកម្មភាពស្តីពីការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួនស្របតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 93. ភាគរយនៃសកម្មភាពអភិវឌ្ឍសមត្ថភាពដែលបានគ្រោងក្នុងផែនការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្ត | ភាគរយ | 70% | 80% | 40% | កំពុងដំណើរការ | – រដ្ឋបាលរាជធានី ខេត្តបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន៧៥វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួនប្រមាណ១.៨០០រូប ដោយផ្តោត លើប្រធានបទសំខាន់ៗមានដូចជា៖<br>○ ការងារគណនេយ្យភាពសង្គម<br>○ ការកសាងផែនការ និងការរៀបចំថវិកា |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | ○ អន្តរាគមន៍អភិវឌ្ឍសមត្ថភាព<br>○ តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>○ តួនាទី ភារកិច្ចស្មៀនដល់រដ្ឋបាលឃុំ សង្កាត់<br>○ ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ<br>○ ថវិកាឆ្លើយតបនឹងយេនឌ័រក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់។ |
| 3.7 | **ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.7.1 | ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន | 94. ភាគរយបុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានដែលបានជ្រើសរើស | ភាគរយ | 80% | 90% | 90% | បានបញ្ចប់ | – ក្រសួងមហាផ្ទៃបានចាត់តាំង និងរៀបចំបុគ្គលិកបំពេញការងារនៅតាមនាយកដ្ឋានទាំង០៤នៃសាលាជាតិរដ្ឋបាលមូលដ្ឋានដែលមានចំនួន៨២នាក់ ស្ត្រីចំនួន២៩នាក់ និងត្រៀមផ្តល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីទាំងនោះ។ |
| | | 95. ភាគរយសាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវបានសាងសង់ | ភាគរយ | | 30% | 30% | កំពុងដំណើរការ | – សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំទីតាំងសម្រាប់ការសាងសង់សាលាជាតិរដ្ឋបាលដ្ឋានដែលមានអគារចំនួន០២ខ្នង គឺអគារសិក្សាសម្រាប់បង្រៀនដែលមានទំហំ ១២.៨៥៨ម៉ែត្រការ៉េ កម្ពស់២ជាន់ និងអគារអន្តេវាសិកដ្ឋានទំហំ ៣.៧៣៤ម៉ែត្រការ៉េ កម្ពស់១ជាន់។ អគារសិក្សាមានបន្ទប់សិក្សាតូចៗចំនួន០៩ បន្ទប់សិក្សាធំៗចំនួន០៧ សហសាលសិក្សាចំនួន០១ បន្ទប់កុំព្យូទ័រចំនួន០២ បណ្ណាល័យចំនួន០១ បន្ទប់ប្រជុំចំនួន២ បន្ទប់សម្រាប់គ្រូបង្រៀនចំនួន០១ អាហារដ្ឋានចំនួន០១ កន្លែងក្មេងលេង បន្ទប់ព្យាបាលបឋមចំនួន០១ បន្ទប់សម្ភារៈនិងបន្ទប់ផ្សេងៗទៀត។ ក្រៅពីនេះមានការិយាល័យសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីបំពេញការងារ។ អគារអន្តេវាសិកដ្ឋានមានបន្ទប់សម្រាប់សិក្ខាកាមស្នាក់នៅចំនួន៦៤បន្ទប់ និងបន្ទប់ផ្សេងៗទៀត។ ការសាងសង់អគារសិក្សា និងអន្តេវាសិកដ្ឋាននៃសាលាជាតិរដ្ឋបាលមូលដ្ឋានគ្រោង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | បញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០២៥ខាងមុខ ដែលប្រើប្រាស់ថវិកាសាងសង់ប្រមាណ៦.១៥លានដុល្លារ ដែលទទួលបានថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី ស្ថិតក្រោមក្របខណ្ឌកម្មវិធីកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុដំហ៊ានទី២ ( ADB Loan No. 3970-CAM )។ |
| | | 96. ចំនួនសរុបវគ្គជាមូលដ្ឋានសម្រាប់បុគ្គលិកសាលាត្រូវបានអនុវត្ត | វគ្គ | 2 | 2 | 6 | បានបញ្ចប់ | – បុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានបានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០៦វគ្គ នៅក្នុងប្រទេសចំនួន០៤វគ្គ និងក្រៅប្រទេសចំនួន០២វគ្គ ដែលមានសិក្ខាកាមសរុបចំនួន៦៩រូប ស្ត្រី៣៣រូប លើប្រធានបទសំខាន់ៗមានដូចជា ៖<br>- ការគ្រប់គ្រងហិរញ្ញនៅរដ្ឋបាលឃុំ សង្កាត់<br>- តួនាទីសារព័ត៌មានក្នុងដំណើរការបោះឆ្នោត និងការពង្រឹងតួនាទីសារព័ត៌មានក្នុងបរិបទឌីជីថល<br>- ការបញ្ជ្រាបយេនឌ័រក្នុងការិយាល័យប្រជាពលរដ្ឋ<br>- យេនឌ័រ និងការប្រែប្រួលអាកាសធាតុ<br>- បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសសិង្ហបុរី<br>- កម្មវិធីអភិវឌ្ឍសមត្ថភាពនៅសាធារណរដ្ឋកូរ៉េ |
| 3.7.2 | កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈនិងឯកជន និងស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល | 97. ចំនួនស្ថាប័នអភិវឌ្ឍសមត្ថភាពដែលបានចុះកិច្ចព្រមព្រៀងជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន | ស្ថាប័ន | | 3 | 1 | បានបញ្ចប់ | – សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការ និងចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយស្ថាប័នអភិវឌ្ឍសមត្ថភាពរបស់ក្រសួង ស្ថាប័នចំនួន៣រួមមាន៖<br>○ សាលាភូមិន្ទរដ្ឋបាល នៃក្រសួងមុខងារសាធារណៈ<br>○ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>○ វិទ្យាស្ថានជាតិសង្គមកិច្ច នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>– សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការ និងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដូចជា ៖ UNDP |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | សម្ថ័ន្ធភាពក្រុមប្រឹក្សារដ្ឋបាល ថ្នាក់ក្រោមជាតិ ខេត្តកណ្តាល ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី<br>– សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិមួយចំនួនដើម្បីផ្តល់ការបណ្តុះបណ្តាលដូចខាងក្រោម៖<br>○ បានសហការជាមួយការិយាល័យគម្រោងផ្នែកអភិបាលកិច្ចរបស់អង្គការសហប្រជាជាតិ (UNPOG) បានរៀបចំឯកសារ និងផ្តល់ការបណ្តុះបណ្តាលអំពីមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដល់មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>○ បានសហការជាមួយអង្គការតម្លាភាពកម្ពុជា (TIC) សិក្សាស្រាវជ្រាវ និងរៀបចំឯកសារ (១) គោលនយោបាយសង្ខេបស្តីពីក្របខណ្ឌសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិក្រោយកូវីដ-១៩ (២) ឯកសារស្រាវជ្រាវស្តីពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និង (៣) ករណីសិក្សាស្តីពីការរៀបចំសណ្តាប់ធ្នាប់តាមដងស្ទឹងសៀមរាប។ ទន្ទឹមនេះ ក៏បាននិងកំពុងសហការរៀបចំគម្រោងស្តីពីការលើកកម្ពស់ភាពជាដៃគូនៅថ្នាក់ក្រោមជាតិដើម្បីការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព (Public-Private Partnership Project)។<br>○ បានសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) រៀបចំឯកសារបណ្តុះបណ្តាល និងករណីសិក្សាពាក់ព័ន្ធភាពជាដៃគូ (PPP-Public Private Partnership) និងរៀបចំគម្រោងស្តីពីការរៀបចំអនាគតក្រុង ស្រុកអភិវឌ្ឍន៍ប្រកបដោយចីរភាព |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ○ បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ) រៀបចំរបាយការណ៍ឯកសារទស្សនទានស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា<br>○ បានសហការជាមួយអង្គការទស្សនពិភពលោក ( World Vision ) រៀបចំម៉ូឌុលសិក្សា និងឯកសារបណ្តុះបណ្តាលសម្រាប់ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមគោលដៅជាកម្លាំងសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>○ បានសហការជាមួយអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ ( GIZ ) ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីសមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំដល់ក្រុមគោលដៅជា មន្ត្រីរាជការជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>○ បានសហការជាមួយអង្គការវ៉តធើអេត ( WaterAid ) ផ្តល់វគ្គបណ្តុះបណ្តាលក្នុងកម្មវិធីពង្រឹងភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត និងអនាម័យ សម្រាប់ក្រុមគោលដៅ ជាមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– ក្រៅពីកិច្ចសហប្រតិបត្តិការខាងលើ សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងសិក្សាអំពីលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូផ្សេងៗទៀតរួមមាន ៖ អង្គការមូលនិធិអាស៊ីកម្ពុជា ( The Asia Foundation ) អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ( NGO Forum ) អង្គការអាក់សិនអេតកម្ពុជា ( ActionAid ) អង្គការសុខភាពអន្តរជាតិ៣៦០ ( FHI360 ) អង្គការឃែរកម្ពុជា ( Care Cambodia ) និងសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ( CPDD ) ជាដើម។ល។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 3.7.3 | ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ | 98. ចំនួនកម្មវិធីសិក្សា និងវគ្គបណ្ដុះបណ្ដាលត្រូវបានរៀបចំ | វគ្គ | 33 | 40 | 40 | បានបញ្ចប់ | – សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្ដុះបណ្ដាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចំនួន៣៧វគ្គ ដែលមានសិក្ខាកាមសរុបចំនួន១.៥៧០នាក់ ស្ត្រីចំនួន ៥៨៤រូប ដោយផ្ដោតលើប្រធានបទ និងកម្មវិធីសំខាន់ៗ មានដូចជា ៖<br>○ មូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍ ប្រកបដោយចីរភាព<br>○ កម្មវិធីភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីជំនាន់៥<br>○ កិច្ចការរដ្ឋបាល<br>○ កម្មវិធីវិក្រឹត្យការមូលដ្ឋានជំនាន់ទី៧<br>○ អភិបាលកិច្ចល្អ<br>○ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>○ កម្មវិធីលេខាធិការរដ្ឋបាលឆ្នាំ២០២៣<br>○ កម្មវិធីរចនាបែបបទវានុវត្តន៍លើកទី២<br>○ កម្មវិធីបង្កើនសមត្ថភាពយេនឌ័រ និងអភិវឌ្ឍន៍ ជំនាញជាអ្នកដឹកនាំ<br>○ កម្មវិធីគ្រប់គ្រងកម្រិត១ ឆ្នាំ២០២៣សម្រាប់ ក្រុមគោលដៅជាអភិបាលរងក្រុង ស្រុក ខណ្ឌ<br>○ ការតម្រង់ទិសដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស។ |
| | | 99. ចំនួនវគ្គបណ្ដុះបណ្ដាលជាកាតព្វកិច្ចត្រូវបានរៀបចំ | វគ្គ | 1 | 2 | 2 | បានបញ្ចប់ | – សាលាជាតិរដ្ឋបាលមូលដ្ឋាន បានរៀបចំវគ្គកាតព្វកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានលទ្ធផលដូចបានរៀបរាប់ក្នុងសូចនាករទី៩៨ខាងលើ |
| **3.8** | **កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.8.1 | ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ | 100. ចំនួនស្ថាប័នអភិវឌ្ឍសមត្ថភាពដែលបានចុះកិច្ចព្រមព្រៀងជាមួយសាលា | ស្ថាប័ន | 2 | 4 | 4 | បានបញ្ចប់ | – ស្ថិតក្រោមក្របខណ្ឌកម្មវិធីកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុជំហានទី២ ( ADB Loan No. |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | និងអ្នកជំនាញវិជ្ជាជីវៈដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារៈបណ្តុះបណ្តាល | ជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីរៀបចំកម្មវិធីសិក្សា និងសម្ភារៈបណ្តុះបណ្តាល | | | | | | 3970-CAM ) សាលាជាតិរដ្ឋបាលមូលដ្ឋានបានជ្រើសរើសក្រុមហ៊ុន Training and Technology Transfer Limited ( TTT ), New Zealand ដើម្បីរៀបចំកម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាល។ |
| 3.8.2 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា | 101. លិខិតបទដ្ឋានស្តីពីការរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | 1 | 1 | កំពុងដំណើរការ | – សាលាជាតិរដ្ឋបាលមូលដ្ឋាន បានរៀបចំជាសេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 102. ភាគរយនៃវគ្គបណ្តុះបណ្តាលដែលបានអនុវត្តដោយមានការរៀបចំកម្មវិធីសិក្សាច្បាស់លាស់ | ភាគរយ | 60% | 80% | 80% | បានបញ្ចប់ | – សាលាជាតិរដ្ឋបាលមូលដ្ឋាន បានរៀបចំបណ្តុះបណ្តាលស្របតាមកម្មវិធីសិក្សាដែលបានកំណត់ក្នុងសេចក្តីណែនាំដែលមានជាធរមាន។ |
| 3.8.3 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា | 103. លិខិតបទដ្ឋានស្តីពីបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | 1 | សេចក្តីព្រាង | កំពុងដំណើរការ | – សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំសេចក្តីព្រាងសៀវភៅគោលចំនួន០៨ ពាក់ព័ន្ធប្រធានបទ (១)ការតាក់តែងអត្ថបទ (២)សេចក្តីផ្តើមនៃការគ្រប់គ្រងនៅកម្ពុជា (៣)រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤)ការគ្រប់គ្រងបុគ្គលិកនៅក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៥)រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ក្រសួងមហាផ្ទៃ (៦)ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (៧)ការសរសេរសំណើគម្រោង និង(៨)បម្រែបម្រួលអាកាសធាតុ។ ជាមួយនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំសៀវភៅស្តីពីកិច្ចការពិធីការ។<br>– សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំសៀវភៅណែនាំចំនួន០៧ ពាក់ព័ន្ធប្រធានបទ (១)ការគ្រប់គ្រងមុខងារអប់រំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (២)ការគ្រប់គ្រងមុខងារសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត (៣) ប្រតិបត្តិការសម្រាប់ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន (៤)ការរៀនបណ្តើរធ្វើការ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | បណ្តើរ (៥)ការណែនាំសម្រាប់គ្រូបណ្តុះបណ្តាល (៦) ការណែនាំសម្រាប់អ្នកគ្រប់គ្រងវគ្គបណ្តុះបណ្តាល និង (៧)នីតិវិធី និងរបៀបរបបការងាររបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ។ |
| | | 104. ភាគរយនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំដោយមានឯកសារសម្ភារៈបណ្តុះបណ្តាលសមស្រប | ភាគរយ | 70% | 80% | 80% | បានបញ្ចប់ | – សាលាជាតិរដ្ឋបាលមូលដ្ឋាន បានរៀបចំ និងគ្រោងឯកសារ សម្ភារៈបណ្តុះបណ្តាលសមស្រប តាមនីតិវិធីនានាដែលមានជាធរមាន។ |
| **3.9** | **វិធីសាស្ត្របណ្តុះបណ្តាលជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 3.9.1 | ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា | 105. លិខិតបទដ្ឋានស្តីពីវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានាត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | បានរៀបចំ | រៀបចំ | មិនទាន់បានអនុវត្ត | |
| 3.9.2 | ការលើកកម្ពស់ការបណ្តុះបណ្តាលតាមបណ្តុំវិស័យ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក | 106. ចំនួនវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញដែលបានរៀបចំសម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | វគ្គ | | 2 | 1 | កំពុងដំណើរការ | – ក្នុងឆ្នាំ២០២៣ កន្លងទៅ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាល ចំនួន៦៣វគ្គ ដែលសិក្ខាកាមចូលរួមសរុបចំនួន២.៨០៦នាក់ ស្រី៩៤៨នាក់។ |
| **4** | **ទិមដ្ឋការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។** | | | | | | | |
| **4.1** | **កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្ស៊ីគ្នា ដោយផ្អែកលើទិតលក្ខណៈ នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ** | | | | | | | |
| 4.1.1 | ការបន្ស៊ីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 107. ភាគរយគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន | ភាគរយ | | | 100% | បានបញ្ចប់ | – រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បានរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៣សរុបចំនួន ២.៩៣៧គម្រោង ដែលគម្រោងទាំងនេះជាគម្រោងដែលបានលើកឡើងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ |
| 4.1.3 | ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 108. ការសិក្សាអំពីការរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការ | ការសិក្សា | | | 1 | មិនទាន់បានអនុវត្ត | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | | | | | |
| | | 109. ការសិក្សាអំពីការរៀបចំយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម | ការសិក្សា | | | 1 | មិនទាន់បានអនុវត្ត | |
| 4.1.4 | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 110. កម្រងបញ្ជីសំណួរប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ត្រូវបានពិនិត្យ និងកែសម្រួល | បញ្ជីសំណួរ | បានសិក្សា | | កែសម្រួល | បានបញ្ចប់ | – កម្រងបញ្ជីសំណួរនៃប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ដែលមានសំណួរសរុបចំនួន ១.១៦២ប្រមូលផ្តុំលើគ្រប់វិស័យត្រូវបានពិនិត្យ កែសម្រួល និងបំពេញបន្ថែមដោយមានកិច្ចសហការវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងផែនការ។ |
| | | 111. ប្រព័ន្ធទិន្នន័យអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួល (PID) | ទិន្នន័យ | បានសិក្សា | | កែសម្រួល | បានបញ្ចប់ | – បានធ្វើបច្ចុប្បន្នភាពបញ្ចូលព័ត៌មានអាកាសធាតុ និងទាញយករបាយការណ៍ក្នុងប្រព័ន្ធ PID ដោយមានការគាំទ្រពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៃកម្ពុជា គាំទ្រដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុបៃតងដំណាក់កាលទី៣ (CCCA3)<br>– បច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនេះកំពុងរៀបចំ និងធ្វើតេស្តសាកល្បងចំនួន០៣ ខេត្តកំពត ព្រៃវែង និងខេត្តស្វាយរៀង។ |
| | | 112. ប្រព័ន្ធទិន្នន័យស្តីពីព័ត៌មានគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួល (SPD) | ទិន្នន័យ | | | កែសម្រួល | បានបញ្ចប់ | – បានធ្វើបច្ចុប្បន្នភាព បញ្ចូលព័ត៌មានអាកាសធាតុ និងទាញយករបាយការណ៍ក្នុងប្រព័ន្ធ SPD ដោយមានការគាំទ្រពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៃកម្ពុជា គាំទ្រដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុបៃតងដំណាក់កាលទី៣ (CCCA3)<br>– បច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនេះកំពុងរៀបចំ និងធ្វើតេស្តសាកល្បងចំនួន០៣ ខេត្ត កំពត ព្រៃវែង និងខេត្តស្វាយរៀង។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | 113. ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ត្រូវបានប្រមូល ផលិត និងចែករំលែក (CDB) | ទិន្នន័យ | | 1 | 1 | បានបញ្ចប់ | – ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់(CDB) ឆ្នាំ២០២២ ត្រូវបានប្រមូល និងចែករំលែកដល់ស្ថាប័នដែលមានតម្រូវការពាក់ព័ន្ធ។ |
| **4.2** | **ការអនុវត្តមុខងារបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្ទេរសិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| 4.2.1 | ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) | 114. ចំនួនរាជធានី ខេត្ត ដែលបានអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | រាជធានី ខេត្ត | 25 | | 25 | បានបញ្ចប់ | – រាជធានី ខេត្ត ទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការរៀបចំរបាយការណ៍។ |
| | | 115. ចំនួនក្រុង ស្រុក ឃុំ សង្កាត់ដែលបានអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ក្រុង ស្រុក ឃុំ សង្កាត់ | 260 | | 500 | កំពុងដំណើរការ | – បានដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថលសាកល្បង FMIS (Portal) ជំនាន់ទី១ នៅរដ្ឋបាលក្រុង ស្រុក ចំនួន១៩០ និងឃុំ សង្កាត់គោលដៅចំនួន១.៦៥២ ព្រមទាំងបានដាក់ឱ្យអនុវត្ត និងបាន<br>– បណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់គោលដៅទាំងនេះជាបន្តបន្ទាប់។ |
| 4.2.2 | ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 116. កម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើនឡើង | ទឹកប្រាក់ | | | | មិនទាន់អនុវត្ត | |
| **4.3** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 4.3.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រង ចំណូលសារពើពន្ធដែលមានស្រាប់ | 117. ចំនួនអ្នកបង់ពន្ធប្រចាំឆ្នាំនៅរដ្ឋបាលរាជធានី ខេត្ត មានការកើនឡើងធៀបនឹងឆ្នាំ២០២២ | អ្នកបង់ពន្ធ | | កើនឡើង | | មិនទាន់បានអនុវត្ត | |
| | | 118. ចំណូលសារពើពន្ធរបស់រាជធានី ខេត្ត មានការកើនឡើងធៀបនឹងឆ្នាំ២០២២ | ចំណូល | 386 លាន ដុល្លារ | កើនឡើង | កើនឡើង | បានបញ្ចប់ | – ក្នុងឆ្នាំ២០២៣នេះ ការប្រមូលចំណូលសារពើពន្ធរបស់រាជធានី ខេត្តឆ្នាំ២០២៣មានចំនួន ៥៣០លានដុល្លារ មានការកើនឡើងចំនួន១៤៣លានដុល្លារ ស្មើនឹង ២៦% ធៀបនឹងឆ្នាំ២០២២ ។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 4.3.2 | ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | 119. ចំនួនភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក | ភាគរយ | 4% | 4% | 4% | បានបញ្ចប់ | – ក្នុងឆ្នាំ២០២៣នេះ រដ្ឋបាលខេត្តបានចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤% ស្មើនឹង១៧.៦៦៤ លានរៀល ស្មើ ៤.៤០ លានដុល្លារ (គិតជាមធ្យមក្រុង ស្រុកនីមួយៗទទួលបាន៩៣ លានរៀល ស្មើនឹង២៣.២៥០ដុល្លារ)។ បន្ថែមលើនេះ<br>– រដ្ឋបាលរាជធានី ខេត្តបានក៏ចែករំលែកចំណូលសារពើពន្ធរបស់ខ្លួនទៅឱ្យរដ្ឋបាលឃុំ សង្កាត់នៅក្នុងរដ្ឋបាលខេត្តទាំង២៤ ចំនួន៥,៥% ស្មើនឹង៧១.៦៣០ លានរៀល ស្មើ១៧.៩ លានដុល្លារ (គិតជាមធ្យមឃុំ សង្កាត់នីមួយៗទទួលបាន៤៦ លានរៀល ស្មើនឹង ១១.៥០០ ដុល្លារ)<br>– ចាប់ពីឆ្នាំ២០២៤តទៅរដ្ឋបាលរាជធានី ខេត្តនឹងចែករំលែកចំណូលសារពើពន្ធរបស់ខ្លួន ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងអត្រាថេរចំនួន៤% និងទៅឱ្យរដ្ឋបាលឃុំ សង្កាត់មានការកើនឡើងដល់៦%។ |
| **4.4** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍មុខងារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | | |
| 4.4.2 | ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា | 120. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ប្រព័ន្ធ | សាកល្បង | អនុវត្ត | សាកល្បង | កំពុងដំណើរការ | – បានកំពុងសាកល្បងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) នៅរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេស ដោយបានបណ្តុះបណ្តាលដល់មន្ត្រីជំនាញ មន្ត្រីឃុំ សង្កាត់ចំនួន៧វគ្គពីថ្ងៃទី២០ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ តាមប្រព័ន្ធអនឡាញ (Zoom) ដែលមានសមាសភាពចូលរួមសរុបចំនួន ៣.៣០៤រូប និងគ្រោងដាក់ឱ្យអនុវត្តជាផ្លូវការនៅរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសនាដើមខែមករា ឆ្នាំ២០២៤។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | 121. ភាគរយនៃការទូទាត់តាមប្រព័ន្ធឌីជីថលសម្រាប់អង្គភាព/ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | ភាគរយ | រៀបចំ | សាកល្បង | សាកល្បង | បានបញ្ចប់ | – បានពង្រីកការអនុវត្តសាកល្បងប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយ ខេត្តគោលដៅចំនួន១៣ រួមមាន៖ រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តកណ្ដាល ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំងនិងអនុវត្តជាផ្លូវការនៅឆ្នាំ២០២៤។ |
| **4.5** | **ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់** | | | | | | | |
| 4.5.1 | ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 122. ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមុខងារដែលបានផ្ទេរ | ការផ្ទេរ | | អនុវត្ត | | មិនទាន់បានអនុវត្ត | |
| | | 123. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលរាជធានី ខេត្តត្រូវបានពង្រឹងការអនុវត្ត | ប្រព័ន្ធ | | អនុវត្ត | អនុវត្ត | បានបញ្ចប់ | – រដ្ឋបាលរាជធានី ខេត្តទាំង២៥បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានដាក់ឱ្យអនុវត្តតាំងពីខែមករា ឆ្នាំ២០២១។ |
| | | 124. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ប្រព័ន្ធ | | អនុវត្ត | អនុវត្ត | បានបញ្ចប់ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទូទាំងប្រទេសតាំងពីខែមីនា ឆ្នាំ២០២៣។ |
| **4.6** | **មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ** | | | | | | | |
| 4.6.1 | ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាល ក្រុង ស្រុក | 125. អត្រាផ្ទេរធនធានពីថវិកាជាតិទៅឱ្យមូលនិធិក្រុង ស្រុក | អត្រា | 1.3 | 1.4 | 1.4 | បានបញ្ចប់ | – រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ពីឆ្នាំ២០២៤-២០២៨ ដែលមានអត្រា១,៦% ដែលអត្រានេះ មានការកើនឡើង ០,១% ធៀបទៅនឹង អត្រាផ្ទេរនៅក្នុងឆ្នាំ២០២៣។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | 126. ការរៀបចំលិខិតបទដ្ឋានស្តីពីការចូលរួមធនធានពីថវិការដ្ឋ (២០២៤-២០២៨) និងពិនិត្យមើលឡើងវិញនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវិភាជធនធានពីមូលនិធិរដ្ឋបាលក្រុង ស្រុក | លិខិតបទដ្ឋាន | | អនុវត្ត | | បានបញ្ចប់ | – អនុក្រឹត្យលេខ១៥២ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ ដែលមានអត្រា១,៦% ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣<br>– ធនធានថវិការបស់រដ្ឋបាលក្រុង ស្រុកសម្រាប់ឆ្នាំ២០២៣នេះ មានចំនួន៦៨០.៨០៣លានរៀល (សមមូល១៧០លានដុល្លារ) មានការកើនឡើងចំនួន៥០.៥៩៦លានរៀល ស្មើនឹង៨% ធៀបទៅនឹងថវិការបស់រដ្ឋបាលក្រុងស្រុកឆ្នាំ២០២២<br>– ធនធានថវិការបស់រដ្ឋបាលក្រុង ស្រុកសម្រាប់ឆ្នាំ២០២៤មានចំនួន២.២៥៥.២៨៤លានរៀល (សមមូល៥៥៥លានដុល្លារ) មានការកើនឡើងចំនួន១.៥៧៤.៤៨១លានរៀល ស្មើនឹងជាង៣៣០% ធៀបទៅនឹងថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២៣។ ថវិកាកើនឡើងនេះ គឺភាគច្រើនលើសលុបជាថវិកាផ្ទេរក្នុងវិស័យអប់រំ ស្របតាមមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដែលមានចំនួនប្រមាណជាង៤០០លានដុល្លារ។ |
| 4.6.2 | ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 127. ការសិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | | រៀបចំ | ការសិក្សា | មិនទាន់បានអនុវត្ត | |
| **4.7** | **មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| 4.7.1 | ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមាន | 128. ការសិក្សាអំពីលក្ខណៈវិនិច្ឆ័យ រូបមន្ត និងលក្ខខណ្ឌនានា ដើម្បីជាមូលដ្ឋានធ្វើការគណនាទំហំធនធានហិរញ្ញវត្ថុ | ការសិក្សា | | | អនុវត្ត | មិនទាន់បានអនុវត្ត | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | បច្ចុប្បន្ន ព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង | សម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | |
| | | 129. ការសិក្សាលើការរៀបចំការដាក់បញ្ចូលធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារទៅក្នុងគម្រោងថវិកាឯកភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | | អនុវត្ត | ការសិក្សា | មិនទាន់បានអនុវត្ត | |
| | | 130. ការសិក្សាអំពីខ្ទង់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបានពីការឧបត្ថម្ភធនពីថ្នាក់ជាតិក្នុងក្របខ័ណ្ឌជាធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងខ្ទង់ថវិកាសម្រាប់ការឧបត្ថម្ភធនក្នុងក្របខ័ណ្ឌជាធនធានហិរញ្ញវត្ថុផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ដោយឡែកពីគ្នា | ការសិក្សា | | អនុវត្ត | ការសិក្សា | មិនទាន់បានអនុវត្ត | |
| **4.10** | **ប្រព័ន្ធសវនកម្ម និងអធិការកិច្ចលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | | | | | | | |
| 4.10.1 | ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | 131. សេចក្តីណែនាំស្តីពីនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រាជធានី ខេត្ត និងក្រុង ស្រុក | សេចក្តីណែនាំ | | 1 | 1 | កំពុងដំណើរការ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងសិក្សាស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងរៀបចំការសិក្សា អំពីលទ្ធភាពនៃការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងរៀបចំនូវនីតិ វិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 5 | **ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ÷ រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសម្រុះសម្រួលដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។** | | | | | | | |
| 5.1 | **ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព** | | | | | | | |
| 5.1.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច | 132. មេរៀនបទពិសោធន៍ស្តីពីការអនុវត្តមុខងារជាកាតព្វកិច្ចត្រូវបានរៀបចំ | ករណីសិក្សា | | 1 | 1 | មិនទាន់បានអនុវត្ត | |
| | | 133. ចំនួនភាគរយសរុបនៃមុខងារជាកាតព្វកិច្ចដែលមានសេចក្តីណែនាំបច្ចេកទេសដែលបានរៀបចំ | ភាគរយ | 50% | 70% | 40% | បានបញ្ចប់ | – សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នចំនួន០៨ រួមមាន ៖ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនិវានុវត្តន៍ ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជននិងកីឡា<br>– សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីអនុវត្តមុខងារការសាងសង់ ការជួសជុល ការថែទាំផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានា និងការងារគ្រប់គ្រងដីចំណីផ្លូវជាតិ ផ្លូវខេត្តដែលស្ថិតក្នុងទីប្រជុំជន កំពុងរៀបចំដោយក្រសួងសាធារណការ និងដឹកជញ្ជូន<br>– បានសហការជាមួយក្រុមការងារធនាគារពិភពលោក និងអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យ និងរៀបចំការ គ្រប់គ្រង និងប្រតិបត្តិការទីលានទុកដាក់សំរាមនៅតាមក្រុងមួយចំនួន និងបានសិក្សាវាយតម្លៃលើគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា ក្រោមក្របខណ្ឌហិរញ្ញប្បទានរបស់ធនាគារពិភពលោក។ ជាមួយគ្នានេះ ក្រោមការគាំទ្រពី |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | គម្រោងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅកម្ពុជា ( ISD/GIZ ) បាននិងកំពុង រៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រសម្រាប់ការកៀរគរធនធានគាំទ្រដល់ការផ្តល់សេវាសំរាម និងសំណល់រឹង។ |
| | | 134. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលអំពីការអនុវត្តមុខងារជាកាតព្វកិច្ចដែលបានអនុវត្តសម្រាប់រដ្ឋបាល ក្រុង ស្រុក | វគ្គ | | 4 | 1 | កំពុងដំណើរការ | – លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធបានរៀបចំកិច្ចប្រជុំ ត្រួតពិនិត្យ និងសម្របសម្រួលដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តមុខងារសុខាភិបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួងអប់រំ យុវជននិងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ បានចុះផ្សព្វផ្សាយអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ ការគ្រប់គ្រងបុគ្គលិកអប់រំ ការគ្រប់គ្រងថវិកាអប់រំ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ដោយមានអ្នកចូលរួមសរុប១.១៦៣នាក់<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយក្រសួងអប់រំ យុវជននិងកីឡាមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ បានរៀបចំបញ្ចប់នូវសៀវភៅណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារអប់រំ និងបានរៀបចំការបណ្តុះបណ្តាលអំពីសៀវភៅណែនាំនេះដល់រដ្ឋបាលក្រុង ស្រុកនៃខេត្តចំនួន០៤រួមមាន ៖ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដែលមានសិក្ខាកាមចូលរួមសរុប ចំនួន១៦៣នាក់។ លេខាធិការដ្ឋាន គ.ជ.អ.ប. គ្រោងនឹងរៀបចំការបណ្តុះប |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ណ្តាលនេះ ទៅដល់ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសនៅដើមឆ្នាំ២០២៤ខាងមុខនេះ។ |
| | | 135. ការផ្ទេរមុខងារក្នុងវិស័យព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | អនុក្រឹត្យ | សេចក្តីព្រាង | អនុម័ត | សេចក្តីព្រាង | កំពុងដំណើរការ | – វឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងច្បាប់ព្រៃឈើ និងច្បាប់ជលផលត្រូវបានរាយការណ៍ជូនកិច្ចប្រជុំ គ.ជ.អ.ប. លើកទី២១ ដែលបានរៀបចំកាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣។<br>– សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានបញ្ចូលក្នុងក្រមបរិស្ថាន ដែលបានដាក់ឱ្យអនុវត្តរួចរាល់ ក្នុងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។ |
| 5.1.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស | 136. នីតិវិធីសម្រាប់អនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានពិនិត្យ និងកែសម្រួល | ការសិក្សា | | 1 | សៀវភៅណែនាំ | កំពុងដំណើរការ | – សៀវភៅណែនាំស្តីពីកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យ និងរៀបចំឡើងវិញ ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស<br>– សៀវភៅណែនាំស្តីពីការរៀបចំរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបាន រៀបចំ និងផ្សព្វផ្សាយអនុវត្តដោយក្រសួងមហាផ្ទៃក្នុងឆ្នាំ២០២៣។ |
| | | 137. នីតិវិធីសម្រាប់អនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានពិនិត្យ និងកែសម្រួល | ការសិក្សា | | 1 | សៀវភៅណែនាំ | កំពុងដំណើរការ | – សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ កំពុងត្រូវបានពិនិត្យ និងកែសម្រួល ឡើងវិញឱ្យបានសមស្របទៅតាមគោលការណ៍ ច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលបានដាក់ចេញ និងផ្តល់ភាពងាយស្រួល និងច្បាស់លាស់សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ |
| **5.2** | **យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួលឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងពិរុញ្ញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | | | | | | | |
| 5.2.1 | ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវា | 138. បែបបទ និងនីតិវិធីនៃការផ្តល់សេវាត្រូវបានកែសម្រួល និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | 1 | | កំពុងដំណើរការ | លិខិតបទដ្ឋានដែលកំពុងដំណើរការរៀបចំរួមមាន ៖<br>– សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | រដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត | | | | | | – សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការផ្តល់ថវិកាប្រាក់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– សេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារផ្តល់សេវាក្នុងវិស័យពាណិជ្ជកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវារដ្ឋបាលក្នុងវិស័យសុខាភិបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– សេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារអភិវឌ្ឍន៍ក្នុងវិស័យពាណិជ្ជកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីបែបបទ និងនីតិវិធីនៃការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យពាណិជ្ជកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីការអនុវត្តមុខងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីអនុវត្តមុខងារការសាងសង់ ការជួសជុល ការថែទាំផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានា និងការងារគ្រប់គ្រងដីចំណីផ្លូវជាតិ ផ្លូវខេត្តដែលស្ថិតក្នុងទីប្រជុំជន<br>– សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍សម្របសម្រួលការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា។ |
| | | 139. ចំនួនសរុបសេវារដ្ឋបាលដែលបានផ្តល់ដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត | សេវារដ្ឋបាល | 69ម៉ឺនសេវា | កើនឡើង ១០% | 62ម៉ឺនសេវា | បានបញ្ចប់ | – ២០២៣នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត បានផ្តល់សេវារដ្ឋបាលសរុបចំនួន៦២៥.៧២៩សេវា ស្មើនឹង៩០% ធៀបនឹងចំនួនសេវាសរុបដែលបានផ្តល់ក្នុងឆ្នាំ២០២២។ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | 140. ចំនួនសរុបចំណូលនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត (គិតជាលានរៀល) | ចំណូល | 113,000 លានរៀល | កើនឡើង ១០% | 90,897 លានរៀល | បានបញ្ចប់ | – ឆ្នាំ២០២៣នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន៩០.៨៩៦.៩៣០.៥៤៩រៀល (២២.៧២៤.២៣២,៦៣ដុល្លារអាមេរិក) ស្មើនឹង ៨០% ធៀបនឹងចំណូលសរុបឆ្នាំ២០២២។ |
| 5.2.2 | ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 141. ចំនួនសរុបសេវារដ្ឋបាលដែលបានផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | សេវារដ្ឋបាល | 1,56 លានសេវា | កើនឡើង ១០% | 2,6លានសេវា | បានបញ្ចប់ | – ឆ្នាំ២០២៣នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ បានផ្តល់សេវារដ្ឋបាលសរុបចំនួន ២.៦៦២.៥៩៨សេវា ស្មើនឹង១៧០% ធៀបនឹងសេវាសរុបដែលផ្តល់ក្នុងឆ្នាំ២០២២។ |
| | | 142. ចំនួនសរុបចំណូលនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ (គិតជាលានរៀល) | ចំណូល | 11,009 លានរៀល | កើនឡើង ១០% | 13,317 លានរៀល | បានបញ្ចប់ | – ឆ្នាំ២០២៣នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន១៣.៣១៧.៤២០.០៥៦រៀល (៣.៣២៩.៣៥៥ដុល្លារអាមេរិក) ស្មើនឹង១២០% ធៀបនឹងចំណូលសរុបឆ្នាំ២០២២។ |
| 5.2.3 | ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ | 143. ការផ្តល់សេវាក្នុងវិស័យចំនួនបីបានផ្តល់តាមប្រព័ន្ធអនឡាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង | ការផ្តល់សេវា | | អនុវត្តសាកល្បង | អនុវត្តសាកល្បង | បានបញ្ចប់ | – ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញដែលកំពុងដំណើរការសាកល្បងរួមមាន៤ វិស័យ ៖<br>○ វិស័យវប្បធម៌<br>○ វិស័យឧស្សាហកម្ម<br>○ វិស័យទេសចរណ៍<br>○ វិស័យកសិកម្ម |
| **5.3** | **យុទ្ធសាស្ត្រលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជនត្រូវបានពិនិត្យ កែសម្រួល និងជំរុញការអនុវត្ត** | | | | | | | |
| 5.3.1 | ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន | 144. បញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនានាត្រូវបានរៀបចំដោយរាជធានី ខេត្ត | បញ្ជី | | 1 | | មិនទាន់បានអនុវត្ត | |
| **5.4** | **ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 5.4.1 | ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 145. ការសិក្សាអំពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | ការសិក្សា | | 1 | | មិនទាន់បានអនុវត្ត | |
| 5.4.2 | ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | 146. ឯកសារបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ | សៀវភៅណែនាំ | សេចក្តីព្រាង | អនុម័ត | ការសិក្សាវាយតម្លៃ | កំពុងដំណើរការ | – លេខាធិការដ្ឋាន គ.ជ.អ.ប. បានសិក្សាវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តគោលនយោបាយសុវត្ថិភាព បរិស្ថាន និងសង្គមក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងពិនិត្យ និងបញ្ជ្រាបគោលនយោបាយនេះក្នុងសៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ |
| 5.4.4 | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 147. លិខិតបទដ្ឋានសម្រាប់អនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវនានា ត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | | 1 | សៀវភៅណែនាំ | កំពុងដំណើរការ | – លេខាធិការដ្ឋាន គ.ជ.អ.ប. បានសិក្សាវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តគោលនយោបាយសុវត្ថិភាព បរិស្ថាន និងសង្គមក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងពិនិត្យ និងបញ្ជ្រាបគោលនយោបាយនេះក្នុងសៀវភៅណែនាំស្តីពីការអនុវត្ត គម្រោងមូលនិធិឃុំសង្កាត់<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. បានចូលរួមកិច្ចប្រជុំកែសម្រួល សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់នៅចុងខែវិច្ឆិកា និងដើមខែធ្នូ ឆ្នាំ២០២៣។ |
| | | 148. លិខិតបទដ្ឋានសម្រាប់ការបញ្ជ្រាបសុវត្ថិភាព បរិស្ថាន និងសង្គមចូលទៅក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ | លិខិតបទដ្ឋាន | សេចក្តីព្រាង | អនុម័ត | | កំពុងដំណើរការ | – លេខាធិការដ្ឋាន គ.ជ.អ.ប. បានសិក្សាវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តគោលនយោបាយសុវត្ថិភាព បរិស្ថាន និងសង្គមក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងពិនិត្យ និងបញ្ជ្រាបគោលនយោបាយនេះក្នុងសៀវភៅណែនាំស្តីពីការអនុវត្ត គម្រោងមូលនិធិឃុំសង្កាត់។ |
| | | 149. ចំនួនភាគរយនៃគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ និងអនុ | ភាគរយ | 20% | 20% | 10% | កំពុងដំណើរការ | – រដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោង "លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | វត្តដោយផ្តោតលើការបង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | | | | | | កសិកម្ម និងអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា (STARD) គម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា (CCCA) គម្រោងគាំទ្រលេខាធិការដ្ឋានគ.ជ.អ.ប. ក្នុងការបំពេញល័ក្ខខ័ណ្ឌស្ថាប័នអនុវត្តគម្រោងនៃ GCF និងគម្រោងនវានុវត្តនៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-WRP)។ |

## ឧបសម្ព័ន្ធទី២ ៖ ទន្និន្នភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣របស់ក្រសួង ស្ថាប័ន

(គិតជាលានរៀល)

| ល.រ. | ក្រសួង ស្ថាប័ន | ថវិកាឆ្នាំ២០២៣ | ថវិកាចំណាយឆ្នាំ២០២៣ | សមតុល្យ |
|---|---|---|---|---|
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | 8,550 | 8,547 | 3 |
| ២ | ក្រសួងមហាផ្ទៃ | 316 | - | 316 |
| ៣ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 258 | 174 | 85 |
| ៤ | ក្រសួងមុខងារសាធារណៈ | 79 | - | 79 |
| ៥ | ក្រសួងផែនការ | 64 | 63 | 1 |
| ៦ | ក្រសួងកិច្ចការនារី | 307 | 296 | 12 |
| ៧ | ក្រសួងអប់រំ យុវជន និងកីឡា | 100 | 53 | 47 |
| ៨ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 99 | - | 99 |
| ៩ | ក្រសួងសាធារណការ និងដឹកជញ្ជូន | 80 | 40 | 76 |
| ១០ | ក្រសួងបរិស្ថាន | 39 | 39 | - |
| ១១ | ក្រសួងទេសចរណ៍ | 45 | 45 | - |
| ១២ | ក្រសួងពាណិជ្ជកម្ម | 90 | 65 | 25 |
| ១៣ | ក្រសួងធនធានទឹក និងឧតុនិយម | 14 | 5 | 9 |
| ១៤ | ក្រសួងអភិវឌ្ឍន៍ជនបទ | 485 | 274 | 212 |
| ១៥ | ក្រសួងរ៉ែ និងថាមពល | 43 | 43 | 0 |
| ១៦ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនិវានុវត្តន៍ | 25 | - | 25 |
| ១៧ | ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ | 41 | - | 41 |
| ១៨ | ក្រសួងសុខាភិបាល | 70 | - | 70 |
| ១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 115 | 85 | 30 |
| ២០ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 75 | 75 | - |
| ២១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 51 | 18 | 33 |
| | **សរុប** | **10,945** | **9,821** | **1,124** |

## វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣របស់រាជធានី ខេត្ត (គិតជាលានរៀល)

| ល.រ. | រាជធានី ខេត្ត | ថវិកាឆ្នាំ២០២៣ | ថវិកាចំណាយឆ្នាំ២០២៣ | សមតុល្យ |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | 293 | 224.47 | 69 |
| ២ | បាត់ដំបង | 976 | 322.00 | 654 |
| ៣ | កំពង់ចាម | 1,217 | 1,201.80 | 15 |
| ៤ | កំពង់ឆ្នាំង | 194 | 174.60 | 19 |
| ៥ | កំពង់ស្ពឺ | 212 | 208.40 | 4 |
| ៦ | កំពង់ធំ | 332 | 173.01 | 159 |
| ៧ | កំពត | 889 | 817.41 | 71 |
| ៨ | កណ្តាល | 1,682 | 1,197.07 | 485 |
| ៩ | កោះកុង | 578 | 554.78 | 23 |
| ១០ | ក្រចេះ | 360 | 251.35 | 108 |
| ១១ | មណ្ឌលគិរី | 311 | 70.37 | 240 |
| ១២ | ភ្នំពេញ | 2,428 | 2,078.97 | 349 |
| ១៣ | ព្រះវិហារ | 357 | 149.18 | 208 |
| ១៤ | ព្រៃវែង | 772 | 87.20 | 685 |
| ១៥ | ពោធិ៍សាត់ | 201 | 164.13 | 37 |
| ១៦ | រតនគិរី | 179 | 177.60 | 2 |
| ១៧ | សៀមរាប | 715 | 128.09 | 587 |
| ១៨ | ព្រះសីហនុ | 239 | 149.00 | 90 |
| ១៩ | ស្ទឹងត្រែង | 166 | 90.78 | 76 |
| ២០ | ស្វាយរៀង | 467 | 422 | 45 |
| ២១ | តាកែវ | 521 | 377.35 | 144 |
| ២២ | ឧត្តរមានជ័យ | 195 | 126.48 | 69 |
| ២៣ | កែប | 33 | 24.40 | 8 |
| ២៤ | ប៉ៃលិន | 182 | 11.95 | 170 |
| ២៥ | ត្បូងឃ្មុំ | 541 | 449.87 | 91 |
| | សរុប | **14,038** | **9,632** | **4,406** |

## វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣របស់ដៃគូអភិវឌ្ឍ (គិតជាលានរៀល)

| ល.រ. | គម្រោង | ប្រភពមូលនិធិ | ថវិកា | ចំណាយ | សមតុល្យ |
|---|---|---|---|---|---|
| ១ | ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្ម ខ្នាតតូច ជំហានទី២ (TSDD) | ADB | 65,811 | 63,125 | 2,686 |
| ២ | ការលើកកម្ពស់អាហារូបត្ថម្ភ (CNP) | IFAD | 9,949 | 10,439 | (490) |
| ៣ | ការអភិវឌ្ឍសមត្ថភាពដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) | ADB | 8,212 | 998 | 7,213 |
| ៤ | ការគាំទ្រមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) | ADB | 27,629 | - | 27,629 |
| ៥ | ការគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ (ISAF) | WB | 1,835 | 24,620 | (22,784) |
| ៦ | លើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (CSOs) | WB | 13,978 | 7,855 | 6,124 |
| ៧ | នវានុវត្តន៍នៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-WRP) | UNCDF | 1,107 | 1,222 | (115) |
| ៨ | ការលើកកម្ពស់វិស័យសេវាសង្គម | UNICEF | 2,870 | 644 | 2,226 |
| ៩ | ការលើកកម្ពស់កិច្ចការពារកុមារ | UNICEF | 320 | 488 | (168) |
| ១០ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា (ISD) | GIZ | 12,526 | - | 12,526 |
| ១១ | ការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា (CCCA) | UNDP | 330 | 158 | 172 |
| ១២ | គាំទ្រលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការបំពេញល័ក្ខខ័ណ្ឌស្ថាប័នអនុវត្តគម្រោងនៃ មូលនិធិអាកាសធាតុបៃតង GCF | GCF | 2,068 | 693 | 1,375 |
| ១៣ | គម្រោងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា (STARD) | UNDP | 263 | 309 | (46) |
| ១៤ | ការពង្រឹងតួនាទីសមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (ASAC) | ASAC | 740 | 551 | 189 |
| | **សរុប** | | **147,638** | **110,104** | **36,537** |

# ឧបសម្ព័ន្ធទី៣ ៖ ស្ថានភាពនៃការគ្រប់គ្រងហានិភ័យ

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| **សមាសភាគទី១ ៖ ការគ្រប់គ្រង និងការសម្របសម្រួលកម្មវិធីកំណែទម្រង់** | | | | | | |
| ១ | ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយធម្មជាតិនាំឱ្យពន្យារពេល និងផ្អាកការអនុវត្តសកម្មភាពនានានៃ ផ.ស.ថ. | ទាប | មធ្យម | ➢ ពិនិត្យ និងកែសម្រួល ផ.ស.ថ. ដោយផ្ដោតលើសកម្មភាពមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ រៀបចំ និងពង្រឹងការអនុវត្តសកម្មភាពនានា តាមរយៈប្រព័ន្ធអនឡាញ | ក្រសួង ស្ថាប័នអនុវត្តទាំងអស់ | – ស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ សម្រាប់ឆ្នាំ២០២៣នេះ គឺមិនមានផលប៉ះពាល់ទេ ដោយសាររាជរដ្ឋាភិបាលបានទប់ស្កាត់ និងមានការចាក់ថ្នាំបង្ការបានទាន់ពេលវេលា នាំឱ្យដំណើរការនៃការអនុវត្ត ផ.ស.ថ. ត្រូវបានអនុវត្តទៅតាមផែនការដែលបានគ្រោងទុក។ |
| ២ | ធនធានសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ដែលបានសន្យាគាំទ្រដោយក្រសួង ស្ថាប័ន និងរាជធានី ខេត្ត មិនបានវិភាជគ្រប់គ្រាន់ និងផ្ដល់គ្រប់ចំនួន និងទាន់ពេលវេលា | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដានការអនុវត្តគ្រោងថវិកាឆ្នាំ២០២៣របស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត<br>➢ ពង្រឹងការតាមដានការអនុវត្តសេចក្ដីសម្រេចរួម<br>➢ ពង្រឹងទំនាក់ទំនង និងកិច្ចសហការជាមួយ MEF ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តថវិកាសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ | – ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានវិភាជថវិកាក្នុងចំនួនសមស្រប (៦.២លានដុល្លារ) សម្រាប់គាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ និងបានចំណាយសម្រាប់ការអនុវត្តកិច្ចការនេះ ចំនួនប្រមាណ២៥%ដូចមានបរិយាយនៅផ្នែកស្ថានភាពហិរញ្ញវត្ថុខាងលើ។ |
| ៣ | ភាពអសកម្មភាពនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនាំឱ្យដំណើរការ និងប្រសិទ្ធភាពនៃការងារកំណែទម្រង់មានការថយចុះ រួមបញ្ចូលទាំងការអនុវត្ត ផ.ស.ថ. សេចក្ដីសម្រេចរួម និងកិច្ចព្រមព្រៀងនានា | មធ្យម | មធ្យម | ➢ ពង្រឹងការតាមដាន និងការអនុវត្តការងារកំណែទម្រង់ដោយ គ.ជ.អ.ប. តាមរយៈកិច្ចប្រជុំ គ.ជ.អ.ប.<br>➢ ពង្រឹងការរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការ អនុវត្ត ផ.ស.ថ. ជាមួយស្ថាប័នអនុវត្តនានា | – គ.ជ.អ.ប.<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – គ.ជ.វ.វ.របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំកិច្ចប្រជុំរបស់ខ្លួនជាប្រចាំ ដើម្បីរៀបចំ និងត្រួតពិនិត្យការអនុវត្តផ.ស.ថ. ឆ្នាំ២០២៣។ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| **សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| ១ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកមិនអាចបំពេញតួនាទីរបស់ខ្លួនបានពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងត្រួតពិនិត្យលើការអនុវត្តការងាររបស់គណៈអភិបាល និងបុគ្គលិករបស់ខ្លួន | ខ្ពស់ | ខ្ពស់ | ➢ រៀបចំវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការយល់ដឹងបន្ថែមទៅក្នុងការអនុវត្តតួនាទី និងអាណត្តិការងាររបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ<br>➢ ការរៀបចំឱ្យមានគម្រោងចំណាយច្បាស់លាស់របស់ក្រុមប្រឹក្សានៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. | - សាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពតួនាទីរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ២ | មន្ត្រីរដ្ឋបាលខេត្តមិនផ្លាស់ប្តូរទម្លាប់ក្នុងការគ្រប់គ្រង និងអន្តរាគមន៍លើការអនុវត្តការងាររបស់រដ្ឋបាលមូលដ្ឋានឱ្យទៅជាការជួយគាំទ្រផ្នែកបច្ចេកទេស និងការប្រឹក្សាយោបល់ | មធ្យម | ខ្ពស់ | ➢ ផ្តល់គោលការណ៍ណែនាំ និងការបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលខេត្តអំពីទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋាន<br>➢ ជំរុញ និងពង្រឹងការតាមដានត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍ពីក្រសួងមហាផ្ទៃ ក្នុងករណីដែលមានអាកប្បកិរិយា និងសកម្មភាពមិនសមស្របរបស់មន្ត្រីនៃរដ្ឋបាលខេត្ត | - ក្រសួងមហាផ្ទៃ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. | - សាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពតួនាទីរបស់គណៈអភិបាល និងមន្ត្រីរដ្ឋបាលខេត្តអំពីទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋាន |
| ៣ | ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិមិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីការបង្កើនចំនួនស្ត្រី | មធ្យម | ខ្ពស់ | ➢ ពង្រឹងការផ្សព្វផ្សាយអំពីផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ<br>➢ ពង្រឹងការត្រួតពិនិត្យ និងការគាំទ្រ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | - លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងមហាផ្ទៃ | - ផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និង កែសម្រួល ដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងសហការជាមួយក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ។ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| **សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | | | | | | |
| ១ | សិទ្ធិអំណាចក្នុងការជ្រើសរើស និងរៀបចំបុគ្គលិកមិនអាចអនុវត្តបានតាមគោលការណ៍ បទប្បញ្ញត្តិដែលបានកំណត់ | មធ្យម | មធ្យម | ➢ ការរៀបចំសេចក្តីណែនាំបន្ថែមរបស់ថ្នាក់ជាតិ ដើម្បីពង្រឹងការអនុវត្តគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់រួចហើយ<br>➢ ការពង្រឹងការតាមដាន ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងរៀបចំបុគ្គលិក | – ក្រសួងមុខងារសាធារណៈ<br>– ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំផែនការ និងជ្រើសរើសបុគ្គលិករបស់ខ្លួនស្របតាមបែបបទ និងនីតិវិធីដែលមានស្រាប់។ |
| ២ | ការវាយតម្លៃបុគ្គលិកមិនត្រូវបានអនុវត្តទៀងទាត់ និងត្រឹមត្រូវ | ខ្ពស់ | មធ្យម | ➢ ពង្រឹងការគាំទ្រ ការតាមដានត្រួតពិនិត្យការអនុវត្តផែនការវាយតម្លៃបុគ្គលិកទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីថ្នាក់ជាតិ | – ក្រសួងមហាផ្ទៃ<br>– ក្រសួងមុខងារសាធារណៈ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – បុគ្គលិកថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានវាយតម្លៃរៀងរាល់២ឆ្នាំម្តងសម្រាប់តម្លើងថ្នាក់ និងឋានន្តរស័ក្តិ។ |
| ៣ | ខ្វះការចូលរួមរបស់មន្ទីរ អង្គភាព ជំនាញនាំឱ្យការអភិវឌ្ឍសមត្ថភាព ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្ត មុខងារដែលបានផ្ទេរមិនសូវមានប្រសិទ្ធភាព | មធ្យម | មធ្យម | ➢ ពង្រឹងកិច្ចសហការ និងផ្តល់ការគាំទ្រដល់មន្ទីរ អង្គភាពជំនាញក្នុងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌ<br>➢ ពង្រឹងការរៀបចំ និងការអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ តាមរយៈវិធីសាស្ត្រផ្សេងៗ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– រដ្ឋបាលរាជធានី ខេត្ត | – មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានវិភាជថវិកាសម្រាប់អភិវឌ្ឍសមត្ថភាពមន្ត្រីការិយាល័យជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| ៤ | ពុំមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពអន្តរកាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | ខ្ពស់ | មធ្យម | ➢ ពង្រឹងការតាមដានក្រសួងមហាផ្ទៃ ក្នុងការរៀបចំ និងការវិភាជថវិកាសម្រាប់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>➢ សម្របសម្រួល និងសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការផ្តល់ថវិកាគាំទ្រផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>➢ សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរធនធានសម្រាប់អនុវត្តផែនការ | – ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – ឆ្នាំ២០២៣នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងបានរៀបចំវគ្គអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣៧វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន១.៥៧០នាក់ ស្ត្រីចំនួន៥៨៤នាក់។ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | អភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | | |
| ៥ | សមត្ថភាពបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅមានកម្រិតក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | មធ្យម | មធ្យម | ➢ ពង្រឹងការតាមដាន ការគាំទ្រទៅដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>➢ ការអភិវឌ្ឍសមត្ថភាពបន្ថែមទៅលើស្តង់ដារនៃការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | – គ.ជ.អ.ប.<br>– គ.ជ.វ.វ. ក្រសួង ស្ថាប័នអនុវត្ត | – ឆ្នាំ២០២៣នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងបានរៀបចំវគ្គអភិវឌ្ឍសមត្ថភាពបន្ថែមស្តង់ដារនៃការអនុវត្តមុខងារដែលបានផ្ទេរដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| **សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធកសាងផែនការ និងថវិកាថ្នាក់ក្រោមជាតិ** | | | | | | |
| ១ | រដ្ឋបាលក្រុង ស្រុកមានធនធានថវិកា ផ្នែកអភិវឌ្ឍតិចតួចដែលមិនអាចអនុវត្ត មុខងារផ្តល់សេវា ក៏ដូចជាការឆ្លើយតបនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព | មធ្យម | ខ្ពស់ | ➢ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាន និង សេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងចំណាយផ្នែកអភិវឌ្ឍន៍របស់ក្រុង ស្រុក<br>➢ សិក្សា និងរៀបចំលិខិតបទដ្ឋាននានាអំពីការបង្កើនចំណូលដល់រដ្ឋបាលក្រុង ស្រុក | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – មូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ ត្រូវបានវិភាជចំនួន ១,៦% នៃចំណូលចរន្តថវិកាជាតិមានការកើនឡើងចំនួន០,១% ធៀបនឹងឆ្នាំ២០២៣។ |
| ២ | ការផ្ទេរការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពន្យារពេល | មធ្យម | ខ្ពស់ | ➢ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃត្រូវបន្តធ្វើការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងផ្ទេរមុខងារពាក់ព័ន្ធនានា | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃកំពុងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផ្ទេរមុខងារពាក់ព័ន្ធនានា |
| ៣ | ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និង គ្រោះធម្មជាតិនាំឱ្យមានការកាត់បន្ថយថវិកាសម្រាប់ការអនុវត្តសកម្មភាពនានានៃ ផ.ស.ថ. ដើម្បីយកទៅប្រើប្រាស់ ដើម្បីការពារ និងទប់ស្កាត់ហានិភ័យនេះ | មធ្យម | ខ្ពស់ | ➢ ពិនិត្យ និងកែសម្រួល ផ.ស.ថ. ដោយផ្តោតលើសកម្មភាព និងគម្រោងមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ រៀបចំ និងពង្រឹងការអនុវត្តសកម្មភាពនានាតាមរយៈប្រព័ន្ធអនឡាញ | – ស្ថាប័នអនុវត្តទាំងអស់ | – ស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ សម្រាប់ឆ្នាំ២០២៣នេះ គឺមិនមានផលប៉ះពាល់ទេ ដោយសាររាជរដ្ឋាភិបាលបានទប់ស្កាត់ និងមានការចាក់ថ្នាំបង្ការបានទាន់ពេលវេលា នាំឱ្យដំណើរការនៃការអនុវត្ត ផ.ស.ថ. ត្រូវបានអនុវត្តទៅតាមផែនការដែលបានគ្រោងទុក។ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| **សមាសភាគទី៥ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | | | | | | |
| ១ | ភាពយឺតយ៉ាវក្នុងការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក | ទាប | ខ្ពស់ | ➢ ជំរុញ និងពង្រឹងការរៀបចំឯកសារចាំបាច់នានានៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធនានា<br>➢ លេខាធិការដ្ឋាន គ.ជ.អ.ប. តាមដាន សហការ និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការរៀបចំឯកសារពាក់ព័ន្ធនានា | - ក្រសួង ស្ថាប័ន<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. | - សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នចំនួន០៨ រួមមាន ៖ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនិវានុវត្តន៍ ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជននិងកីឡា។ |
| ២ | រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួន ពុំមានបុគ្គលិក និងសមត្ថភាពសមស្របនាំឱ្យការអនុវត្តមុខងារដែលបានផ្ទេរពុំមានប្រសិទ្ធភាព | ទាប | មធ្យម | ➢ សម្របសម្រួល និងពង្រឹងកិច្ចសហការរវាងកម្មវិធីកំណែទម្រង់ទាំងបីក្នុងការសម្របសម្រួលដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង<br>➢ ពង្រឹងការតាមដាន ការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌនៅនឹងកន្លែង<br>➢ សិក្សា និងពិនិត្យមើលជម្រើសនានាក្នុងការផ្ទេរបុគ្គលិកពីមន្ទីរ អង្គភាពជំនាញទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួង ស្ថាប័ន<br>- រាជធានី ខេត្ត | - បានរៀបចំកិច្ចប្រជុំកំណែទម្រង់ទាំង៣ ចំនួន០៣លើកសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា<br>- ឆ្នាំ២០២៣នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងបានរៀបចំវគ្គអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣៧វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន១.៥៧០នាក់ ស្ត្រីចំនួន៥៨៤នាក់។ |
| ៣ | មុខងារជាជម្រើសពាក់ព័ន្ធនឹងសេវាសង្គមមិនអាចអនុវត្តស្របទៅតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | មធ្យម | ➢ គោលការណ៍ណែនាំច្បាស់លាស់ស្តីពីការជ្រើសរើស ការរៀបចំ និងការអនុវត្តមុខងារជាជម្រើសដែលពាក់ព័ន្ធនឹងសេវាសង្គម | - ក្រសួងមហាផ្ទៃ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បាន |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | ➢ ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់អាទិភាពដល់ការចំណាយលើការផ្តល់សេវាសង្គមសម្រាប់ក្រុមក្រីក្រ និងងាយរងគ្រោះ | | កំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន។ |
| ៤ | រដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់តិចតួចអំពីអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះទាំងនៅក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងគម្រោងថវិកានានា | ខ្ពស់ | មធ្យម | ➢ រៀបចំផែនការសកម្មភាពនិង ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ<br>➢ ពង្រឹងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>➢ ពង្រឹងការវាយតម្លៃ និងតាមដានដល់ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំ និងអនុវត្តកម្មវិធីផ្តល់ពានរង្វាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារបានល្អ។ | - លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួងមហាផ្ទៃ | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន រួមបញ្ចូលទាំងចំណាយសម្រាប់ការងារសមភាពយេនឌ័រ បរិយាប័ន្ន និងសង្គម។ |
| ៥ | ក្រុង ស្រុក ខណ្ឌមួយចំនួនមិនសូវយកចិត្តទុកដាក់ និងផ្តួចផ្តើមគំនិតក្នុងការអនុវត្តលិខិតបទដ្ឋាននានា ដែលមាន និងមុខងារនានាដែលបានផ្ទេរនាំឱ្យការគាំទ្ររបស់រាជធានី ខេត្ត មិនមានប្រសិទ្ធភាព | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដាន និងគាំទ្រក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារដែលបានផ្ទេរ<br>➢ ធ្វើការណែនាំដល់ក្រុង ស្រុក ខណ្ឌដែលអសកម្ម | - លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួង ស្ថាប័ន<br>- រាជធានី ខេត្ត | - រដ្ឋបាលរាជធានី ខេត្តបានចុះតាមដាន និងគាំទ្រក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ជាប្រចាំក្នុងការរៀបចំ និងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិរួមទាំងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ។ |
| ៦ | ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និងគ្រោះធម្មជាតិនាំឱ្យពន្យារពេល និងផ្អាកសកម្មភាពនៃការរៀបចំ និងការអនុវត្តសកម្មភាព និងគម្រោងនានានៃ ផ.ស.ថ. | ទាប | មធ្យម | ➢ ពិនិត្យ និងកែសម្រួល ផ.ស.ថ. ដោយផ្តោតលើសកម្មភាពមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ រៀបចំ និងពង្រឹងការអនុវត្តសកម្មភាពនានា តាមរយៈប្រព័ន្ធអនឡាញ | - ស្ថាប័នអនុវត្តទាំងអស់ | - ស្ថានភាពជំងឺកូវីដ-១៩ បានកាត់បន្ថយស្ទើរតែទាំងស្រុង និងពុំមានផលប៉ះពាល់ដល់ការអនុវត្ត ផ.ស.ថ.។ |

| ល.រ. | හានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| ៧ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការចំណាយបន្ថែមលើការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា | មធ្យម | ខ្ពស់ | ➢ កៀរគរធនធានបន្ថែមពីមូលនិធិអាកាសធាតុបៃតង និងពីប្រភពផ្សេងទៀត ដើម្បីផ្ដល់ហិរញ្ញប្បទានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | លេខាធិការដ្ឋាន គ.ជ.អ.ប. | – អនុក្រឹត្យស្ដីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន រួមបញ្ចូលទាំងចំណាយសម្រាប់ការពង្រឹងភាពធន់ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា។ |
| ៨ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | មធ្យម | មធ្យម | ➢ បញ្ចូលការលើកកម្ពស់ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុទៅក្នុងវគ្គបណ្ដុះបណ្ដាលអំពីភាពជាអ្នកដឹកនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | លេខាធិការដ្ឋាន គ.ជ.អ.ប. | – សាលាជាតិរដ្ឋបាលមូលដ្ឋានបានបញ្ជ្រាបប្រធានបទនៃការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា និងឯកសារបណ្ដុះបណ្ដាលដែលបានអនុវត្តដូចមានលទ្ធផលរៀបរាប់ខាងលើ។ |